សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Économiques
Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ

ស្រាវជ្រាវចាប់ពីថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០២១ ដល់ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០២១


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ខង ម៉េងស្រី**

**មាគ មាលាតី**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ចាន់ ស៊ីនដេត**


ថ្នាក់បរិញ្ញាបត្រ សេដ្ឋកិច្ចអភិវឌ្ឍន៍

ជំនាន់ទី ៥

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរបាយការណ៍ ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំទាំងពីរឈ្មោះ **វង វ៉េងទ្រី** និង **មាក មាលាតី** ជានិស្សិតថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់៥ ឆ្នាំសិក្សា២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចៈ

សូមថ្លែងអំណរគុណយ៉ាងអនេកប្បការជូនចំពោះ៖

- លោកឪពុក វង វណ្ណៈ និងអ្នកម្តាយ អ៊ូច សុខលាប
- លោកឪពុក ហាយ ហឿន និងអ្នកម្តាយ សុង ធារី

លោកអ្នកមានគុណទាំងពីរមានគុណដ៏ធំធេងក្រៃលែងគ្មានអ្វីប្រៀបស្មើបាន គឺលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំដឹងក្តីដោយបានជម្នះនូវរាល់ឧបសគ្គ និងប្រកបដោយព្រហ្មវិហារធម៌។ លោកអ្នកមានគុណទាំងពីរបានអប់រំទូន្មានប្រៀនប្រដៅលើកទឹកចិត្ត ផ្គត់ផ្គង់សព្វគ្រប់បែបយ៉ាងទាំងកម្លាំងកាយកម្លាំងចិត្ត សព្វគ្រប់បែបយ៉ាង ដោយមិនគិតពីពេលវេលា និងការលំបាកអ្វីឡើយដើម្បីឱ្យពួកយើងខ្ញុំបានសិក្សារៀនសូត្ររហូតមកដល់សព្វថ្ងៃនេះ។ គុណានុបការៈលោកដ៏ធំធេងនេះពិតជាមិនអាចយកអ្វីមកប្រៀបផ្ទឹមបានឡើយ។

- សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោកសាស្រ្តាចារ្យបណ្ឌិត **ខ៉ាន់ ស៊ុនដេត** ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ បង្ហាត់បង្រៀន និងដឹកនាំត្រួតពិនិត្យ កែតម្រូវដល់យើងខ្ញុំព្រមទាំងបញ្ចេញគំនិតសម្រាប់ការច្នៃប្រឌិតបន្ថែមទៀត ក្នុងកិច្ចការស្រាវជ្រាវនេះតាំងពីដំណើរការចាប់ផ្តើមរហូតដល់របាយការណ៍មួយចងក្រងប្រកបដោយជោគជ័យ។
- **ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង** ប្រធានការិយាល័យសិក្សា និងបណ្ឌិតសាស្រ្តាចារ្យគ្រប់មុខវិជ្ជាទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទ នីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយកម្លាំងចិត្តក្នុងការអប់រំបង្ហាត់បង្រៀន និងបានផ្តល់ចំណេះដឹងដល់យើងខ្ញុំព្រមទាំងនិស្សិតដទៃទៀតតាំងទីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់បញ្ចប់បរិញ្ញាបត្រ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរចំពោះអ្នកមានគុណទាំងអស់ឱ្យជួបប្រទះតែ សុភមង្គល និង ប្រសិទ្ធិពរជ័យពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅនេះគឺជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ជំនាន់ទី៥ នៃឆ្នាំសិក្សា ២០១៧-២០២១ ក្នុងការសិក្សាក្រោមប្រធានបទស្តីអំពី "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" ដែលវាជាប្រភេទអត្ថបទស្រាវជ្រាវថ្មីមួយដែលបានសរសេរឡើងដោយក្រុមនិស្សិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់បន្ថែមពីបញ្ហាប្រឈមនានា ក៏ដូចជាផលប៉ះពាល់ដែលមានមកលើវិស័យអប់រំក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ នេះ។

អត្ថបទស្រាវជ្រាវថ្មីនេះ គឺផ្តោតសំខាន់ទៅលើផលប៉ះពាល់ និងបញ្ហាប្រឈមផ្សេងៗដែលវិស័យអប់រំត្រូវបានទទួលរងឥទ្ធិពលពីការរាតត្បាតនៃជម្ងឺកូវីដ-១៩ ហើយវាបានរំលេចឡើងនូវចំណុចសំខាន់ៗដែលទាក់ទងនឹងការផ្លាស់ប្តូរបរិបទមកសិក្សាតាមប្រព័ន្ធអនឡាញ ក្នុងអំឡុងពេលដែលគ្រឹះស្ថានសិក្សានានានៅទូទាំងប្រទេសត្រូវបានបិទទ្វារ។ បន្ថែមពីនេះទៀតគឺយើងក៏បានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រព័ន្ធអប់រំនៅក្នុងបណ្តាប្រទេសអាស៊ានមួយចំនួន ព្រមទាំងសិក្សាលើគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជា មុននិងក្រោយពេលមានការរាតត្បាតនៃជម្ងឺកូវីដ-១៩ផងដែរ។

លើសពីនេះទៅទៀតនោះ ចំពោះអត្ថបទសារណាមួយនេះ វាត្រូវបានចងក្រងឡើងក្រោមការណែនាំរបស់សាស្ត្រាចារ្យ ដែលមានចំណេះដឹង ជំនាញ និងបទពិសោធន៍ជាច្រើនក្នុងការផ្តល់ជាអនុសាសន៍ណែនាំល្អៗ ក្នុងការចងក្រងអត្ថបទ ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវឯកសារពាក់ព័ន្ធប្រកបដោយប្រសិទ្ធភាព។

ត្បិតតែមានការលំបាកបន្តិចមែនក្នុងការចងក្រងនូវអត្ថបទសារណានេះឡើង ដោយសារតែសាលារៀនត្រូវបានបិទ ព្រោះមានការរីករាលដាលនៃជម្ងឺកូវីដ-១៩ មិនអាចជួបពិភាក្សាជាមួយនឹងសាស្ត្រាចារ្យណែនាំដោយផ្ទាល់ ចំណែកឯកសារស្រាវជ្រាវផ្សេងៗគឺត្រូវពឹងផ្អែកស្ទើរតែទាំងស្រុងតាមប្រព័ន្ធអ៊ិនធឺណេត ដោយមិនអាចទៅបណ្ណាល័យបាន ប៉ុន្តែពួកយើងខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយក្រៃលែងក្នុងការលើកយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ ព្រោះវាត្រូវទៅនឹងស្ថានភាពជាក់ស្តែងដែលកំពុងតែកើតមាននៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅតាមបណ្តាប្រទេសផ្សេងៗក្នុងពិភពលោកផងដែរ។

យើងខ្ញុំជឿជាក់ថា ការសិក្សាស្រាវជ្រាវនេះ ពិតជាមានលក្ខណៈនៅខ្វះខាតចន្លោះជាពុំខានឡើយ ហេតុនេះយើងខ្ញុំសូមអភ័យទោសនូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា អាស្រ័យដូចនេះយើងខ្ញុំរីករាយទទួលនូវការរិះគន់ ផ្តល់យោបល់ និងកែលម្អរាល់កំហុសទាំងឡាយពីសំណាក់សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ព្រមទាំងនិស្សិត មិត្តអ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយជាទីបំផុត។

ដោយក្តីគោរព និងស្រលាញ់យ៉ាងជ្រាលជ្រៅ!

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់........................................................................................................ v
បញ្ជីតារាង........................................................................................................ vi
បញ្ជីក្រាហ្វិក........................................................................................................ vii
បញ្ជីឧបសម្ព័ន្ធ........................................................................................................ viii

## សេចក្តីផ្តើម

១. លំនាំបញ្ហា........................................................................................................ ២
២. គោលបំណងនៃការស្រាវជ្រាវ........................................................................................................ ៣
៣. ចំណោទបញ្ហា........................................................................................................ ៣
៤. សារៈសំខាន់នៃការស្រាវជ្រាវ........................................................................................................ ៣
៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ........................................................................................................ ៤
៦. វិធីសាស្ត្រនៃការស្រាវជ្រាវ........................................................................................................ ៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........................................................................................................ ៥

## ជំពូកទី១
## រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ

១.១ និយមន័យ........................................................................................................ ៧
១.១.១ ការអប់រំ........................................................................................................ ៧
១.១.២ ផលប៉ះពាល់........................................................................................................ ៧
១.២ ទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ........................................................................................................ ៨
១.២.១ ទ្រឹស្តីនៃការអប់រំតាមបែបប្រពៃណី........................................................................................................ ៨
១.២.២ ទ្រឹស្តីនៃការអប់រំតាមរយៈ E-learning........................................................................................................ ៨
១.២.៣ ទ្រឹស្តីនៃការអប់រំតាមបដិវត្តន៍នៃឧស្សាហកម្ម ៤.0........................................................................................................ ៩
១.៣ ករណីសិក្សាប្រព័ន្ធអប់រំនៅក្នុងបណ្តាប្រទេសអាស៊ានមួយចំនួន........................................................................................................ ១០
១.៣.១ ប្រព័ន្ធអប់រំនៅក្នុងប្រទេសថៃ........................................................................................................ ១០
១.៣.១.១ រចនាសម្ព័ន្ធនៃការសិក្សា........................................................................................................ ១០

១.៣.១.២ ការអប់រំមត្តេយ្យសិក្សា ........ ១១
១.៣.១.៣ ការអប់រំមធ្យមសិក្សាទុតិយភូមិ ........ ១១
១.៣.១.៤ ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ ១១
១.៣.១.៥ ផែនការនៃការអប់រំ និងបញ្ហាប្រឈម ........ ១៣
១.៣.២ ប្រព័ន្ធអប់រំរបស់សាលារៀននៅក្នុងប្រទេសវៀតណាម ........ ១៤
១.៣.២.១ ការអប់រំបឋមសិក្សា ........ ១៥
១.៣.២.២ ការអប់រំក្នុងកម្រិតមធ្យមសិក្សា ........ ១៦
១.៣.២.៣ ការអប់រំវិជ្ជាជីវៈ ........ ១៧
១.៣.២.៤ ការសិក្សាកម្រិតខ្ពស់ ........ ១៨
១.៣.២.៥ គោលបំណងនៃការអប់រំ ........ ១៩
១.៣.៣ ការអប់រំក្នុងប្រទេសមីយ៉ាន់ម៉ា ........ ២០
១.៣.៣.១ ប្រព័ន្ធអប់រំមូលដ្ឋាន ........ ២១
១.៣.៣.២ ការអប់រំបឋមសិក្សា ........ ២១
១.៣.៣.៣ ការអប់រំអនុវិទ្យាល័យ និងវិទ្យាល័យ ........ ២២
១.៣.៣.៤ ការអប់រំថ្នាក់បរិញ្ញាបត្រ ........ ២២

## ជំពូកទី២

## វិស័យអប់រំនៅកម្ពុជាមុនពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩

២.១ ការវិវត្តិនៃប្រព័ន្ធអប់រំ ........ .២៣
២.១.២ ការអប់រំតាមបែបប្រពៃណី ........ ២៣
២.១.២ ក្រោយពីកំណែទម្រង់ក្នុងឆ្នាំ១៩៩៦ ........ ២៣
២.១.៣ កំណែទម្រង់នៅក្នុងឆ្នាំ២០១៤ ........ ២៤
២.១.៤ កំណែទម្រង់ក្នុងឆ្នាំ២០១៨ ........ ២៤
២.២ ប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជា ........ ២៥
២.២.១ អប់រំកុមារតូច ........ ២៥
២.២.២ ការអប់រំបឋមសិក្សា. ........ ២៦
២.២.៣ ការអប់រំចំណេះទូទៅ ........ ២៦
២.២.៤ ការអប់រំឧត្តមសិក្សា ........ ២៧

២.២.៥ អប់រំក្រៅប្រព័ន្ធ......២៨
២.៣ ផលប៉ះពាល់នានាលើវិស័យអប់រំ......៣០
២.៣.១ កត្តាជីវភាព ឬ ភាពក្រីក្រ......៣០
២.៣.២ កត្តាសង្គ្រាម......៣១
២.៣.៣ កត្តាជម្ងឺឆ្លង...... ៣២
២.៤ គោលនយោបាយ និង ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពវិស័យអប់រំ ...... ៣៣
២.៤.១ យុទ្ធសាស្ត្រចតុកោណ...... ៣៤
២.៤.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីពីការអប់រំនៅកម្ពុជា......៣៥
២.៤.៣ ចក្ខុវិស័យបេសកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា......៣៨
២.៤.៤ គោលនយោបាយអប់រំរយៈពេលមធ្យម...... ៣៩
២.៤.៥ ការជម្រុញលើវិស័យបច្ចេកវិទ្យា E-learning, EDU 4.0...... ៤០

## ជំពូកទី៣
## វិស័យអប់រំនៅក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩

៣.១ អំពីស្ថានភាពទូទៅនៃជម្ងឺកូវីដ-១៩នៅក្នុងប្រទេសកម្ពុជា......៤២
៣.១.១ មុនពេលឆ្លងជាសហគមន៍...... ៤៣
៣.១.២ អំឡុងពេលឆ្លងជាសហគមន៍...... ៤៣
៣.២ ការបិទសាលា......៤៤
៣.២.១ ការបិទសាលាតាមតំបន់...... ៤៤
៣.២.២ ការបិទសាលាទូទាំងប្រទេស...... ៤៥
៣.៣ ការផ្លាស់ប្ដូរបរិបទនៃការសិក្សាពីចម្ងាយ (Online study) ក្នុងវិស័យរដ្ឋ...... ៤៦
៣.៣.១ កត្តាប្រឈម...... ៤៧
៣.៣.១.១ កត្តាប្រឈមផ្នែកសម្ភារៈ......៤៨
៣.៣.១.២ កត្តាខ្វះខាតនូវចំណេះដឹងផ្នែកបច្ចេកវិទ្យា និង ជំនាញ ......៤៨
៣.៣.១.៣ កត្តាប្រឈមក្នុងការសម្របខ្លួន......៤៩
៣.៣.១.៤ កត្តាប្រឈមផ្នែកប្រព័ន្ធអ៊ិនធឺណេត......៥០
៣.៣.២ ឱកាស...... ៥០
៣.៣.២.១ ការពន្លឿនក្នុងការចាប់យកនូវបច្ចេកវិទ្យា......៥១

៣.៣.២.២ ការកែទម្រង់លើវិស័យអប់រំ...................................................................................................៥១
៣.៣.២.៣ វិធីសាស្ត្រ និង ព័ត៌ទាក់ទងទៅនឹងមេរៀនកាន់តែមានភាពសម្បូរបែប ......................៥២
៣.៤ ការសិក្សាតាមរយៈអនឡាញក្នុងអំឡុងពេល Lockdown របស់វិស័យឯកជន ..........................៥៣
៣.៤.១ បញ្ហាប្រឈមនៅក្នុងការសិក្សាតាមរយៈអនឡាញ................................................... ៥៣
៣.៤.១.១ គុណភាពនៃការសិក្សាតាមរយៈប្រព័ន្ធអនឡាញ ................................................ ៥៣
៣.៤.១.២ ការសម្របខ្លួន....................................................................................................៥៤
៣.៤.១.៣ ការក្សៀយធន ...................................................................................................៥៤
៣.៤.២ ឱកាសផ្សេងៗសម្រាប់សិស្ស-និស្សិតក្នុងអំឡុងពេលសិក្សាតាមរយៈអនឡាញ.................៥៥
៣.៥ ការវិភាគទៅលើការស្ទង់មតិរបស់សិស្ស-និស្សិតពីផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ទៅលើវិស័យអប់រំ ... ៥៥
៣.៥.១ គោលបំណងនៃការធ្វើការស្ទង់មតិ...................................................................... ៥៦
៣.៥.២ លទ្ធផលនៃការស្ទង់មតិ..................................................................................... ៥៦
៣.៦ លទ្ធផលនៃការស្រាវជ្រាវ.......................................................................................................៦៥
៣.៦.១ ចំណុចខ្លាំង.................................................................................................... ៦៦
៣.៦.២ ចំណុចខ្សោយ................................................................................................. ៦៨

## សេចក្តីសន្និដ្ឋាន និង អនុសាសន៍

សេចក្តីសន្និដ្ឋាន...............................................................................................................៧១
អនុសាសន៍.......................................................................................................................៧២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- STEM ៖ Science, Technology, Engineering and Math
- ITC ៖ Information and Communications Technology
- ONIE ៖ Office of The Non-Formal and Informal Education
- NEA ៖ Thailand′s National Education Accounts
- MOLISA ៖ The Ministry of Labour - Invalids and Social Affairs
- MOET ៖ The Ministry of Education and Training
- CESR ៖ Myanmar Comprehensive Education Sector Review
- MOE ៖ The Ministry of Education
- E-Learning ៖ Electronic learning
- E-Library ៖ Electronic Library
- EDU-4.0 ៖ Education 4.0
- % ៖ ភាគរយ

# បញ្ជីតារាង

តារាងទី១ ៖ ប្រព័ន្ធអប់រំផ្លូវការរបស់ប្រទេសថៃ ...............................................................................១២

តារាងទី២៖ ឧបករណ៍រៀបចំផែនការអប់រំនៅប្រទេសថៃ.....................................................................១៤

តារាងទី៣៖ ចំនួនសាលារៀន គ្រូ និងនិស្សិតឆ្នាំ ២០១៥-២០១៦ .......................................................២១

តារាងទី៤៖ បង្ហាញពីចំនួនកុមារតូចនៅក្នុងប្រទេសកម្ពុជាដែលបានទទួលសេវាអប់រំ(ចូលរៀន) ................២៥

តារាងទី៥៖ បង្ហាញពីទិន្នន័យទាក់ទងនឹងការអប់រំក្រៅប្រព័ន្ធ............................................................២៨

# បញ្ជីក្រាហ្វិច

ក្រាហ្វិចទី១៖ អត្រាអក្ខរជនអាយុ១៥ឆ្នាំឡើងពីឆ្នាំ២០១១ ដល់ឆ្នាំ ២០១៩........................................ ២៩
ក្រាហ្វិចទី២៖ បង្ហាញពីចំនួនសិស្សចូលរៀនក្នុងកម្មវិធីចូលរៀនឡើងវិញតាមកម្រិតថ្នាក់........................ ៣០
ក្រាហ្វិចទី៣៖ អត្រាជួបការខ្វះខាត រាប់តាមចំនួនមនុស្ស លើវិស័យអប់រំ(%) បែងចែកតាមសូចនាករ កុមារអាយុ ៥-១៨ឆ្នាំ........................................................................................................ ៣១
ក្រាហ្វិចទី៤៖ បង្ហាញពីចំនួនសិស្ស និស្សិត ទាក់ទងនឹងកម្រិតបទពិសោធន៍របស់ពួកគេក្នុងការរៀនតាមអនឡាញ ........................................................................................................ ៥៦
ក្រាហ្វិចទី៥៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីការពេញចិត្តរបស់ពួកគេក្នុងការរៀនតាមប្រព័ន្ធអ៊ិនធឺណេត....៥៧
ក្រាហ្វិចទី៦៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីលទ្ធភាពរបស់ពួកគេ ក្នុងការប្រើឧបករណ៍រៀនតាមអ៊ិនធឺណេត ........................................................................................................ ៥៨
ក្រាហ្វិចទី៧៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីលទ្ធភាពរបស់ពួកគេក្នុងការប្រើអ៊ិនធឺណេត........................៥៨
ក្រាហ្វិចទី៨៖ បង្ហាញពីលទ្ធភាពពេលវេលាដែលសិស្ស និស្សិតមាន បើប្រៀបធៀបទៅ និងការសិក្សាផ្ទាល់ក្នុងថ្នាក់........................................................................................................ ៥៩
ក្រាហ្វិចទី៩៖ បង្ហាញពីបញ្ហាប្រឈមរបស់សិស្ស និស្សិត ក្នុងអំឡុងពេលសិក្សាតាមអនឡាញ..................៦០
ក្រាហ្វិចទី១០៖ បង្ហាញពីចំនួនម៉ោងដែលសិស្ស និស្សិតចំណាយពេលក្នុងការសិក្សាពីចម្ងាយ..................៦១
ក្រាហ្វិចទី១១៖ បង្ហាញពីប្រសិទ្ធភាពនៃការរៀនពីចម្ងាយក្នុងអំឡុងពេលកូវីដ-១៩................................ ៦២
ក្រាហ្វិចទី១២៖ បង្ហាញពីកម្រិតនៃផលវិបាកក្នុងការសិក្សាតាមអនឡាញរបស់សិស្ស និស្សិត.................. ៦២
ក្រាហ្វិចទី១៣៖ បង្ហាញពីកម្រិតនៃ ការគ្រប់គ្រងពេលវេលាក្នុងការសិក្សាតាមអនឡាញ របស់សិស្ស និស្សិត ........................................................................................................ ៦៣
ក្រាហ្វិចទី១៤៖ បង្ហាញពីចំនួនសិស្សនិស្សិត ពីចំណូលចិត្តសម្រាប់ការរៀនតាមអនឡាញ........................៦៤
ក្រាហ្វិចទី១៥៖ បង្ហាញពីចំនួនសិស្ស និស្សិត ពៅលទ្ធផលនៃការសិក្សារបស់ពួកគេក្នុងពេលរៀនតាមអនឡាញ កាលពីឆ្នាំ២០២០........................................................................................ ៦៥

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្ទង់មតិ

ឧបសម្ព័ន្ធទី២៖ ផលលំបាកផ្សេងៗ ទៀតនៃការរីករាលនៃជម្ងឺកូវីដ-១៩ មកលើការសិក្សាអប់រំរបស់អ្នកក្នុងអំឡុងពេលរៀនពីចម្ងាយ/E-learning

ឧបសម្ព័ន្ធទី៣៖ ផលវិជ្ជមានមួយចំនួននៃការរីករាលនៃជម្ងឺកូវីដ-១៩ ដែលធ្វើឱ្យការសិក្សាត្រូវពឹងផ្អែកតាម E-learning

ឧបសម្ព័ន្ធទី៤៖ ច្បាប់ស្តីពីការអប់រំ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ក្នុងប្រទេសនីមួយៗនៅលើពិភពលោក វិស័យអប់រំ គឺជាវិស័យចម្បងមួយក្នុងការជួយជម្រុញឱ្យមានការអភិវឌ្ឍន៍នូវវិស័យផ្សេងៗនៅក្នុងប្រទេស ហើយក៏ជាវិស័យស្នូលមួយដែលជួយជម្រុញដល់កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសទាំងមូលតាមរយៈការបង្កើតនូវធនធានមនុស្សផងដែរ។ ជាការពិតណាស់ ប្រទេសមួយមានការអភិវឌ្ឍន៍ប្រសើរឡើងទៅបានគឺអាស្រ័យទៅលើវិស័យជាច្រើនដែលមាននៅក្នុងប្រទេសដែលរួមមាន វិស័យទេសចរណ៍ វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម វិស័យអប់រំ និងវិស័យផ្សេងៗមួយចំនួនទៀត។ ក្នុងចំណោមវិស័យទាំងនេះ វិស័យអប់រំគឺជាវិស័យមួយដែលចូលរួមជួយដល់គ្រប់វិស័យដ៏ទៃទៀតឱ្យមានការរីកចម្រើនផងដែរ ព្រោះថានៅពេលដែលវិស័យអប់រំមានភាពរីកចម្រើន នោះមានន័យថានឹងបង្កើតឱ្យមាននូវធនធានមនុស្សជាច្រើនសម្រាប់ប្រទេស ឱ្យរាល់ការអភិវឌ្ឍន៍ទៅលើវិស័យដ៏ទៃទៀតគឺច្បាស់ណាស់នឹងមានភាពរីកចម្រើនទៅតាមនោះដែរ ដោយសារតែសម្បូរធនធានមនុស្សក្នុងការបញ្ចេញនូវគំនិតថ្មីៗដើម្បីជួយវិស័យទាំងនោះមានភាពរីកចម្រើនដែរ ពោលគឺធ្វើឱ្យការបង្កើនផលិតភាពផលិតផលមានគុណភាពខ្ពស់ ហើយចំណាយពេលតិចជាងមុន ចំណេញច្រើនជាងមុន ទទួលបានផលក៏ច្រើនជាងមុន ដែលនឹងជួយឱ្យប្រទេសរបស់ខ្លួនមានលទ្ធភាពក្នុងការប្រកួតប្រជែងទីផ្សារបរទេសផងដែរ។ ដោយយើងមើលឃើញថា គ្រប់បណ្ដាប្រទេសដែលមានការរីកចម្រើន និងប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់នៅលើពិភពលោក វិស័យអប់រំគឺជាវិស័យស្នូលក្នុងការបណ្ដុះបណ្ដាល និងផ្ដល់នូវធនធានមនុស្សទៅដល់វិស័យផ្សេងៗទៀតក្នុងដំណើរការ ការអភិវឌ្ឍន៍ ប៉ុន្តែវាទាមទារនូវភាពអត់ធ្មត់ក្នុងការបង្ហាត់បង្រៀន បណ្ដុះបណ្ដាល ក្នុងរយៈពេលយូរផងដែរ ។

ដូចនេះសរបញ្ជាក់ឱ្យយើងឃើញថា ក្នុងការអភិវឌ្ឍប្រទេសមួយឱ្យមានភាពរីកចម្រើនបាន ក្រៅតែយកចិត្តទុកដាក់លើវិស័យផ្សេងៗ នោះគឺត្រូវការដាច់ខាតផ្ដោតសំខាន់លើវិស័យអប់រំ ព្រោះវិស័យនេះគឺជាផ្នែកធំមួយក្នុងការជួយប្រទេសទាំងមូលមានការអភិវឌ្ឍលើគ្រប់វិស័យ ក៏ដូចជាជួយជម្រុញឱ្យមានកំណើនសេដ្ឋកិច្ចផងដែរ។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ យ៉ាងខ្លាំងទៅលើវិស័យអប់រំ ព្រោះថាការសិក្សាគឺជាស្នូលមួយក្នុងការអូសទាញមនុស្សឱ្យក្លាយទៅជាធនធានសំខាន់នៅក្នុងប្រទេសទាំងមូល ដែលវាជាគន្លឹះមួយដ៏សំខាន់នៅក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសប្រកបដោយសក្តានុពល និងនិរន្តរភាព។ ប៉ុន្តែនៅក្នុងចន្លោះឆ្នាំ ២០១៩ និងឆ្នាំ ២០២១ វិស័យអប់រំនៅស្ទើរតែទូទាំងប្រទេសនៅលើពិភពលោកគឺត្រូវបានរងផលប៉ះពាល់យ៉ាងដំណំ ពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ ជាពិសេសគឺចំពោះប្រទេសដែលកំពុងអភិវឌ្ឍន៍ដែលរួមមានប្រទេសកម្ពុជាផងដែរ។ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាទទួលរងនូវផលប៉ះពាល់យ៉ាងខ្លាំង នៅក្នុងចន្លោះឆ្នាំ២០២០ និងឆ្នាំ២០២១ ពោលគឺសាលារៀនទូទាំងប្រទេសត្រូវបានបិទ ហើយបរិបទនៃការសិក្សារបស់សិស្សនិស្សិតទាំងអស់ត្រូវបានផ្លាស់ប្ដូរមកធ្វើការសិក្សាតាមរយៈប្រព័ន្ធអនឡាញវិញ។ ហេតុដូចនេះហើយទើបក្រុមរបស់យើងខ្ញុំបានលើកយក

ប្រធានបទស្តីពី "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" ក្នុងគោលបំណងដើម្បីធ្វើការសិក្សាស្វែងយល់បន្ថែមពីផលប៉ះពាល់របស់វិស័យអប់រំ ជាពិសេសគឺចំពោះប្រទេសកម្ពុជាផ្ទាល់ព្រមទាំងស្វែងយល់ពីឱកាសផ្សេងៗ ក៏ដូចជាដំណោះស្រាយមួយចំនួនដែលរាជរដ្ឋាភិបាលបានប្រើក្នុងការដោះស្រាយនូវបញ្ហាប្រឈមទាំងនោះក្នុងអំឡុងពេលនោះផងដែរ។

## ១. លំនាំបញ្ហា

ប្រទេសកម្ពុជាជាប្រទេសចំណាស់មួយដែលធ្លាប់ឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃជាច្រើនលើកច្រើនសារ ដែលជាមូលហេតុ ធ្វើឱ្យបាត់បង់នូវធនធានមនុស្សអស់ជាច្រើននាក់ក្នុងការជួយដល់ការអភិវឌ្ឍរបស់ប្រទេសជាតិ។

នៅក្នុងប៉ុន្មានទសវត្សចុងក្រោយនេះ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាគឺមានការអភិវឌ្ឍន៍ជាលំដាប់ បើប្រៀបធៀបទៅនឹងសម័យកាលកន្លងមក។ ប្រសិទ្ធភាពនៃការអប់រំគឺមានភាពល្អប្រសើរពីមួយសម័យកាលទៅមួយសម័យកាល ដោយមានការយកចិត្តទុកដាក់ពីប្រមុខរាជរដ្ឋាភិបាល ជាពិសេសគឺការកែប្រែនូវប្រព័ន្ធអប់រំទៅតាមបែបទំនើបកម្មដែលគេហៅថា E-Learning ហើយក៏នឹងកំពុងវិវត្តខ្លួនចូលទៅក្នុងបដិវត្តន៍ឧស្សាហកម្ម ៤.០ ជា បណ្តើរៗផងដែរ។ ប៉ុន្មានឆ្នាំចុងក្រោយនេះ គេឃើញថាវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពរីចម្រើនខ្លាំងគួរឱ្យកត់សម្គាល់ រួមជាមួយការយកចិត្តទុកដាក់ទ្វេដងពីសំណាក់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើយ៉ាងណាឱ្យវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពល្អប្រសើរជាងនេះបន្ថែមទៀត ព្រោះថាវិស័យអប់រំក៏ជាផ្នែកសំខាន់មួយ ក្នុងការជួយជម្រុញដល់សេដ្ឋកិច្ចនៅក្នុងប្រទេសទាំងមូលឱ្យមានការកើនឡើងផងដែរ។ ប៉ុន្តែរាប់ចាប់ពីដើមឆ្នាំ២០២០ រហូតមកដល់ ដើមឆ្នាំ២០២១ វិស័យអប់រំបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការរីករាលដាលនៃជម្ងឺឆ្លងកូវីដ-១៩។ ជម្ងឺកូវីដ-១៩ មានប្រភពមកពីប្រទេសចិន ដែលផ្ទុះឡើងកាលពីអំឡុងចុងឆ្នាំ២០១៩ ហើយបានរីកសាយភាយចូលមកក្នុងប្រទេសនៅទូទាំងសកលលោក ក្នុងនោះរួមមានប្រទេសកម្ពុជាមួយផងដែរ។ ជម្ងឺមួយនេះបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាដោយស្ទើរតែគ្រប់វិស័យទាំងអស់នៅក្នុងប្រទេស បានទទួលផលប៉ះពាល់យ៉ាងខ្លាំងជាពិសេសគឺទៅលើវិស័យអប់រំតែម្តង។ សាលានៅក្នុងទីក្រុងភ្នំពេញ រួមទាំងបណ្តាខេត្តមួយចំនួនត្រូវបានផ្អាកក្នុងការទៅរៀនផ្ទាល់នៅក្នុងសាលារៀន ការប្រឡងថ្នាក់ជាតិមួយចំនួនត្រូវបានលើកពេលជាបន្តបន្ទាប់ រហូតឈានដល់ការសម្រេចឱ្យគ្មានការប្រឡងសញ្ញាបត្រទុតិយភូមិ ដោយសម្រេចឱ្យសិស្សជាប់ជាស្វ័យប្រវត្តដោយពុំចាំបាច់ប្រឡង(នៅក្នុងឆ្នាំ២០២០)។

ជម្ងឺកូវីដ-១៩ នេះបានឆ្លងចូលប្រទេសកម្ពុជានៅអំឡុងដើមឆ្នាំ២០២០ ដែលជាហេតុធ្វើឱ្យមានការបិទសាលាស្ទើរតែនៅទូទាំងប្រទេសទៅហើយ ដោយជំនួសមកវិញនូវការសិក្សាតាមប្រព័ន្ធអនឡាញ ដែលនេះហើយជាមូលហេតុចម្បងមួយធ្វើឱ្យគុណភាពនៃវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះ។

## ២. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" រួមមានដូចខាងក្រោម៖

- ស្វែងយល់ពីផលប៉ះពាល់ដែលកើតមាននៅក្នុងអំឡុងពេលការសិក្សាតាមប្រព័ន្ធអនឡាញ
- ដើម្បីស្វែងយល់ពីផលវិជ្ជមានមួយចំនួនដែលទទួលបានពីការសិក្សាតាមអនឡាញ
- ឪកាសផ្សេងៗដែលជួយក្នុងការវិវត្តដល់គុណភាពវិស័យអប់រំក្នុងប្រទេសនាពេលអនាគត
- ស្វែងយល់ពីដំណោះស្រាយផ្សេងៗដែលរាជរដ្ឋាភិបាលក៏ដូចជា ក្រសួងអប់រំ យុវជន និងកីឡាបានប្រើប្រាស់ក្នុងអំឡុងពេលបញ្ហាប្រឈមទាំងនេះ
- ទុកជាឯកសារ ដើម្បីផ្តល់ជាប្រយោជន៍ដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ឱ្យបានស្វែងយល់ពីបរិបទសិក្សានៅក្នុងការរីករាលដាលនៃជម្ងឺកូវីដ-១៩ ។

## ៣. ចំណោទបញ្ហា

ការផ្តល់នូវសេវាអប់រំនៅក្នុងអំឡុងពេល ដែលប្រទេសកំពុងតែជួបនូវបញ្ហាការរីករាលដាលជាសកល នៃជម្ងឺឆ្លងកូវីដ-១៩ មិនមែនជាការងាយស្រួលនោះទេ ហើយកាន់តែពិបាកទៀតនោះគឺការសិក្សាពីចម្ងាយ(តាមរយៈប្រព័ន្ធអនឡាញ) ដែលជាមូលហេតុធ្វើឱ្យកើតមាននូវបញ្ហាប្រឈមមួយចំនួន ទាំងសម្ភារៈ ទាំងចំណេះដឹងផ្នែកបច្ចេកវិទ្យា ទាំងការសម្របខ្លួននឹងបញ្ហាមួយចំនួនទៀត ជាពិសេសគឺនៅតាមទីជនបទ។ ហេតុដូចនេះទើបរបស់ក្រុមយើងខ្ញុំ សម្រេចយកប្រធានបទដែលទាក់ទងទៅនឹងបរិបទនៃការសិក្សានៅក្នុងអំឡុងពេលការរីករាលដាលជាសកលនៃជម្ងឺកូវីដ-១៩ ដើម្បីលើកបង្ហាញពីបញ្ហាប្រឈមដែលសិស្ស និស្សិត គ្រូបង្រៀនកំពុងជួបប្រទះក៏ដូចជាឪកាសផ្សេងៗទៀត រួមទាំងការចាប់យកនូវបច្ចេកវិទ្យាសម្រាប់ការវិវត្តនៃវិស័យអប់រំផងដែរ។ ដើម្បីពិនិត្យទៅលើបញ្ហាប្រឈមផ្សេងៗ ដែលបានរៀបរាប់នៅខាងលើ ពួកយើងបានធ្វើការចោទសួរមួយដូចខាងក្រោម៖

តើក្នុងការរីរាលដាលនៃជម្ងឺកូវីដ-១៩ បានផ្តល់ផលប៉ះពាល់អ្វីខ្លះមកលើវិស័យអប់រំ?

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

វិស័យអប់រំគឺដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតនូវធនធានមនុស្ស ក៏ដូចជាចូលរួមមួយផ្នែកធំក្នុងការជួយឱ្យប្រទេសមួយមានការរីកចម្រើន តែដោយសារតែនៅក្នុងស្ថានភាពមានការរីករាលដាលជម្ងឺឆ្លងកូវីដ-១៩ គឺបានធ្វើឱ្យគុណភាព ក៏ដូចជាប្រសិទ្ធភាពនៃវិស័យអប់រំនៅក្នុងប្រទេសមួយចំនួននៅទូទាំងពិភពលោកគឺជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ហើយក្នុងនោះប្រទេសកម្ពុជាក៏រាប់បញ្ចូលជាប្រទេសមួយដែលកំពុងតែទទួលរងនូវផលប៉ះយ៉ាងខ្លាំងពីស្ថានភាពនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩នេះផងដែរ ជាពិសេសគឺទៅលើវិស័យអប់រំ។

ក្នុងការលើកយកប្រធានបទ "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" មកធ្វើការសិក្សាស្រាវជ្រាវ ពួកយើងសង្ឃឹមយ៉ាងមុតមាំថាការសិក្សាស្រាវជ្រាវមួយនេះនឹងផ្តល់ប្រយោជន៍ដល់៖

- ចំពោះខ្លួនពួកយើងផ្ទាល់ គឺទទួលបានចំណេះដឹងបន្ថែមពីការស្រាវជ្រាវលើប្រធានបទមួយនេះ ជាពិសេសគឺបានធ្វើឱ្យប្រសើរឡើងបន្ថែមលើជំនាញស្រាវជ្រាវរបស់ពួកយើង សម្រាប់យកទៅប្រើនាពេលអនាគត។ បន្ថែមពីលើនេះទៀត គឺពួកយើងមានឱកាសសិក្សាបន្ថែមទៅលើបញ្ហាដែលវិស័យអប់រំកំពុងតែជួបប្រទះក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាផ្ទាល់ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ព្រមទាំងមានឱកាសស្វែងយល់បន្ថែមពីដំណោះស្រាយផ្សេងៗ ផងដែរ។
- ចំពោះអ្នកសិក្សាជំនាន់ក្រោយ គឺចែករំលែកចំណេះដឹងពីបញ្ហាដែលបានកើតមានទៅលើវិស័យអប់រំ ព្រមទាំងផលវិជ្ជមាន ក៏ដូចជាឱកាសផ្សេងៗដែលទទួលបានពី ការសិក្សាតាមប្រព័ន្ធអនឡាញ ក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺឆ្លងកូវីដ-១៩ ហើយក៏ផ្តល់ជាឯកសារមួយបន្សល់ទុកសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត ដែលមានបំណងចង់សិក្សាស្រាវជ្រាវ និងស្វែងយល់ពីបញ្ហា ដូចគ្នានេះអាចប្រើប្រាស់ឯកសារមួយនេះ ជាមូលដ្ឋានគ្រឹះសម្រាប់ជាជំនួយដល់ពួកគេនៅក្នុងការសិក្សាស្រាវជ្រាវ និងពង្រីកវិសាលភាពនៃការសិក្សាស្រាវជ្រាវ ពោលគឺចេះប្រើប្រាស់ធនធានដែលមានស្រាប់ និងបង្កើតគំនិតច្នៃប្រឌិតថ្មី ក្នុងការស្វែងរកនូវដំណោះស្រាយទៅលើបញ្ហាប្រឈមរបស់វិស័យអប់រំដែលមានប្រសិទ្ធភាពកាន់តែប្រសើរជាងនេះ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ទំហំនៃការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះគឺផ្តោតទៅលើ ផលប៉ះពាល់ដែលវិស័យអប់រំកំពុងជួបប្រទះនៅក្នុងអំឡុងពេលការបិទសាលារៀនដែលបណ្តាលមកពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ ហើយក្នុងនោះក៏រួមមានបន្ថែមនូវឱកាសផ្សេងៗ ដែលយើងទទួលបានក្នុងអំឡុងពេលនៃការរៀនតាមប្រព័ន្ធអនឡាញនេះផងដែរ។

ចំណែកដែនកំណត់នៃការស្រាវជ្រាវនេះវិញគឺ ផ្តោតសំខាន់ទៅលើកផលប៉ះពាល់របស់វិស័យអប់រំទាំងពីរវិស័យ ពោលគឺមានទាំងវិស័យរដ្ឋ និងវិស័យឯកជន នៅក្នុងអំឡុងពេលបិទសាលា ក៏ដូចជាបញ្ហាប្រឈមដែលសិស្ស និស្សិត និងគ្រូបង្រៀនបានជួបប្រទះនៅក្នុងអំឡុងពេលការសិក្សាតាមរយៈប្រព័ន្ធអនឡាញនេះ នៅក្នុងចន្លោះពេលនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ពីឆ្នាំ២០២០ ដល់២០២១ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ក្នុងការសរសេរអត្ថបទស្រាវជ្រាវលើប្រធានបទ "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" ក្រុមយើងខ្ញុំគឺប្រើនូវវិធីសាស្ត្រគុណវិស័យ។

**តម្រូវការទិន្នន័យ៖**

- ធ្វើការស្ទង់មតិតាមប្រព័ន្ធអនឡាញដោយប្រើកម្រងសំណួរសរុបចំនួន ១៨សំណួរ ដែលរួមមានសំណួរបិទចំនួន ១៦សំណួរ និងសំណួរបើកចំនួន ២សំណួរ ក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធ និងធ្វើការសិក្សាបានគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើការវិភាគក្នុងអត្ថបទនេះផងដែរ។
- ចំនួនទំហំសំណាកយក១០០ករណីមកពិនិត្យ ហើយបន្ថែមពីនេះក៏មានការប្រើប្រាស់ទិន្នន័យទីពីរ (Secondary data)ផងដែរ។
- បន្ទាប់ពីប្រមូលទិន្នន័យ/ព័ត៌មានបាន ការវិភាគគឺប្រើតាមក្រាបសម្រាប់វាយតម្លៃលើផលប៉ះពាល់នៃការរីករាលដាលជម្ងឺកូវីដ-១៩មកលើវិស័យអប់រំក្នុងប្រទេសកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវក្រោមប្រធានបទ "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" បានបែងចែកជា ៣ជំពូក រួមមាន៖ នៅក្នុង**ជំពូកទី១** ពួកយើងបង្ហាញនៅក្នុងជំពូកមួយនេះ គឺក្នុងគោលបំណងដើម្បីស្វែងយល់ពីពាក្យគន្លឹះសំខាន់ដែលមាននៅក្នុងប្រធានបទរបស់ពួកយើង។ ក្នុងចំណុចដំបូងគឺមានការលើកបង្ហាញនូវនិយមន័យពីពាក្យគន្លឹះសំខាន់នៅក្នុងប្រធានបទរបស់ ដែលក្នុងនោះ ពួកយើងបានជ្រើសរើសយកពីរពាក្យមកបង្ហាញគឺ៖ និយមន័យនៃពាក្យ "ការអប់រំ" និង "ផលប៉ះពាល់"។ ធ្វើការលើកបង្ហាញពីទស្សនៈ ផ្សេងៗទាក់ទងនឹងវិស័យអប់រំនៅមុនពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ បង្ហាញពីទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ នៅក្នុង៣ដំណាក់កាល ដែលរួមមាន វិស័យអប់រំតាមបែបប្រពៃណី ក្នុងដំណាក់កាលE-learning និង ក្នុងដំណាក់កាលបដិវត្តន៍ឧស្សាហកម្ម៤.០។ លើកបង្ហាញពីការអប់រំនៅតាមបណ្តាប្រទេសនៅក្នុងអាស៊ានមួយចំនួនដូចជា ប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសមីយ៉ាន់ម៉ា ដើម្បីស្វែងយល់ពីប្រព័ន្ធអប់រំ ផលប៉ះពាល់ ក៏ដូចជាគោលនយោបាយដែលនៅតាមបណ្តាប្រទេសទាំងនោះបានប្រើប្រាស់នៅក្នុង វិស័យអប់រំរបស់ពួកគេ។ នៅក្នុង**ជំពូកទី២** គឺធ្វើការលើកបង្ហាញដោយផ្តោតទៅលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជានៅមុនពេលការរីរាលដាលនៃជម្ងឺកូវីដ-១៩ ។ ក្នុងនោះពួកយើងធ្វើការលើកបង្ហាញពីស្ថានភាពទូទៅនៃវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ការវិត្តនៃវិស័យអប់រំដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីភាពរីកចម្រើនក្នុងវិស័យអប់រំនៃប្រទេសកម្ពុជា ពីមួយដំណាក់កាលទៅមួយដំណាក់កាល។ លើសពីនេះទៅទៀតគឺបង្ហាញពីបញ្ហាប្រឈម ក៏ដូចជាផលប៉ះពាល់នៃវិស័យអប់រំទាំងផ្នែករដ្ឋ និងឯកជន រួមជាមួយនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលចំពោះវិស័យអប់រំផងដែរ។ ចំណែកឯនៅក្នុង**ជំពូកទី៣**ពួកយើងធ្វើការលើកបង្ហាញផ្នែកសំខាន់បំផុតនៃប្រធានបទមួយនេះគឺ វិស័យអប់រំនៅក្នុងអំឡុងពេលការរីករាលដាលនៃ ជម្ងឺកូវីដ-១៩ ដោយលើកយកចំណុចសំខាន់មួយចំនួនមកបកស្រាយនៅក្នុងជំពូកមួយនេះ ដែលរួមមាន បរិបទនៃការសិក្សា ផលប៉ះពាល់ ក៏ដូចជាឱកាសមួយចំនួនសិស្សនិស្សិតទទួលបានក្នុងអំឡុង

ពេលនៃការសិក្សាតាមរយៈប្រព័ន្ធអនឡាញ។ លើសពីនេះក៏មានការលើកបង្ហាញពីចំណុចវិជ្ជមានមួយចំនួនតូច ដែលវិស័យអប់រំទទួលនៅក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩នេះផងដែរ។

# ជំពូកទី១
# រំលឹកទ្រឹស្ដីពាក់ព័ន្ធ
# នឹងការអប់រំ

# ជំពូកទី១

# រំលឹកទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ

## ១.១ និយមន័យ

### ១.១.១ ការអប់រំ

ការអប់រំ គឺជាការបណ្តុះបណ្តាល ឬជាការណែនាំបុគ្គលម្នាក់ៗទាំងក្នុងសាលា និងក្រៅសាលាដើម្បីឱ្យបុគ្គលនោះមានការប្រែប្រួលទាំងចំណេះដឹង បំណិន សីលធម៌ការរស់នៅ សុចរិតភាព និងរូបរាងកាយ ដើម្បីឆ្ពោះទៅរកការរីកចម្រើន ហើយក្លាយទៅជាមនុស្សម្នាក់ថ្លៃថ្នូរនៅក្នុងសង្គម។ ឬការអប់រំ គឺជារបៀបមួយសម្រាប់ផ្តល់តម្រិះវិជ្ជា និងប្រពៃណីសម្រាប់បុគ្គលម្នាក់ៗនៅក្នុងសង្គមមួយ ឬ ជាវិធីចាត់ចែងបណ្តុះបណ្តាលនិងបង្រៀន។

បន្ថែមពីនេះទៀតនិយមន័យការអប់រំ គឺសំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និង ពិភពលោក។[1]

### ១.១.២ ផលប៉ះពាល់

ផលប៉ះពាល់គឺសំដៅទៅដល់ ស្ថានភាព ឬសកម្មភាពនៃអ្វីមួយ មានទំនាក់ទំនង ឬមានឥទ្ធិពលទៅលើស្ថានភាពឬសកម្មភាពអ្វីមួយផ្សេងទៀតដែលជាទូទៅគឺជាឥទ្ធិពលអវិជ្ជមាន ពោលគឺភាគីម្ខាងដែលទទួលរងឥទ្ធិពលគឺជាអ្នកដែលខាតបង់។

ឧទាហរណ៍៖ ជម្ងឺកូវីដ-១៩បានផ្តល់ជាផលប៉ះពាល់ជាច្រើនទៅលើសេដ្ឋកិច្ចនៅតាមបណ្តាប្រទេសមួយចំនួនជាពិសេសគឺប្រទេសកំពុងអភិវឌ្ឍន៍។ ក្នុងឧទាហរណ៍មួយនេះ ពាក្យថាផលប៉ះពាល់ គឺមានន័យសំដៅទៅដល់ឥទ្ធិពលអវិជ្ជមានដែលបណ្តាប្រទេសទទួលបានពីជម្ងឺកូវីដ-១៩ ជាក់ស្តែងដូចជាវិស័យជាច្រើននៅក្នុងប្រទេសដែលរួមមានវិស័យទេសចរណ៍ វិស័យពាណិជ្ជកម្ម វិស័យអប់រំ និងវិស័យផ្សេងៗទៀតគឺកំពុងតែជួបនូវបញ្ហាអាក់រអួរ ដែលធ្វើឱ្យសេដ្ឋកិច្ចក្នុងប្រទេសទាំងមូលមានការធ្លាក់ចុះផងដែរ។

សរុបមកវិញផលប៉ះពាល់ទៅលើវិស័យអប់រំ គឺផ្តល់នូវផលខាតបង់ខ្លាំងបំផុតទៅលើការបង្អាក់នៃការរីកចម្រើនសេដ្ឋកិច្ចក្នុងប្រទេសនីមួយៗនៅលើពិភពលោក ជាពិសេសទៅលើប្រទេសដែលកំពុងអភិវឌ្ឍន៍

[1]ច្បាប់ស្តីពីការអប់រំ ២០០៧, លេខ នស/រកម/១២០៧/០៣២, ២១ វិច្ឆិកា ២០០៧, មាត្រា៤។

ដោយសារតែវិស័យអប់រំ គឺបានបណ្តុះនូវធនធានមនុស្ស ទាំងចំណេះដឹង និងជំនាញ ដែលវាជាផ្នត់មួយដ៏សំខាន់ដើម្បីឈានទៅដល់ប្រទេសដែលមានការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច។

## ១.២ ទ្រឹស្តីពាក់ព័ន្ធនឹងការអប់រំ

តាំងពីយូរលង់មកហើយ ការអប់រំត្រូវបានចាត់ទុកថា ជាការវិនិយោគដ៏សំខាន់បំផុតដើម្បីសម្រេចបានពិភពលោកមួយកាន់តែប្រសើរ។ ការអប់រំគឺជាការកសាងសមត្ថភាពខាងរាងកាយ ចំណេះដឹង ប្រាជ្ញាស្មារតី បំណិន និងអត្តចរិករបស់មនុស្ស។ ការអប់រំមិនមែនសំដៅតែការសិក្សារៀនសូត្រនៅក្នុងសាលារៀនប៉ុណ្ណោះទេ តែក៏ជាការសិក្សាពេញមួយជីវិតនៅក្នុងស្ថាប័នសង្គមដែរ។ ការអប់រំមានគោលបំណងធ្វើឱ្យមនុស្ស និង សង្គមមនុស្សកាន់តែល្អទៅៗគ្មានទីបញ្ចប់។[2]

### ១.២.១ ទ្រឹស្តីនៃការអប់រំតាមបែបប្រពៃណី

ប្រពៃណីការអប់រំនៅប្រទេសកម្ពុជាត្រូវបានចេញពីវត្តអារាម ហើយព្រះសង្ឃគឺជាគ្រូបង្រៀន។ សិស្សភាគច្រើនគឺសុទ្ធតែក្មេងប្រុស ហើយការអប់រំគឺត្រូវបានកំណត់ឱ្យទន្ទេញដដែលៗដូចព្រះសង្ឃទន្ទេញបាលី។សម័យកាលបន្តៗមកទៀត ការអប់រំមានការរីកចម្រើនពីមួយសម័យកាលទៅមួយសម័យកាល ដោយមានជាសាលារៀន សម្រាប់សិស្ស មានការបង្រៀនផ្ទាល់រវាងគ្រូនឹងសិស្សនៅក្នុងថ្នាក់រៀន ហើយឯកសារផ្សេងៗសម្រាប់សិស្សស្រាវជ្រាវគឺមាននៅក្នុងបណ្ណាល័យនៃសាលារៀន តែមិនទាន់មានជាការប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិកណាមួយបញ្ចូលក្នុងវិស័យអប់រំឡើយ។

យោងទៅតាមមាត្រា២ នៅក្នុងច្បាប់ស្តីពីការអប់រំ បានចារថា ការអប់រំគឺមានគោលបំណងអភិវឌ្ឍន៍ធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់អ្នកទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាន នូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជម្រុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារ អត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ។[3]

### ១.២.២ ទ្រឹស្តីនៃការអប់រំតាមរយៈ E-learning

នាពេលបច្ចុប្បន្ននេះ ដោយសារតែបណ្តាញបច្ចេកវិទ្យាមានការរីកចម្រើន ការសិក្សារបស់សិស្ស និស្សិតមានការផ្លាស់ប្តូរឆ្ពោះទៅរកភាពល្អប្រសើរឡើង និងកាន់តែទំនើប។ នៅក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ បើមើលទៅតាមបណ្តាសាកលវិទ្យាល័យល្បីៗលើពិភពលោក គឺគេបានប្រើប្រាស់នូវបណ្តាញសិក្សាថ្មីដែលមានប្រយោជន៍ និងប្រសិទ្ធភាពគឺ E-learning។

[2]បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន, *ទស្សនវិជ្ជានិងទ្រឹស្តីស្តីពីការអប់រំ* (២០២១), (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២១)។

[3] ច្បាប់ស្តីពីការអប់រំ ២០០៧, លេខ នស/រកម/១២០៧/០៣២, ២១ វិច្ឆិកា ២០០៧, មាត្រា២។

E-Learning គឺជាវិធីសាស្ត្រការសិក្សារៀនសូត្របែបទំនើបមួយដែលមានលក្ខណៈងាយស្រួលក្នុងការទទួលបានកម្មវិធីសិក្សា និងឯកសារសិក្សាផ្សេងៗតាមប្រព័ន្ធអ៊ិនធើណេតដែលខុសប្លែកពីបែបបទនៃការរៀនសូត្របែបលក្ខណៈប្រពៃណីក្នុងថ្នាក់រៀនផ្ទាល់ ពោលគឺសំដៅទៅលើការសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតដែលមានសកម្មភាពរវាងសិស្ស និងគ្រូក្នុងការចូលរួមឆ្លើយឆ្លង សួរសំណួរ ការដាក់ពិន្ទុកិច្ចការផ្ទះ និងកិច្ចសាលា ការប្រលងធ្វើតេស្ត ដូចនឹងការសិក្សាខាងក្រៅដោយផ្ទាល់ផងដែរ។

ការសិក្សាតាមបែប E-learning អាចជម្រុញឱ្យសិស្សនិស្សិតកម្ពុជា មានសមត្ថភាពក្នុងការប្រកួតប្រជែងជាមួយនឹងបណ្ដាប្រទេសដទៃលើកម្រិតនៃការយល់ដឹង និងការអនុវត្តការងារជាក់ស្ដែង តាមរយៈបណ្ដាញបច្ចេកវិទ្យា ហើយអ្វីដែលល្អបំផុតនោះគឺ សម្រាប់ E-learning សិស្សនិស្សិតអាចរៀនសាឡើងវិញបានគ្រប់ពេលវេលាបើទោះបីជាមិនស្ថិតក្នុងថ្នាក់រៀនក៏ដោយ។ ការសិក្សាបែបនេះគឺមានលក្ខណៈសាមញ្ញនឹងងាយស្រួលដោយសិស្សនៅទីណាក៏អាចរៀនសូត្របានដែរ ប៉ុន្តែអ្វីដែលអ្នកចាំបាច់មានគឺអ៊ិនធឺណេត និងឧបករណ៍បច្ចេកវិទ្យាមានដូចជាកុំព្យូទ័រ ឬស្មាតហ្វូនក្នុងការសិក្សានេះ។ បច្ចុប្បន្ននេះគឺមានកម្មវិធីសិក្សា E-learning មួយចំនួនមានដូចជា Google Classroom និង Microsoft Team និងកម្មវិធី Zoom Meetings ជាដើម។ កម្មវិធីទាំងនេះគឺមានលក្ខណៈពិសេសក្នុងការផ្ដល់ជាលក្ខណៈអាចឱ្យសិស្សនឹងគ្រូចែករំលែកឯកសារសិក្សា ការបង្រៀនបែបលក្ខណៈជាវីដេអូ និងការជជែកគ្នាជាការប្រជុំជាមួយនឹងគ្នាបាន។

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន គ្រឹះស្ថានអប់រំធំៗមួយចំនួនបានដាក់ឱ្យដំណើរការកម្មវិធី E-learning ដោយក្នុងនោះមានដូចជា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យជាតិគ្រប់គ្រង សាកលវិទ្យាល័យជាតិកសិកម្ម និងសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលជាដើម។

### ១.២.៣ ទ្រឹស្ដីនៃការអប់រំតាមបដិវត្តន៍ឧស្សាហកម្ម ៤.០

បដិវត្តន៍ឧស្សាហកម្ម៤.០ គឺជាបញ្ញត្តថ្មីមួយសម្គាល់លើការរីកចម្រើននៃបច្ចេកវិទ្យាតាមរយៈការតភ្ជាប់បណ្ដាញអ៊ិនធឺណេតល្បឿនលឿន ប្រព័ន្ធ5G ប្រព័ន្ធគមនាគមន៍ ព័ត៌មានវិទ្យា និងបញ្ញាសប្បនិម្មិតជាដើម។ ហើយការអប់រំនៅក្នុងបដិវត្តន៍ឧស្សាហកម្ម៤.០ គឺសំដៅលើការអប់រំដែលផ្ដោតសំខាន់ទៅលើមុខវិជ្ជាStem, ICT និងមានបន្ថែមម៉ោងសិក្សាដើម្បីបំពាក់បំប៉នសិស្សឱ្យមានសមត្ថភាពទៅលើបច្ចេកវិទ្យា ពោលគឺការសិក្សាអប់រំគឺផ្ដោតសំខាន់លើការអភិវឌ្ឍន៍សមត្ថភាពយុវជនទៅលើបំណិនទាំង៨ (បំណិនត្រិះរិះ និងដោះស្រាយបញ្ហានវានុវត្តន៍ ការសហការគ្នាជាក្រុម អករកម្មកុំព្យូទ័រ និងបច្ចេកវិទ្យាព័ត៌មានជាដើម) នាសម័យឌីជីថលដែលពឹងផ្អែកលើបច្ចេកវិទ្យាជាជាងកម្លាំងមនុស្ស។

ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ក៏កំពុងតែព្យាយាមអភិវឌ្ឍន៍វិស័យអប់រំរបស់ខ្លួនបណ្តើរៗដើម្បីសម្រប ខ្លួនឱ្យទាន់នឹងបដិវត្តន៍ឧស្សាហកម្ម៤.០ ដោយមានការបង្កើតនូវសាលារៀនជំនាន់ថ្មីដែលជាកំណែទម្រង់ថ្មីមួយ នៅក្នុងប្រព័ន្ធអប់រំ ធ្វើឱ្យសាលារៀនទាំងមូលក្លាយទៅជាសាលារៀនស្វយ័តភាពផ្សារភ្ជាប់ទៅនឹងស្តង់ដារថ្មីមាន គណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដារវិជ្ជាជីវៈ សម្រាប់ការសិក្សានាសតវត្សទី២១ នេះបើយោង តាមគោលនយោបាយស្តីពីសាលារៀនជំនាន់ថ្មីរបស់ក្រសួងអប់រំយុវជន និងកីឡា។

## ១.៣ ករណីសិក្សាប្រព័ន្ធអប់រំនៅក្នុងបណ្តាប្រទេសអាស៊ានមួយចំនួន

### ១.៣.១ ប្រព័ន្ធអប់រំនៅក្នុងប្រទេសថៃ

ការអប់រំ និងការអភិវឌ្ឍអក្ខរកម្មគឺជាប្រពៃណីតាំងពីយូរណាស់មកហើយនៅក្នុង ប្រទេសថៃ។ ប្រព័ន្ធអប់រំ នាពេលបច្ចុប្បន្ននេះមានគោលបំណងដើម្បីកសាង និងគាំទ្រទាំងជំនាញអនុវត្តជាក់ស្តែង និងជំនាញទ្រឹស្តី សមត្ថភាពសង្គម តម្លៃសីលធម៌ និងប្រជាធិបតេយ្យ និងអត្តសញ្ញាណជាតិ។ ជាច្រើនឆ្នាំកន្លងមកប្រទេសថៃ បានពង្រីកចំនួនឆ្នាំសិក្សាសម្រាប់យុវជនថៃដោយឥតគិតថ្លៃបន្ថែមទៀត ហើយព្រមទាំងបានផ្តល់ជូននូវសាលា រៀនជាច្រើនដើម្បីបំពេញតម្រូវការផ្សេងៗគ្នារបស់សិស្សនិស្សិត។ ទោះជាយ៉ាងណាក៏ដោយ និស្សិតនៅតំបន់ ដាច់ស្រយាល ឬមកពីមជ្ឈដ្ឋានដែលជួបការលំបាកមិនមានលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាព ដូចគ្នា នឹងសិស្សនៅតំបន់ផ្សេងទៀតនៃប្រទេសឡើយ។ វិស័យអប់រំនៅប្រទេសថៃបែងចែកជាពីរ គឺ វិស័យរដ្ឋ និងវិស័យឯកជន។

#### ១.៣.១.១ រចនាសម្ព័ន្ធនៃការសិក្សា

ប្រទេសថៃផ្តល់ការអប់រំចំនួនបីប្រភេទគឺការអប់រំផ្លូវការ មិនផ្លូវការ និងក្រៅផ្លូវការ។ ខណៈពេលដែលការ អប់រំមិនផ្លូវការ និង ក្រៅផ្លូវការមិនបានផ្តោតសំខាន់ក្នុងករណីពិនិត្យឡើងវិញឡើយ ពួកវាគឺជាផ្នែកសំខាន់មួយ នៃប្រព័ន្ធអប់រំរបស់ថៃ។ គោលបំណងទាំងពីរនេះផ្តល់នូវជំនាញជាមូលដ្ឋាន និងធានាដល់ការសិក្សាពេញមួយ ជីវិត និងត្រូវបានធ្វើឡើងជាពិសេសសម្រាប់កុមារ និងមនុស្សធំដែលជួបការលំបាក នៅតំបន់ដាច់ស្រយាល ឬ សហគមន៍ជនជាតិភាគតិច ហើយនៅថ្នាក់ជាតិពួកគេត្រូវបានត្រួតពិនិត្យដោយការិយាល័យអប់រំមិនផ្លូវការ និង ក្រៅផ្លូវការ(ONIE) នៅក្នុងក្រសួងអប់រំ ប៉ុន្តែស្ថាប័នសាធារណៈ និងអ្នកពាក់ព័ន្ធឯកជនផ្សេងទៀតក៏ផ្តល់ការអប់រំ នៅខាងក្រៅកម្មវិធីផ្លូវការដែរ។ ក្នុងឆ្នាំ ២០១៣ មាននិស្សិតជាង ២,៦ លាននាក់បានចុះឈ្មោះរៀនក្រៅផ្លូវការ។

ចាប់តាំងពីឆ្នាំ ១៩៩៩ ការអប់រំផ្លូវការត្រូវបានបែងចែកជាថ្នាក់មូលដ្ឋាន និងឧត្តមសិក្សា។ ការអប់រំថ្នាក់ មូលដ្ឋានត្រូវបានផ្តល់ជូនមិនគិតថ្លៃ និងរួមបញ្ចូលទាំងកម្រិតមតេយ្យ បឋមសិក្សា និងអនុវិទ្យាល័យ (តារាង១) ។ ការអប់រំជាកាតព្វកិច្ចចាប់ផ្តើមពីអាយុ ៦ ឆ្នាំនិងមានរយៈពេល ៩ ឆ្នាំដែលរួមមានការចូលរៀនបឋមសិក្សា (ថ្នាក់ទី ១ ដល់ទី ៦) និងមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ M1-3) ។

### ១.៣.១.២ ការអប់រំមត្តេយ្យសិក្សា

ការអប់រំមត្តេយ្យសិក្សាក្លាយជាផ្នែកមួយនៃការអប់រំជាមូលដ្ឋាននៅឆ្នាំ ២០០៤ វាមិនមែនជាកំហិតទេតែត្រូវបានធ្វើឡើងដោយឥតគិតថ្លៃតាំងពីឆ្នាំ ២០០៩ ក្នុងគោលបំណងដើម្បីជួយសម្រួលដល់ការចូលដំណើរការ។ សាលារដ្ឋជាធម្មតាផ្តល់ជូននូវពីរឆ្នាំនៃសាលាមត្តេយ្យ (ក្មេងអាយុបី ឬ បួនឆ្នាំ) និងមួយឆ្នាំក្នុងការរៀនត្រៀមមុនចូលសិក្សា(ក្មេងអាយុប្រាំឆ្នាំ) ។ កុមារដែលមានអាយុតិចអាចចូលរួមមជ្ឈមណ្ឌលថែទាំកុមារ។ ការចូលរួមបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ យោងតាមស្ថិតិអន្តរជាតិការចុះឈ្មោះចូលរៀនសុទ្ធក្នុងការអប់រំបឋមសិក្សាគឺស្ទើរតែជាសកលក្នុងឆ្នាំ ២០១១។

### ១.៣.១.៣ ការអប់រំមធ្យមសិក្សាទុតិយភូមិ

ការអប់រំមធ្យមសិក្សាទុតិយភូមិចែកជាថ្នាក់មូលដ្ឋាន និងវិជ្ជាជីវៈ។ បើយោងតាមស្ថិតិរបស់រាជរដ្ឋាភិបាលប្រហែល ៧៥%នៃយុវជនមានសិទ្ធិ ត្រូវបានចុះឈ្មោះក្នុងឆ្នាំ២០១៣។ សិស្សគឺទទួលបានសិទ្ធិសេរីភាពពេញលេញក្នុងការជ្រើសរើសមុខវិជ្ជារបស់ពួកគេ ព្រោះថាការអប់រំមធ្យមសិក្សាទុតិយភូមិមានគោលបំណងរៀបចំ ពួកវាសម្រាប់ការសិក្សាបន្ត និងជីវិតការងារ។

### ១.៣.១.៤ ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្លូវការត្រូវបានផ្តល់ជូននៅឯកម្រិតអនុវិទ្យាល័យនៅក្នុងសាលារៀនជាក់លាក់មួយ ឬស្ថាប័ននានានៅក្នុងម៉ូដែលពីរដោយផ្អែកលើកិច្ចព្រមព្រៀងរវាងសាលារៀន និងក្រុមហ៊ុន។ បន្ទាប់ពីសិក្សាវគ្គសិក្សាយៈពេល ២ឆ្នាំនិស្សិតទទួលបានសញ្ញាបត្រ ហើយបន្ទាប់មកពួកគេអាចបន្តទទួលបានសិទ្ធិបន្តទៅសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា។ ចំណែកឯការអប់រំបណ្តុះបណ្តាល និងវិជ្ជាជីវៈមធ្យមសិក្សាទុតិយភូមិបានធ្លាក់ចុះប្រហែលមួយភាគបី(៣២,៧%)នៃសិស្សមធ្យមសិក្សាទុតិយភូមិទាំងអស់ក្នុងឆ្នាំ២០១៣។

ប្រព័ន្ធសាលារៀនផ្លូវការរបស់ប្រទេសថៃមានចំនួនច្រើន បើទាក់ទងនឹងការចុះឈ្មោះចូលរៀន ប៉ុន្តែចំនួនសិស្សបានថយចុះក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ។ ម្យ៉ាងវិញទៀតការអប់រំមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សាបានកត់សំគាល់ ការកើនឡើងបន្តិចនៃការចុះឈ្មោះបើទោះបីជាអត្រានៃការចូលរួមមានកម្រិតទាបក៏ដោយ។ ក្រសួងអប់រំបានរាយការណ៍ថាក្នុងឆ្នាំ ២០១៣ មានកុមារប្រមាណ ១១,២លាននាក់ បានចុះឈ្មោះចូលរៀនថ្នាក់មូលដ្ឋានពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិៈ ១,៨ លាននាក់ នៅក្នុងការអប់មត្តេយ្យសិក្សា ៤,៩លាននាក់ នៅបឋមសិក្សា ៤,៩ លាននាក់ និងមធ្យមសិក្សា ៤.៥ លាននាក់។[4] ក្នុងឆ្នាំ ២០១៣ និស្សិតចំនួន ២,៤១

---

[4] Office of the Permanent Secretary (2014), *Educational Statistics in Brief 2013*, Office of the Permanent Secretary, Ministry of Education of Thailand, Bangkok, [www.mis.moe.go.th/mis-th/images/statistic/Statistic/statistics2556.pdf] (ចូលទស្សនាថ្ងៃ២ ឧសភា ២០២១)។

លាននាក់បានចូលរួមក្នុងទម្រង់ខ្ពស់ជាងនេះ (ថ្នាក់បរិញ្ញាបត្រ) ការអប់រំ ៩០%នៃពួកគេគឺស្ថិតនៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ។

## តារាងទី១ ៖ ប្រព័ន្ធអប់រំផ្លូវការរបស់ថៃ

<table>
<tr><th rowspan="2">អាយុធម្មតា</th><th rowspan="2">ថ្នាក់</th><th colspan="7">កម្រិតនិងទម្រង់នៃការអប់រំ</th></tr>
<tr><th colspan="3">ការអប់រំទូទៅ</th><th>ការអប់រំវិជ្ជាជីវៈ</th><th colspan="3" rowspan="2">ទម្រង់អប់រំផ្សេងទៀត</th></tr>
<tr><td>1</td><td></td><td colspan="2" rowspan="5">ថ្នាក់មត្តេយ្យ</td><td rowspan="2"></td><td rowspan="14"></td></tr>
<tr><td>2</td><td></td><td rowspan="13"></td><td rowspan="22">ការអប់រំក្រៅផ្លូវការ</td><td rowspan="22">ការអប់រំពិសេស</td></tr>
<tr><td>3</td><td></td><td rowspan="15">ការអប់រំជាមូលដ្ឋានដោយឥតគិតថ្លៃ</td></tr>
<tr><td>4</td><td></td></tr>
<tr><td>5</td><td></td></tr>
<tr><td>6</td><td>P1</td><td rowspan="6">ថ្នាក់បឋម</td><td rowspan="9">វិស័យអប់រំជាកាតព្វកិច្ច</td></tr>
<tr><td>7</td><td>P2</td></tr>
<tr><td>8</td><td>P3</td></tr>
<tr><td>9</td><td>P4</td></tr>
<tr><td>10</td><td>P5</td></tr>
<tr><td>11</td><td>P6</td></tr>
<tr><td>12</td><td>M1</td><td rowspan="3">ថ្នាក់អនុវិទ្យាល័យ</td></tr>
<tr><td>13</td><td>M2</td></tr>
<tr><td>14</td><td>M3</td></tr>
<tr><td>15</td><td>M4</td><td colspan="2" rowspan="3">ថ្នាក់វិទ្យាល័យ</td><td rowspan="3">វិជ្ជាជីវៈបន្ទាប់បន្សំ</td><td rowspan="9">ការបណ្ដុះបណ្ដាលវគ្គខ្លី</td></tr>
<tr><td>16</td><td>M5</td></tr>
<tr><td>17</td><td>M6</td></tr>
<tr><td>18</td><td></td><td colspan="3" rowspan="4">ថ្នាក់ឧត្តមសិក្សា</td><td rowspan="2">វិជ្ជាជីវៈកម្រិតខ្ពស់</td></tr>
<tr><td>19</td><td></td></tr>
<tr><td>20</td><td></td><td rowspan="4"></td></tr>
<tr><td>21</td><td></td></tr>
<tr><td>22</td><td></td><td colspan="3" rowspan="2">បញ្ចប់ការសិក្សាឧត្តម</td></tr>
<tr><td>23</td><td></td></tr>
</table>

ចំណាំ : P = prathom (primary level); M = mattayom (secondary level)

ប្រភព : Adapted from Ministry of Education (2008), Towards a Learning Society in Thailand: An Introduction to Education in Thailand; OECD (2013b), Southeast Asian Economic Outlook 2013: With Perspectives on China and India, http://dx.doi.org/10.1787/saeo-2013-en.

### ១.៣.១.៥ ផែនការនៃការអប់រំ និងបញ្ហាប្រឈម

ដូចដែលបានកំណត់ដោយ NEA ប្រទេសថៃបានអភិវឌ្ឍជាតិរយៈពេល ១៥ ឆ្នាំ ចំពោះផែនការអប់រំ (២០០២-២០១៦) ដើម្បីលើកកម្ពស់ការអភិវឌ្ឍដែលផ្តោតលើធនធានមនុស្ស សេដ្ឋកិច្ចផ្អែកលើចំណេះដឹង ការរៀនសូត្រ និងការចូលរួមរបស់ភាគីពាក់ព័ន្ធកាន់តែច្រើន។ ទោះបីជាប្រទេសមានវឌ្ឍនភាពរីកចម្រើនជាលំដាប់ក្នុងរយៈពេលនេះ តែវាបានប្រឈមមុខជាប្រចាំជាមួយការលំបាកក្នុងការកំណែទម្រង់ទៅជាសកម្មភាពនៅថ្នាក់ឬសាលា។ ការស្រាវជ្រាវបញ្ជាក់ពីបញ្ហាប្រឈមមួយចំនួនដែលរារាំងការអនុវត្តកំណែទម្រង់រួមទាំងអស្ថិរភាពនយោបាយរបស់ប្រទេសនេះ ខ្វះការគាំទ្រផ្នែកហិរញ្ញវត្ថុ និងជាទូទៅមានភាពស្មុគស្មាញនៃកំណែទម្រង់ច្បាប់។ អាទិភាពនៃការអប់រំនាពេលបច្ចុប្បន្នត្រូវបានកំណត់តាមរយៈរយៈពេលច្រើនឆ្នាំ ឯកសារផែនការអប់រំដែលត្រូវបានបកស្រាយដោយក្រុមប្រឹក្សាជាតិ (ដូចជាឯកសារផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមជាតិ ឬដោយក្រសួងបរិស្ថាន)។ ផែនការជាតិអប់រំ និងសកម្មភាពអប់រំរយៈពេល ៤ ឆ្នាំរបស់ក្រសួងអប់រំ រៀបចំផែនការទាំងពីរនៅចុងឆ្នាំ ២០១៦ ដោយចង្អុលបង្ហាញ អំពីតម្រូវការនៃរបៀបវារៈថ្មីដែលកំណត់ចេញចក្ខុវិស័យរយៈពេលវែងបន្ទាប់សម្រាប់ការអប់រំនៅក្នុងប្រទេស និងសម្រាប់គោលនយោបាយប្រកបដោយប្រសិទ្ធភាពការអភិវឌ្ឍដើម្បីយកឈ្នះលើបញ្ហាប្រឈមក្នុងការអនុវត្តកន្លងមក។

តារាងទី២ ៖ ឧបករណ៍រៀបចំផែនការអប់រំនៅប្រទេសថៃ

| | | |
|---|---|---|
| ផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ | ២០១២-២០១៦ | **ផែនការអភិវឌ្ឍន៍សម្រាប់ប្រទេសថៃដោយបញ្ចូលគោលបំណងអប់រំ**<br>លើកកម្ពស់ការរៀនសូត្រពេញមួយជីវិតនិងសេដ្ឋកិច្ចផ្អែកលើចំណេះដឹង។ |
| ការស្នើសម្រាប់ទសវត្សរ៍ទីពីរនៃកំណែទម្រង់នៃវិស័យអប់រំ | ២០០៩-២០១៨ | **ឯកសារផែនការពាក់កណ្តាលអាណត្តិ**<br>គោលដៅចម្បង៖ ការកែលំអគុណភាពបង្កើនឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នាពង្រឹងការចូលរួមរបស់ភាគីពាក់ព័ន្ធ។<br>វិធានការដោះស្រាយឱ្យរួមបញ្ចូលទាំងការវាយតម្លៃនិងការវាយតម្លៃអភិបាលកិច្ចសាលារៀនតូចនិងវិមជ្ឈការនិស្សិតជួបការលំបាក, និងកម្មវិធីសិក្សាលក្ខណៈសម្បត្តិក្របខ័ណ្ឌគុណភាពគ្រូបង្រៀននិងការបែងចែកថវិកា។ |
| ផែនការសកម្មភាពរយៈពេល ៤ ឆ្នាំរបស់ក្រសួងអប់រំ | ២០១៣-២០១៦ | **ឯកសារផែនការរយៈពេលខ្លី**<br>ផ្តល់នូវចក្ខុវិស័យបេសកកម្មនិងគោលដៅជាយុទ្ធសាស្ត្រ។មានគោលបំណងអភិវឌ្ឍការគ្រប់គ្រងការអប់រំការរៀនសូត្រពេញមួយការអប់រំនិងគុណភាពគ្រូនិងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា។ |

ប្រភព : UNESCO and IBE (2011), "Thailand", *World Data on Education*, www.ibe.unesco.org/ ileadmin/user_upload/Publications/WDE/2010/pdf-versions/Thailand.pdf; UNESCO Bangkok (2008),*Secondary Education Regional Information Base: Country Profile - Thailand*, www.uis.unesco.org/Library/Documents/Thailand.pdf.

### ១.៣.២ ប្រព័ន្ធអប់រំរបស់សាលារៀននៅក្នុងប្រទេសវៀតណាម

ប្រព័ន្ធអប់រំរបស់ប្រទេសវៀតណាមបានឆ្លងកាត់នូវការវិវត្តន៍ជាច្រើនសម័យកាល និងច្រើនដំណាក់កាល គិតចាប់តាំងពីសម័យសក្តិភូមិ និងអាណានិគម រហូតមកដល់សម័យកាលឆ្នាំ២០១០ ការអប់រំនៅក្នុងប្រទេសវៀតណាមមានការរីកចម្រើនជាលំដាប់។ ការកែទម្រង់លើវិស័យអប់រំនៅក្នុងប្រទេសវៀតណាម ត្រូវបានធ្វើឡើងជាច្រើនលើកច្រើនសារទៅតាមសម័យកាលនីមួយៗរបស់ប្រទេសវៀតណាម ហើយស្របគ្នានោះដែរក៏មាននូវបញ្ហាប្រឈមមួយចំនួនធំផងដែរ។ ក្នុងនោះក្រសួងអប់រំនៃប្រទេសវៀតណាមបានយកចិត្តទុកដាក់ទៅលើវិស័យអប់រំ ចំពោះគ្រប់កម្រិតដែលរួមមាន ការអប់រំថ្នាក់បឋមសិក្សា ការអប់រំក្នុងកម្រិតមធ្យមសិក្សា កម្រិតអប់រំវិជ្ជាជីវៈ និងកម្រិតបរិញ្ញាបត្រជាន់ខ្ពស់។ ការកែលម្អកម្មវិធីសិក្សាចំណេះទូទៅនៅប្រទេសវៀតណាមបានចាប់ផ្តើ

មជាផ្លូវការនៅឆ្នាំ២០០០ បន្ទាប់មករហូតដល់ឆ្នាំ២០០៦ កម្មវិធីសិក្សានិងសៀវភៅសិក្សាថ្មីៗត្រូវបានណែនាំនិងប្រើប្រាស់សម្រាប់ការបង្រៀននិងការរៀនសូត្រនៅគ្រប់ថ្នាក់ទាំងអស់នៅអនុវិទ្យាល័យ និងវិទ្យាល័យ។

### ១.៣.២.១ ការអប់រំបឋមសិក្សា

ការអប់រំបឋមសិក្សានៅប្រទេសវៀតណាមមាន ៥ ថ្នាក់ដោយចាប់ផ្តើមពីក្មេងអាយុ ៦ ឆ្នាំ មានន័យថាកុមារនឹងបញ្ចប់ការសិក្សាថ្នាក់បឋមសិក្សានៅអាយុ ១១ ឆ្នាំ។ នៅក្នុងកម្មវិធីសិក្សាបឋមសិក្សាបច្ចុប្បន្នកុមារនៅថ្នាក់ទី ១-៣ សិក្សាមុខវិជ្ជាចំនួន ៦ គឺ៖ ភាសាវៀតណាម គណិតវិទ្យា វិទ្យាសាស្ត្រធម្មជាតិនិងសង្គម ការអប់រំសីលធម៌ (ពលរដ្ឋ) អប់រំកាយ និងសិល្បៈ ហើយសម្រាប់កុមារថ្នាក់ទី៤-៥ ត្រូវរៀនថែមមួយមុខវិជ្ជាទៀតគឺ ប្រវត្តិសាស្ត្រ និងភូមិសាស្ត្រ។ ខណៈពេលមុខវិជ្ជាភូមិសាស្ត្រ វិទ្យាសាស្ត្រមានសៀវភៅសិក្សារបស់សិស្សហើយមុខវិជ្ជាដែលនៅសល់មានសៀវភៅណែនាំរបស់គ្រូ។

ក្នុងឆ្នាំសិក្សា ២០០៤-២០០៥ ប្រទេសវៀតណាមមានសាលាបឋមសិក្សាចំនួន ១៤,៥១៨ និងមានចំនួន ១,០៣៤ បញ្ចូលគ្នាបឋមសិក្សា និងអនុវិទ្យាល័យ ចំណែកឯចំនួនសិស្សបឋមសរុបវិញគឺមាន ៧,៧៧៣,៤៨៤ នាក់។ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះចំនួនសិស្សបឋមបានបន្តធ្លាក់ចុះ។ អ្នកវិភាគជឿជាក់ថាបាតុភូតនេះកើតឡើងដោយសារតែអត្រាកំណើនប្រជាជនមានការថយចុះ (ឧទាហរណ៍ការថយចុះចំនួនប្រជាជនអាយុពី ៦-១១ ឆ្នាំ) ។ ក្នុងគោលបំណងដើម្បីបំពេញបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ស្តីពីសកលភាវូបនីយកម្មអប់រំបឋមសិក្សានៅក្នុងឆ្នាំ ១៩៩១ (ឧទាហរណ៍កុមារគ្រប់រូបត្រូវបញ្ចប់បឋមសិក្សានៅអាយុ ១៤ ឆ្នាំចុងក្រោយ) សម្រាប់អតីតកាលជប់ឆ្នាំ ថ្ងៃទី ៥ ខែកញ្ញាត្រូវបានជ្រើសរើសជា" ថ្ងៃនាំកុមារទៅសាលារៀន"ក្នុងគោលបំណងលើកទឹកចិត្តគ្រួសារទាំងអស់ដែលមានកូនអាយុ ៦ ឆ្នាំឱ្យនាំកូន ៗ ទៅចុះឈ្មោះចូលរៀន។ ថ្នាក់ទី ១ ក្នុងឆ្នាំ ២០០០ អត្រាចុះឈ្មោះចូលរៀនរបស់កុមារអាយុ ៦-១១ ឆ្នាំគឺ ៩៥% ។ តួលេខនេះគឺមានច្រើនជាង៩៨% ក្នុងឆ្នាំសិក្សា ២០០៤-២០០៥ ។

គោលបំណងសម្រាប់ការអប់រំកម្រិតបឋមក្នុងអំឡុងពេលហូតដល់ឆ្នាំ ២០១០ គឺ៖ ដើម្បីសម្រេចបានគោលដៅសាកលភាវូបនីយកម្មនៃការអប់រំបឋមសិក្សាជាមួយ និងអាយុត្រឹមត្រូវ (ទាក់ទាញកុមារ ៩៩% ឱ្យចុះឈ្មោះនៅតាមសាលារៀននឹងកាត់បន្ថយអត្រាបោះបង់ចោលការសិក្សា) ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពនិងប្រសិទ្ធភាពនៃសាលា, ការផ្លាស់ប្តូរឆ្ពោះទៅរកសាលារៀនពេញមួយថ្ងៃ, ដើម្បីណែនាំភាសាបរទេសសម្រាប់សិស្សចាប់ពីថ្នាក់ទី៣ ដើម្បីលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការបង្រៀននឹងរៀន និងដើម្បីកាត់បន្ថយសមាមាត្រសិស្ស / គ្រូនិងទំហំថ្នាក់។

### ១.៣.២.២ ការអប់រំក្នុងកម្រិតមធ្យមសិក្សា

ការអប់រំអនុវិទ្យាល័យនៅវៀតណាមចែកជាពីរកម្រិត គឺអនុវិទ្យាល័យ និងវិទ្យាល័យ។ ទាបជាងអនុវិទ្យាល័យមានបួនថ្នាក់ (ថ្នាក់ទី ៦ ដល់ទី ៩) ។ មធ្យមសិក្សាទុតិយភូមិមានបីថ្នាក់ (ថ្នាក់ទី ១០ ដល់ ១២) ហើយខណៈដែលកម្រិតអនុវិទ្យាល័យទាបគឺមានលក្ខណៈជាសកល សិស្សបឋមដែលបានបញ្ចប់បឋមសិក្សាត្រូវបានអនុញ្ញាតឱ្យចូលថ្នាក់ទី ៦ សិស្សអនុវិទ្យាល័យទាំងអស់ត្រូវទទួលបានជោគជ័យក្នុងការប្រឡងជ្រើសរើសឱ្យបន្តទៅវិទ្យាល័យ។ ជម្រើសអាចត្រូវបានធ្វើឡើងតាមវិធីបីយ៉ាង៖

- តាមរយៈការប្រឡង
- តាមរយៈការពិចារណាផ្អែកលើលទ្ធផលនៃការសិក្សាថ្នាក់ទី ៩
- តាមរយៈការរួមបញ្ចូលគ្នាទាំងពីរខាងលើ។

ការសម្រេចចិត្តលើវិធីជ្រើសរើសដែលគួរតែត្រូវបានប្រើ នៅក្នុងខេត្តជាក់លាក់ឬទីក្រុងនឹងត្រូវបានធ្វើឡើងដោយគណៈកម្មាធិការរបស់ខេត្ត/ក្រុង។ ក្នុងឆ្នាំសិក្សា ២០០៤-២០០៥ ប្រទេសវៀតណាមមានអនុវិទ្យាល័យចំនួន ១០,០៧៥ ដែលមានសិស្សសរុបចំនួន ៦,៦៧០,៧១៤ នាក់។ សាលារៀនថ្នាក់វិទ្យាល័យមានចំនួន ២,២២៤ ដែលមានសិស្សសរុប ២,៨០២,១០១ នាក់។ នៅតាមខេត្តដែលសម្បូរជនជាតិភាគតិចច្រើន (ឧទាហរណ៍៖ ខេត្តដែលនៅតាមតំបន់ភ្នំ និងអ្នកដែលនៅតាមទីដាច់ស្រយាលជាច្រើន) នៅទីនោះគឺមានក្រុមប្រឹក្សាសាលាថ្នាក់វិទ្យាល័យ និងអនុវិទ្យាល័យខ្លះៗដែរ។ សាលាសរុបសម្រាប់កុមារជនជាតិភាគតិចមានចំនួន ៣២៥ សាលារៀន ដែលក្នុងនោះមាន ១១ សាលាកម្រិតកណ្តាលដែលមានសិស្សចំនួន ៤,៤០០ នាក់ ហើយ ៤៨ ជាសាលាថ្នាក់វិទ្យាល័យ ដែលមានសិស្សប្រមាណ ២ ម៉ឺននាក់ និង ២៦៦ គឺសាលាថ្នាក់អនុវិទ្យាល័យដែលមានសិស្សប្រមាណ ៦ ម៉ឺននាក់។

ការអនុវត្តកម្មវិធីសិក្សាមធ្យមសិក្សាថ្មីដែលត្រូវបានបញ្ចូល គឺជាផ្នែកមួយដែលសំខាន់នៃកំណែទម្រង់ ការអប់រំ។ ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ កម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិបានបែងចែកជាបីស្ទ្រីម៖

- មូលដ្ឋាន
- វិទ្យាសាស្ត្រពិត និងគណិតវិទ្យា
- វិទ្យាសាស្ត្រសង្គមនិងភាសាបរទេស

ស្ទ្រីមទាំងបីរួមមានមុខវិជ្ជាដូចជា អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ភាសាបរទេស នយោបាយ សញ្ជាតិ, និងការអប់រំកាយឬកីឡា។ ស្ទ្រីមវិទ្យាសាស្ត្រពិតទាមទារកម្រិតខ្ពស់សម្រាប់មុខវិជ្ជាចំនួន ៤៖ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា។ ចំណែកឯស្ទ្រីម វិទ្យាសាស្ត្រសង្គមនិងភាសាបរទេស ទាមទារកម្រិតខ្ពស់សម្រាប់មុខវិជ្ជាចំនួន ៤ គឺអក្សរសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងភាសាបរទេស។

វត្ថុបំណងក្នុងការអប់រំមធ្យមសិក្សាសម្រាប់រយៈពេលរហូតដល់ឆ្នាំ ២០១០ គឺ៖ ដើម្បីសម្រេចបាននូវសកលទាបអនុវិទ្យាល័យ; ដើម្បីទាក់ទាញសិស្ស ៩៩% នៅអាយុ ១១-១៥ ឆ្នាំនិង ៥០% ចំពោះសិស្សនៅអាយុនៃ ១៥-១៨ ដើម្បីចូលរៀនអនុវិទ្យាល័យនឹងមធ្យមសិក្សារៀងគ្នា ដើម្បីកាត់បន្ថយអត្រាបោះបង់ការសិក្សា និងដើម្បីធ្វើឱ្យប្រាកដថាសិស្សទាំងអស់ត្រូវបានផ្តល់ឱ្យនូវឱកាសដើម្បីបន្តសិក្សាភាសាបរទេសចាប់ពីថ្នាក់ទី ៦ ដល់ ថ្នាក់ទី១២ ។

**១.៣.២.៣ ការអប់រំវិជ្ជាជីវៈ**

អនុវិស័យអប់រំវិជ្ជាជីវៈរបស់វៀតណាមមានគោលបំណងបណ្តុះបណ្តាលកម្មករ និងជួយពួកគេក្នុងការស្វែងរកការងារធ្វើឬបន្ថែមជំនាញ / លក្ខណៈបច្ចេកទេស / គុណវុឌ្ឍិរបស់ពួកគេ។ នេះបើយោងតាមការអប់រំថ្មីច្បាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈមានបីកម្រិតគឺ បឋមសិក្សា មធ្យមសិក្សា និងមហាវិទ្យាល័យ។ ការបណ្តុះបណ្តាលបឋមត្រូវបានអនុវត្តក្នុងរយៈពេលតិចជាងមួយឆ្នាំ។ ការបណ្តុះបណ្តាលកម្រិតមធ្យមនឹងកម្រិតមហាវិទ្យាល័យធ្វើឡើងក្នុងរយៈពេលពី ១ ទៅ ៣ ឆ្នាំអាស្រ័យលើលក្ខណៈវិជ្ជាជីវៈ និងតម្រូវការ និងគុណវុឌ្ឍិរបស់សិស្ស។

ស្ថាប័នវិជ្ជាជីវៈរួមមានសាលាមធ្យមសិក្សាជំនាញក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំនឹងបណ្តុះបណ្តាល និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលនៅក្រោមការគ្រប់គ្រងក្រសួងការងារយុទ្ធជនពិការ និងសង្គមកិច្ច (MOLISA)។ យោងតាមច្បាប់អប់រំប្រព័ន្ធបណ្តុះបណ្តាលវិជ្ជាជីវៈក្រោមការទទួលខុសត្រូវរបស់MOLISA នឹងផ្លាស់ប្តូរការផ្តល់ការបណ្តុះបណ្តាលនៅកម្រិតទាំងបីគឺ បឋមសិក្សា មធ្យមសិក្សា និងមហាវិទ្យាល័យ។

ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ (២០០១-២០០៥) បណ្តាញអប់រំវិជ្ជាជីវៈ (ក្រោមការគ្រប់គ្រងរបស់MOLISA) ត្រូវបានពង្រីងនឹងអភិវឌ្ឍន៍។ បច្ចុប្បន្នមានចំនួន ១,៦៨៨ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈទូទាំងប្រទេស។ ទាំងនេះរួមបញ្ចូលទាំងសាលាវិជ្ជាជីវៈចំនួន ២៣៦ (កើនឡើងទ្វេដងបើប្រៀបធៀបជាមួយឆ្នាំ ១៩៩៨) មជ្ឈមណ្ឌលវិជ្ជាជីវៈចំនួន ៤០៤និងមានវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈជាង ១,០០០ ថ្នាក់។[5] នៅក្នុងប្រព័ន្ធស្ថាប័នវិជ្ជាជីវៈនៅទីនោះគឺជាសាលាឯកជន និងបរទេសដែលផ្តល់មូលនិធិដោយសាលាក៏ដូចជាសាលាដែលជាកម្មសិទ្ធិរបស់កងទ័ពបណ្តុះបណ្តាលទាហានដែលរុះរើ។ ដូចជាសម្រាប់អនុវិទ្យាល័យវិជ្ជាជីវៈ (ក្រោមការគ្រប់គ្រងរបស់ MOET) ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយចំនួនទាំងនេះបានកើនឡើងទោះបីមានការធ្វើឱ្យប្រសើរនៃសាលាមួយចំនួន ដើម្បីក្លាយជាមហាវិទ្យាល័យក៏ដោយក្តី។ ជាក់ស្តែងមានសាលាចំនួន ២៥៣ នៅក្នុងឆ្នាំសិក្សា

[5] Draft report on Phase I (2001-2005) implementation of the Strategic Plan for Educational Development during 2001-2010 period, the National Institute for Educational Strategy and Curriculum.

២០០០-២០០១ និងសាលាចំនួន ២៨៥ នៅឆ្នាំ ២០០៤-២០០៥ ឆ្នាំសិក្សាមាន សិស្សនិស្សិតចំនួន ២៨៣,៣៣៥នាក់។ ក្នុងចំណោមនោះមានសាលារដ្ឋចំនួន ២៣៨ និងសាលាឯកជនចំនួន ៤៧ ។

ចំណុចខ្វះខាតដែលត្រូវដោះស្រាយទាក់ទងនឹងស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈបណ្តាញ គឺថាទោះបីជាសាលាវិជ្ជាជីវៈ និងមជ្ឈមណ្ឌលត្រូវបានចែកចាយស្មើៗគ្នាក៏ដោយ តែបណ្តាខេត្តមូលដ្ឋានមួយចំនួននៅតែមិនមាន។ នៅឆ្នាំ ២០០៤ មានតែប្រហែល១០០ស្រុកប៉ុណ្ណោះ ក្នុងចំណោម ៦០០ស្រុក ដែលមានមណ្ឌលវិជ្ជាជីវៈ (១៦,៦%) ។ ទន្ទឹមនឹងនេះគោលបំណងសម្រាប់រយៈពេលរហូតដល់ឆ្នាំ ២០១០ គឺ ១០០% នៃស្រុកទាំងអស់នឹងមានមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ ជាមួយបណ្តាញស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈចង្អៀតបែបនេះវាពិតជាលំបាកណាស់ក្នុងការបំពេញការបណ្តុះបណ្តាលការទាមទារ នៅតាមមូលដ្ឋានជាពិសេសនៅតំបន់ជនបទ។ លើសពីនេះទៀត តម្រូវការសម្រាប់មនុស្សដែលមានជំនាញធនធានជាពិសេសសម្រាប់សហគ្រាសដែលផ្តល់មូលនិធិដោយបរទេសកំពុងក្លាយជារឿងបន្ទាន់។ បើទោះយ៉ាងណាសមត្ថភាពបណ្តុះបណ្តាលរបស់ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈវៀតណាម នៅតែមានច្រើនមានកំណត់។

គោលបំណងនៃការអប់រំវិជ្ជាជីវៈសម្រាប់រយៈពេលរហូតដល់ឆ្នាំ ២០១០ គឺ៖ ដើម្បីបង្កើតឱ្យមានការអនុវត្តជាក់ស្តែងនូវប្រព័ន្ធបណ្តុះបណ្តាលបច្ចេកទេសដែលឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ យកចិត្តទុកដាក់លើការបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លីរបស់កម្មករជំនាញអ្នកបច្ចេកទេស និងវិជ្ជាជីវៈបុគ្គលិកនៅកម្រិតមហាវិទ្យាល័យនៅលើមូលដ្ឋាននៃកម្រិតមធ្យមសិក្សាខ្ពស់ឬមធ្យម និងដើម្បីទាក់ទាញ៣០% នៃនិស្សិតដែលបានបញ្ចប់/បញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ និង១០ភាគរយនៃនិស្សិតទាំងនោះបញ្ចប់មធ្យមសិក្សាទុតិយភូមិ ដើម្បីចូលរៀននៅសាលាវិជ្ជាជីវៈនៅកម្រិតមធ្យមនឹងកម្រិតមហាវិទ្យាល័យរៀងៗខ្លួន។

### ១.៣.២.៤ ការសិក្សាកម្រិតខ្ពស់

ឧត្តមសិក្សានៅប្រទេសវៀតណាមរួមមាន ៤ កម្រិតគឺមហាវិទ្យាល័យ កម្រិតបរិញ្ញាបត្រ កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតៈ

- ការបណ្តុះបណ្តាលកម្រិតមហាវិទ្យាល័យរយៈពេលជាង ២-៣ ឆ្នាំសម្រាប់សិស្សអនុវិទ្យាល័យ ឬនិស្សិតបញ្ចប់ការសិក្សាមធ្យមសិក្សាវិជ្ជាជីវៈ
- ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើវគ្គសិក្សា ៤-៦ ឆ្នាំអាចរកបានសម្រាប់អនុវិទ្យាល័យឬ និស្សិតបញ្ចប់ការសិក្សាមធ្យមសិក្សាវិជ្ជាជីវៈ
- វគ្គបណ្តុះបណ្តាលកម្រិតអនុបណ្ឌិតរយៈពេល ១-២ ឆ្នាំសម្រាប់និស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ។

- ការបណ្តុះបណ្តាលកម្រិតបណ្ឌិតក្នុងរយៈពេល ៤ ឆ្នាំសម្រាប់និស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ។

ក្នុងឆ្នាំសិក្សា ២០០៤-២០០៥ វៀតណាមមានមហាវិទ្យាល័យនិងសាកលវិទ្យាល័យចំនួន ២៣០ ដែលក្នុងនោះមាន និស្សិតចំនួន១,៣១៩,៧៥៤នាក់ ហើយចំពោះអង្គភាពបណ្តុះបណ្តាលក្រោយបញ្ចប់ការសិក្សា (Post graduate training unit) មានចំនួន ១២២ ដែលមាននិស្សិតអនុបណ្ឌិត និងនិស្សិតផ្នែកស្រាវជ្រាវ ៣៤,៧៨៩ នាក់។

ក្នុងរយៈពេល ២០ ឆ្នាំនៃការកែទម្រង់ការអប់រំ ឧត្តមសិក្សារបស់វៀតណាមបានឆ្លងកាត់ការកត់សម្គាល់ការអភិវឌ្ឍ ការពង្រីកការចុះឈ្មោះចូលរៀន ក្នុងគោលបំណងបណ្តុះបណ្តាលនឹងការធ្វើពិពិធកម្មនៃភាពជាម្ចាស់ និងធនធានសម្រាប់ការវិនិយោគ។ ដូចជាកំណើនការចុះឈ្មោះក្នុងឆ្នាំ ២០០១-២០០២ដល់ឆ្នាំ ២០០៤-២០០៥ ឆ្នាំសិក្សាតែមួយឆ្នាំចំនួននិស្សិតមហាវិទ្យាល័យបានកើនឡើង ២៩,៧% ដែលមាននិស្សិតសាកលវិទ្យាល័យចំនួន ៣៧,១% និងនិស្សិតសញ្ញាបត្រអនុបណ្ឌិត និងបណ្ឌិតចំនួន ៦២,៤% ។

ទោះយ៉ាងណាក៏ដោយការអប់រំជាន់ខ្ពស់របស់ប្រទេសវៀតណាម នៅតែប្រឈមនឹងភាពមិនស៊ីសង្វាក់ក្នុងការបំពេញតម្រូវការឧស្សាហូបនីយកម្មទំនើបកម្ម និងសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ និងអនុវិស័យ មិនទាន់បានបំពេញតម្រូវការរបស់ប្រជាជនសម្រាប់ការសិក្សាកម្រិតឧត្តមនៅឡើយ។ សាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ គឺនៅមានការខ្វះខាតក្នុងការទំនាក់ទំនងនឹងតថៈភាពសង្គម។ គុណភាពនឹងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលត្រូវបានអន់ថយ ចំណែកវិធីសាស្ត្របង្រៀន និងការរៀនគឺហួសសម័យ។ ធនធាននៅមានកម្រិត ហើយការប្រើប្រាស់ធនធាននូវមិនទាន់មានប្រសិទ្ធិភាពនៅឡើយ ចំណែកឯស្ថាប័នស្វ័យភាព និងគណនេយ្យភាពមិនបានប្រើពេញលេញទេ។ ចំណុចខ្វះខាត និងភាពមិនត្រូវគ្នាទាំងនេះទាមទារបន្ថែមទៀតក្នុងការពង្រឹង និងធ្វើកំណែទម្រង់បន្ថែមចំពោះឧត្តមសិក្សាក្នុងប្រទេសវៀតណាម។

### ១.៣.២.៥ គោលបំណងនៃការអប់រំ

ប្រព័ន្ធអប់រំរបស់វៀតណាមមានគោលបំណងដោះស្រាយភារកិច្ចធំៗ ចំនួន ៣ គឺការកែលម្អចំណេះដឹងរបស់ប្រជាជន, បណ្តុះបណ្តាលធនធានមនុស្ស និងទេពកោសល្យចិញ្ចឹមបីបាច់ ។[6] ក្នុងរយៈពេលជាង ៣០ ឆ្នាំកន្លងមកប្រទេសវៀតណាមត្រូវបានអនុវត្ត Doi Moi (ការច្នៃប្រឌិត) ដែលជាយុទ្ធនាការបើកចំហរក្នុងស្រុកដែលបានអនុវត្តតាមរយៈពេលនៃសេដ្ឋកិច្ចមជ្ឈិម។ សម្រាប់ជនជាតិវៀតណាម ការអប់រំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ច - សង្គម។ លើសពីនេះទៀតសាកលភាវូបនីយកម្ម និងដំណើរការកំពុងបន្តរបស់វៀតណាមសមាហរណកម្មអន្តរជាតិទាមទារ ឱ្យមានការកែទម្រង់យ៉ាងទូលំទូលាយនៅក្នុងវិស័យអប់រំ

[6] Vietnamese Education System and Teacher Training: Focusing on Science Education។

ជាប្រព័ន្ធ (សមាជ XIII ឆ្នាំ ២០១៤) ។ ដើម្បីឱ្យកំណែទម្រង់នេះទទួលបានជោគជ័យអ្នកស្រាវជ្រាវត្រូវធ្វើការឆ្លុះបញ្ចាំងពីកំណែទម្រង់វិស័យអប់រំរបស់ប្រទេសវៀតណាមចាប់តាំងពីសក្តិភូមិរហូតដល់សម័យទំនើប ដែលបទពិសោធន៍ទាំងនេះអាចនាំផ្លូវឆ្ពោះទៅមុខដើម្បីធ្វើឱ្យប្រព័ន្ធអប់រំក្នុងប្រទេសវៀតណាមអាចត្រៀមសម្រាប់ពេលអនាគត។

### ១.៣.៣ ការអប់រំក្នុងប្រទេសមីយ៉ាន់ម៉ា

នៅពេលដែលលទ្ធិប្រជាធិបតេយ្យមានការរីកចម្រើននៅក្នុងប្រទេសមីយ៉ាន់ម៉ា វាចាំបាច់សម្រាប់គ្រប់វិស័យទាំងអស់ត្រូវធ្វើឱ្យប្រសើរឡើងដើម្បីឆ្លើយតបនឹងប្រទេសនេះគឺ តម្រូវឱ្យមានស្តង់ដារនៃប្រព័ន្ធប្រជាធិបតេយ្យ។ ក្នុងគោលបំណងអភិវឌ្ឍធនធានមនុស្ស កំណែទម្រង់ការអប់រំរបស់មីយ៉ាន់ម៉ាបានចាប់ផ្តើមក្នុងឆ្នាំ ២០១១ នៅពេលដែលប្រព័ន្ធរដ្ឋាភិបាលរបស់ប្រទេសបាន ផ្លាស់ប្តូរពីរដ្ឋាភិបាលយោធាមួយទៅលទ្ធិប្រជាធិបតេយ្យមួយ។ ឥឡូវរដ្ឋាភិបាលថ្មីរបស់មីយ៉ាន់ម៉ា បានធ្វើកំណែទម្រង់វិស័យអប់រំជាអាទិភាពរបស់ជាតិ។

ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈម និងចន្លោះប្រហោងក្នុងប្រព័ន្ធអប់រំ រដ្ឋាភិបាលរបស់ប្រទេសមីយ៉ាន់ម៉ាបានសហការជាមួយដៃគូអភិវឌ្ឍន៍ ហើយបានឈានដល់ការពិនិត្យឡើងវិញលើវិស័យអប់រំទូលំទូលាយ។ សមិទ្ធផលសំខាន់ៗនៃការធ្វើកំណែទម្រង់ការអប់រំរហូតមកដល់ពេលនេះរួមមានទាំងការបង្កើនថវិកាសម្រាប់ការអប់រំការបោះពុម្ពផ្សាយកច្បាប់អប់រំថ្មី និងការដកថ្លៃសាលារដ្ឋ។ ចាប់ផ្តើមពីឆ្នាំសិក្សា ២០១៥-២០១៦ ការចុះឈ្មោះចូលរៀនដោយមិនគិតថ្លៃសម្រាប់សិស្សវិទ្យាល័យ។ ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា គឺបានធ្វើឱ្យឥតគិតថ្លៃនៅឆ្នាំ ២០១០-២០១១ និងអនុវិទ្យាល័យនានានៅឆ្នាំ ២០១៣-២០១៤។ លើសពីនេះទៅទៀតគោលនយោបាយ និងច្បាប់ត្រូវបានដាក់ជាផ្នែកមួយនៃដំណើរការនៃកំណែទម្រង់ប្រព័ន្ធអប់រំ។ ច្បាប់ដែលត្រូវបានអនុម័តថ្មីបំផុតគឺច្បាប់ស្តីពីការអប់រំជាតិក្នុងឆ្នាំ ២០១៤ និងវិសោធនកម្មនៃច្បាប់ស្តីពីការអប់រំជាតិក្នុងឆ្នាំ ២០១៥ គោលនយោបាយអប់រំត្រូវបានដាក់ក្នុងឆ្នាំ២០១១ នេះបើយោងតាមគោលការណ៍ណែនាំរបស់អតីតប្រធានាធិបតី។

ទោះបីការចំណាយបច្ចុប្បន្នលើការអប់រំនៅមីយ៉ាន់ម៉ាខ្ពស់ជាងពីមុន តែវានៅមានកម្រិតទាបបើប្រៀបធៀបជាមួយប្រទេសជិតខាង។ លើសពីនេះទៀតអនុបាតសិស្ស - គ្រូប្រទេសភូមាមានអត្រាខ្ពស់ជាងនៅប្រទេសជិតខាងដូចជាថៃជាដើមទាំងកម្រិតបឋម និងមធ្យមសិក្សា។ កម្មវិធីសិក្សាហួសសម័យក៏ធ្វើឱ្យការអប់រំរបស់ប្រទេសមីយ៉ាន់ម៉ា មិនសូវមានប្រសិទ្ធភាពផងដែរ។ ប្រទេសនេះបានធ្វើកំណែទម្រង់កម្មវិធីសិក្សារបស់ខ្លួនម្តងចន្លោះពីឆ្នាំ ១៩៩៥ និង ១៩៩៩ និងកម្មវិធីសិក្សានេះត្រូវបានប្រើប្រាស់ជាបន្តបន្ទាប់រហូតដល់ឆ្នាំសិក្សា ២០១៥-២០១៦ ។ ទោះយ៉ាងណាក៏ដោយបណ្តាប្រទេសផ្សេងទៀតកែសម្រួលកម្មវិធីសិក្សារបស់ពួកគេជាញឹកញាប់ ។

### ១.៣.៣.១ ប្រព័ន្ធអប់រំមូលដ្ឋាន

យោងតាមក្រសួងការបរទេសមីយ៉ាន់ម៉ា៖‟ រាល់កុមារដែលមានអាយុចូលសាលា” និង‟ ការអប់រំសម្រាប់ទាំងអស់គ្នា” គឺជាបាវចនាដែលជួយជម្រុញធ្វើឱ្យគុណភាពអប់រំរបស់ប្រទេសមីយ៉ាន់ម៉ាកាន់តែប្រសើរ។ ដើម្បីឈានទៅរកយុគសម័យព័ត៌មានវិទ្យាគ្រប់វិទ្យាល័យ ក៏ដូចជាសាលាបឋមសិក្សាគឺកំពុងត្រូវបានបំពាក់ដោយកុំព្យូទ័រ ដើម្បីជួយសិស្សឱ្យស្គាល់ប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក។ សាលារៀនបណ្តុះបណ្តាលសិស្សឱ្យមានអាកប្បកិរិយាខាងសីលធម៌ និងសង្គម។

ប្រព័ន្ធអប់រំមូលដ្ឋានបច្ចុប្បន្ននៅមីយ៉ាន់ម៉ា រួមមានបឋមសិក្សា ៦ ឆ្នាំ (ថ្នាក់ទី ១ ដល់ថ្នាក់ទី ៦) អនុវិទ្យាល័យរយៈពេល ៣ ឆ្នាំ (ថ្នាក់ទី ៧ ដល់ទី ៩) និងការអប់រំរយៈពេល ២ ឆ្នាំនៃវិទ្យាល័យ (ថ្នាក់ទី ១០ និងទី ១១)។ បច្ចុប្បន្ននេះមានសាលាអប់រំមូលដ្ឋានចំនួន ៤៧, ៣៦៥ ក្នុងប្រទេសមីយ៉ាន់ម៉ាដែលមាននិស្សិតប្រមាណ ៩,២៦ លាននាក់។ ភាគច្រើននៃសាលាទាំងនេះគ្រប់គ្រងដោយនាយកដ្ឋានអប់រំមូលដ្ឋានក្រោមក្រសួងអប់រំ (MOE) ។ ចំនួនសាលារៀនគ្រូនិងសិស្សក្នុងការអប់រំមូលដ្ឋានក្នុងឆ្នាំសិក្សា ២០១៥-២០១៦ មានចុះក្នុងតារាងខាងក្រោម។

តារាងទី៣ ៖ ចំនួនសាលារៀនគ្រូនិងនិស្សិត ឆ្នាំសិក្សា២០១៥ - ២០១៦

| លេខរៀង | ប្រភេទសាលា | ចំនួនសាលារៀន (ឆ្នាំ ២០១៦) | ចំនួនគ្រូបង្រៀន | ចំនួនសិស្ស |
|---|---|---|---|---|
| ១ | បឋមសិក្សា | ៣៥,៦៥០ | ១៥៨,១៧៦ | ៥,១៨៤,០៤១ |
| ២ | វត្តអារាម | ១,៥៣៨ | ១១,០៤៤ | ២៩៧,០៣៩ |
| ៣ | មធ្យមសិក្សាបឋមភូមិ | ៦,២២៤ | ១២៩,៩៤៥ | ២៧៩៥,៦០៧ |
| ៤ | មធ្យមសិក្សាទុតិយភូមិ | ៣,៥១៥ | ៣៤,៣៩៣ | ៨៧៣,៨៣២ |
| ៥ | សាលាឯកជន | ៤៣៨ | ៧,៣៩៧ | ១០៧,៤៥១ |
| | សរុប | ៤៧,៣៦៥ | ៣៤០,៩៥៥ | ៩,២៥៧,៩៧០ |

ប្រភព ៖ Education System in Myanmar Brief Description of Primary, Secondary and Tertiary education, http://afeo.org/wp-content/uploads/2018/09/Education-System-in-Myanmar-Brief-Description-of-Primary-Secondary-Tertiary-Education.pdf

### ១.៣.៣.២ ការអប់រំបឋមសិក្សា

សាលាមត្តេយ្យក្នុងប្រទេសមីយ៉ាន់ម៉ាបើកសម្រាប់ កុមារអាយុចន្លោះពី ២ ទៅ ៥ ឆ្នាំ។ កុមារចូលសាលាបឋមសិក្សាជាផ្លូវការនៅអាយុ ៦ ឆ្នាំ។ ការអប់រំនៅបឋមសិក្សានៅប្រទេសមីយ៉ាន់ម៉ាជាគឺចាប់ពី ថ្នាក់ទី ១ ដល់

ទី ៥ ហើយបន្ទាប់ពីបញ្ចប់ការសិក្សានៅបឋមសិក្សាយៈពេល ៥ ឆ្នាំ សិស្សនឹងត្រូវបានអនុញ្ញាតឱ្យចូលរៀនបន្តនៅអនុវិទ្យាល័យប្រសិនបើពួកគេប្រឡងជាប់គ្រប់មុខវិជ្ជា។

**១.៣.៣.៣ ការអប់រំអនុវិទ្យាល័យ និងវិទ្យាល័យ**

ការអប់រំនៅអនុវិទ្យាល័យនៅប្រទេសមីយ៉ាន់ម៉ាមានកម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ។ សិស្សចុះឈ្មោះចូលរៀននៅអនុវិទ្យាល័យចាប់ពីអាយុ ១២ ដល់ ១៦ ឆ្នាំដែលពួកគេបានបញ្ចប់ថ្នាក់ទី ៦ ដល់ទី ៩ ។ ពួកគេនឹងបន្តទៅរៀននៅវិទ្យាល័យបន្ទាប់ពីឆ្លងកាត់ការប្រឡងស្តង់ដារមួយ។ សិស្សត្រូវបានអនុញ្ញាតឱ្យចូលរៀននៅវិទ្យាល័យចាប់ពីអាយុ ១៧ ដល់ ១៩ ឆ្នាំដែលពួកគេនឹងបញ្ចប់ថ្នាក់ទី ១០ និង ១១។ ដើម្បីទទួលបានសញ្ញាបត្រនិស្សិតត្រូវធ្វើការប្រឡងស្តង់ដាអប់រំលេខ ១០ ដែលពួកគេនឹងត្រូវបានផ្តល់សញ្ញាបត្រ A ឬសញ្ញាបត្រខ។ សញ្ញាបត្រអ្នកកាន់មានសិទ្ធិចូលសាកលវិទ្យាល័យ។

**១.៣.៣.៤ ការអប់រំថ្នាក់បរិញ្ញាបត្រ**

ការប្រលងចូលសាកលវិទ្យាល័យដែលគ្រប់គ្រងដោយ ក្រុមប្រឹក្សាមីយ៉ាន់ម៉ានៃការប្រឡងត្រូវបានធ្វើឡើងនៅពាក់កណ្តាលខែមីនាជារៀងរាល់ឆ្នាំ។ ក្នុងប្រទេសមីយ៉ាន់ម៉ាមានសាកលវិទ្យាល័យ និងមហាវិទ្យាល័យចំនួន៤៧ និងសាលាបច្ចេកទេសនិងវិជ្ជាជីវៈចំនួន ១៥៤ ។ ក្នុងឆ្នាំ ២០០៤ រដ្ឋាភិបាលមីយ៉ាន់ម៉ាបាននិយាយថានៅចន្លោះឆ្នាំ ១៩៨៩ និង ២០០៤ ចំនួនមហាវិទ្យាល័យនិងសាកលវិទ្យាល័យបានកើនឡើងពី ៣២ ទៅ ១៥៤ ដោយការចុះឈ្មោះចូលរៀនរបស់និស្សិតមានការកើនឡើងពី ១២០,០០០ ទៅ ៨៩០,០០០។[7]

[7] Jeffrey H, Education in Myanmar(2008), FACTS AND DETAILS https://factsanddetails.com/southeast-asia/Myanmar/sub5_5f/entry-3117.html, (ចូលទស្សនាថ្ងៃទី១៩ មិថុនា ២០២១)។

# ជំពូកទី២
# វិស័យអប់រំនៅកម្ពុជាមុន
# ពេលការរីករាលដាលនៃ
# ជម្ងឺកូវីដ-១៩

# ជំពូកទី២

# វិស័យអប់រំនៅកម្ពុជាមុនពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩

## ២.១ ការវិវត្តន៍នៃប្រព័ន្ធអប់រំ

### ២.១.១ ការអប់រំតាមបែបប្រពៃណី

នៅក្នុងប្រទេសកម្ពុជាប្រព័ន្ធអប់រំ ត្រូវបានបង្កើតតាំងពីយូរលង់ណាស់មកហើយ(យ៉ាងហោចណាស់តាំងពីសតវត្សរ៍ទី ១៣) ។ ជាប្រពៃណី ការអប់រំរបស់ប្រជាជនកម្ពុជាមានដើមកំណើតឡើងនៅក្នុងវត្តអារាម ហើយត្រូវបានផ្តល់ជូនសម្រាប់តែបុរសប៉ុណ្ណោះ ហើយការអប់រំគឺទាក់ទងទៅនឹងអក្សរសិល្ប៍ មូលដ្ឋានគ្រឹះនៃសាសនា និងជំនាញផ្សេងៗ សម្រាប់ជីវិតប្រចាំថ្ងៃដូចជាជាងឈើ សិប្បកម្ម សំណង់ លេងឧបករណ៍តន្ត្រីជាដើម។ ល។

ការអប់រំបែបប្រពៃណីនេះត្រូវបានផ្លាស់ប្តូរជាបណ្តើរៗ នៅពេលដែលប្រទេសបារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជា (១៨៦៣-១៩៥៣) គឺបារាំងបានណែនាំនូវប្រព័ន្ធអប់រំផ្លូវការមួយដែលទទួលឥទ្ធិពលពីគំរូអប់រំបច្ចិមប្រទេស។ តែនៅក្នុងអំឡុងពេលសង្គ្រាមស៊ីវិល ប្រព័ន្ធអប់រំបានជួបវិបត្តិរ៉ាំរ៉ៃហើយត្រូវបានបំផ្លាញទាំងស្រុងក្នុងរបបខ្មែរក្រហមក្រហម (១៩៧០) ហើយនៅចន្លោះឆ្នាំ ១៩៨០ និង ១៩៩០ ការអប់រំត្រូវបានកសាងឡើងវិញពី " គ្មានអ្វីទាល់តែសោះ" ហើយត្រូវបានអភិវឌ្ឍបន្តិចម្តង ៗ រហូតមកដល់បច្ចុប្បន្ន។[8]

### ២.១.២ ក្រោយពីកំណែទម្រង់ក្នុងឆ្នាំ១៩៩៦

បច្ចុប្បន្នបន្ទាប់ពីការកែទម្រង់របស់ខ្លួនក្នុងឆ្នាំ ១៩៩៦ រចនាសម្ព័ន្ធអប់រំផ្លូវការរបស់ប្រទេសកម្ពុជាត្រូវបានបង្កើតឡើងក្នុងគោលការណ៍ ៦ + ៣ + ៣ ។ ៦ឆ្នាំដំបូងសម្រាប់ការសិក្សាអប់រំបឋមសិក្សា(ថ្នាក់ទី១ ដល់ទី៦) ហើយ ៣ឆ្នាំបន្ទាប់សម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិ(ថ្នាក់ទី៧ ដល់ទី៩) បន្ទាប់មកសិស្សត្រូវធ្វើការសិក្សាថ្នាក់មធ្យមសិក្សាតុទិយភូមិ ៣ឆ្នាំបន្ថែមទៀត(ថ្នាក់ទី១០ ដល់ទី១២) មុនពេលមានសិទ្ធប្រឡងយកសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

រាជរដ្ឋាភិបាលបាននឹងកំពុងផ្តល់ការយកចិត្តទុកដាក់ខ្ពស់ ទៅលើវិស័យអប់រំ ដែលជាវិស័យអាទិភាពមួយដ៏សំខាន់ ដោយហេតុថា វិស័យនេះ គឺជាឆ្អឹងខ្នង សម្រាប់ទ្រទ្រង់ ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ព្រមទាំងការអភិវឌ្ឍ វិស័យដទៃៗទៀត។[9]

---

[8] យុត សុខន, *ប្រព័ន្ធអប់រំនៅកម្ពុជា* (២០១៩), BOOKBRIDGE [https://opendevelopmentcambodia.net/km/social-accountability/primary-education/] (ចូលទស្សនាថ្ងៃទី20 ឧសភា ២០២១)។

[9] LOR SOVANNEY, វិស័យអប់រំ ជាឆ្អឹងខ្នងសម្រាប់ទ្រទ្រង់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ (២០១៦) [https://www.cpp.org.kh/details/9567] (ចូលទស្សនាថ្ងៃទី20 ឧសភា ២០២១)។

### ២.១.៣ កំណែទម្រង់នៅក្នុងឆ្នាំ២០១៤

ឆ្លងកាត់កំណែទម្រង់ជាច្រើនលើកច្រើនសារមក នៅក្នុងឆ្នាំ២០១៤ ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការកែទម្រង់លើប្រព័ន្ធអប់រំ ក្នុងគោលបំណងធ្វើឱ្យគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាកាន់តែមានភាពល្អប្រសើរឡើងបន្ថែមទៀត ដើម្បីឈានរកការប្រកួតប្រជែកក្នុងឆាកអន្តរជាតិ។

នៅក្នុងឆ្នាំ២០១៤ ក្រសួងអប់រំយុវជន និងកីឡា បានធ្វើការកែទម្រង់លើវិស័យអប់រំ ដោយធ្វើការរឹតបន្តឹងចំពោះការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។ ជាលទ្ធផលការប្រឡងត្រូវបានធ្វើឡើងចំនួនពីរដងបន្តបន្ទាប់គ្នា។ ដោយសារតែលទ្ធផលនៃការប្រឡងលើទី១ មានអត្រាមានសិស្សជាប់បាក់ឌុបទូទាំងប្រទេសមានចំនួនត្រឹមតែ ២៣,១២៦នាក់ ដែលស្មើនឹង ២៥% ប៉ុណ្ណោះនៃចំនួនបេក្ខជនដែលប្រឡងសរុប។[10]

ចំណែកឯលទ្ធផលនៃការប្រលងលើកទី២ មានសិស្សជាប់ចំនួន ១២,១៩៩នាក់ ស្មើ ១៧,៩៤% ក្នុងចំណោមបេក្ខជនសរុប ៦៨,000 នាក់ ប៉ុន្តែគ្មានអ្នកជាប់និទ្ទេស A ឡើយ។[11]

នៅក្នុងឆ្នាំ ២០១៤ នេះផងដែរ ក្រសួងអប់រំយុវជន និងកីឡា គឺមាននូវយុទ្ធសាស្ត្រសម្រាប់វិស័យអប់រំឆ្នាំ ២០១៤-២០១៨ គឺផ្តោតលើការបន្តសកម្មភាពការពង្រីក និងការបន្តនិរន្តរភាពនៃសមិទ្ធផលដែលបានសម្រេចកន្លងមកទាក់ទងនឹងការចូលរៀន ការលើកកម្ពស់សមធ៌ម ការបង្កើនគុណភាព និងភាពឆ្លើយតបសម្រាប់កុមារ និងយុវជន តាមរយៈការផ្តល់សេវាអប់រំប្រកបដោយវិជ្ជាជីវៈ តម្លាភាពនឹងគណនេយ្យភាព។[12]

### ២.១.៤ កំណែទម្រង់ក្នុងឆ្នាំ២០១៨

នៅក្នុងឆ្នាំ ២០១៨ ក្រសួងអប់រំបានធ្វើការយកចិត្តទុកដាក់ លើវិស័យអប់រំជាបន្តបន្ទាប់ ហើយអ្វីដែលគួរឱ្យកត់សម្គាល់សម្រាប់ឆ្នាំ២០១៨នោះគឺ លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានការប្រកាសពីរដង ក្រោយមានបញ្ហាបច្ចេកទេស ក្នុងការកែកំណែវិញ្ញាសាប្រឡង ដោយពឹងផ្អែកទៅលើបច្ចេកវិទ្យាកុំព្យូទ័រលើកទីមួយ។[13]

---

[10] សុភាព. មណ្ឌលពត៌មានស្ត្រីកម្ពុជា,បទវិភាគ៖ វិស័យអប់រំនៅកម្ពុជា, ថ្ងៃចន្ទ ទី២១ ខែកញ្ញា ឆ្នាំ២០១៥ [https://wmc.org.kh/%E1%9E%94%E1%9E%91%E2%80%8B%E1%9E%9C%E1%9E%B7%E1%9E%97%E1%9E%B6%E1%9E%82%E1%9F%96%E2%80%8B%E1%9E%9F%E1%9F%92%E1%9E%8A%E1%9E%B8%E2%80%8B%E1%9E%96%E1%9E%B8%E2%80% 8B-%E2%80%8B%E1%9E%9C%E1%9E%B7/] (ចូលទស្សនាថ្ងៃទី20 ឧសភា ឆ្នាំ ២០២១)។

[11] CNC, ២០១៤-២០១៩ ឆ្នាំទី៦នៃកំណែទម្រង់ប្រលងបាក់ឌុប"អ្នកចេះ គឺជាប់", ១៩-សីហា-២០១៩ ០២:០០ ព្រឹក [https://www.cnc.com.kh/detail/news/4186] (ចូលទស្សនាថ្ងៃទី២០ ឧសភា ២០២១) ។

[12] ក្រសួងអប់រំយុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៤-២០១៨, ខែ មីនា ឆ្នាំ២០១៤។ https://www.moeys.gov.kh/index.php/kh/policies-and-strategies/559.html#.YLiOHKgzZPY (ចូលទស្សនាថ្ងៃទី២១ ឧសភា ២០២១)។

[13] មួង សារ៉េត, ក្រសួងអប់រំរងការរិះគន់ ថាខ្វះភាពប្រាកដនិយមក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (២០១៨), វិទ្យុអាស៊ីសេរី RFA, ′[https://www.rfa.org/khmer/news/social-economy/MoEYS-is-criticized-about-BakII-result-09142018233905.html] (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២១)។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនការទទួលបានសេវាអប់រំសម្រាប់កុមារកម្ពុជាគ្រប់រូប ការលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្ស និងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធ។ ក្រោយមកទៀតនៅក្នុងឆ្នាំ ២០១៩ សម្រាប់ដំណាក់កាលបន្ទាប់គឺផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ និងឆ្ពោះទៅឆ្នាំ ២០៣០ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ស្តីពីការអប់រំ ដោយឈរលើគោលការណ៍ គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត និងទាំងអស់គ្នា។ [14]

## ២.២ ប្រព័ន្ធអប់រំក្នុងប្រទេសកម្ពុជា

### ២.២.១ អប់រំកុមារតូច

ក្នុងឆ្នាំសិក្សា២០១២-២០១៣ កុមារអាយុ៥ឆ្នាំ ៥៦,៤៩ ភាគរយ បានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូចបើធៀបនឹងឆ្នាំសិក្សា២០០៨-២០០៩ មានត្រឹមតែ ៣៥ ភាគរយប៉ុណ្ណោះ ។ កុមារអាយុចន្លោះ ៣-៤ ឆ្នាំបានចូលរៀន ២១,២៣ ភាគរយ ប៉ុន្តែការទទួលបានសេវាអប់រំកុមារតូចនៅអាយុក្រោម ៣ ឆ្នាំ សម្រេចបានតែ ៣,១៩ ភាគរយប៉ុណ្ណោះ។ វឌ្ឍនភាពកើតឡើងដោយសារការពង្រីកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មត្តេយ្យក្នុងបឋមសិក្សា មត្តេយ្យឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងតាមខ្នងផ្ទះជាដើម។

តារាងទី៤ ៖ បង្ហាញពីចំនួនកុមារតូចនៅក្នុងប្រទេសកម្ពុជាដែលបានទទួលសេវាអប់រំ(ចូលរៀន)

| អាយុ | ចំនួនកុមារ( គិតជាភាគរយ ) | ឆ្នាំសិក្សា |
|---|---|---|
| ៥ឆ្នាំ | ៣៥% | ២០០៨-២០០៩ |
| ៥ឆ្នាំ | ៥៦,៤៩% | ២០១២-២០១៣ |
| ៣-៤ឆ្នាំ | ២១,២៣% | ២០១២-២០១៣ |
| ក្រោមអាយុ ៣ឆ្នាំ | ៣,១៩% | ២០១២-២០១៣ |

អន្តរាគមន៍លក្ខណៈជាគោលនយោបាយក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ កន្លងមក គឺជាមូលដ្ឋានគ្រឹះសម្រាប់ការឈានទៅបង្កើនគុណភាពនៃសេវាអប់រំកុមារតូចនៅក្នុងឆ្នាំ២០១៨។ មូលដ្ឋានគ្រឹះទាំងនោះមានដូចជា ការរៀបចំគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្តីពីការគាំពារនឹងអភិវឌ្ឍកុមារតូច។ គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍកុមារតូច បានប្រកាសស្តីពីការគ្រប់គ្រងសាលាមត្តេយ្យសិក្សាឯកជន និងប្រកាសស្តីពីការទទួលស្គាល់គ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងនោះក៏រួមមានគោលការណ៍ប្រតិបត្តិសម្រាប់កម្មវិធីអប់រំមាតាបិតា រួមបញ្ចូលទាំងស្ត្រីមានផ្ទៃពោះ និងមាតាបិតាដែលមានកូនអាយុក្រោម ២ ឆ្នាំ និង

[14] ក្រសួងអប់រំ យុវជន និងកីឡា, ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩-២០២៣ (២០២១), https://www.moeys.gov.kh/index.php/kh/policies-and-strategies/3206.html#.YLb7eLczblU, (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២១)។

គោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យធនធាន ហើយប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើ លទ្ធផល សម្រាប់ចក្ខុវិស័យអប់រំកុមារតូចត្រូវបានរៀបចំ ដើម្បីលើកកម្ពស់គុណភាពអប់រំផងដែរ។[15]

### ២.២.២ ការអប់រំបឋមសិក្សា

កុមារបានចូលរៀននៅបឋមសិក្សាកាន់តែច្រើន ជាក់ស្តែងអត្រាពិតនៃការសិក្សាបានកើនពី ៩៤,៨ ភាគរយទៅដល់ ៩៧ ភាគរយ និងគ្មានគម្លាតយេនឌ័រ ចំណែកឯអត្រាត្រួតថ្នាក់ និងសិស្សបោះបង់ការសិក្សាបានថយចុះ។ សាលាបឋមសិក្សាមិនគ្រប់កម្រិតត្រូវបានបន្ថែមបន្ទប់រៀនដើម្បីក្លាយជាសាលាគ្រប់កម្រិត ហើយការសិក្សារបស់កុមារពិការ និងកុមារក្រៅសាលាត្រូវបានធ្វើឡើងនៅតាមសាលារៀនមួយចំនួន។ សាលារៀនភាគច្រើនបានអនុវត្តតាមគោលនយោបាយសាលាកុមារមេត្រី ហើយឧបករណ៍សម្រាប់វាយតម្លៃការសិក្សារបស់សិស្សត្រូវបានរៀបចំ និងបានបង្ហាញថាការសិក្សារបស់សិស្សបានល្អប្រសើរ ជាពិសេសមុខវិជ្ជាភាសាខ្មែរនៅកម្រិតថ្នាក់ដំបូង។ ការអប់រំពីរភាសាកំពុងត្រូវបានពង្រីក ក៏ដូចគ្នានឹងថ្នាក់ពន្លឿនការអប់រំ និងថ្នាក់គួបផងដែរ។ អាហារូបករណ៍ប្រមាណ ១៥,០០០ បានផ្តល់ដល់សិស្សក្រីក្រនៅបឋមសិក្សា។ ថវិកាកែលម្អសាលារៀនត្រូវបានផ្តល់ជូនសាលារៀនប្រមាណ ៦០០ សាលា ជាផ្នែកមួយនៃកម្មវិធីដែលបានពង្រីកទូទាំងប្រទេសក្នុងឆ្នាំសិក្សា ២០១៣-២០១៤។ គ្រូបង្រៀនជាច្រើននាក់ត្រូវបានបំប៉នអំពី ប្រសិទ្ធភាពនៃការរៀននិងបង្រៀន។

ការអប់រំបឋមសិក្សាត្រូវបានចាត់ទុកជាអាទិភាពមួយ និងទទួលបាននូវចំណែកថវិកាច្រើនជាងគេក្នុងថវិកាសរុបរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ការផ្តល់ហិរញ្ញប្បទានសម្រាប់បឋមសិក្សាគួរត្រូវបន្តជាអាទិភាពតទៅទៀត និងត្រូវបង្ហាញច្បាស់អំពីទំនាក់ទំនងរវាងធនធាននឹងលទ្ធផល។[16]

### ២.២.៣ ការអប់រំចំណេះទូទៅ

បើយោងតាមក្រសួងអប់រំយុវជន និងកីឡា នៅក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ សកម្មភាពគោលនយោបាយមួយចំនួនត្រូវបានរៀបចំដូចជា ផែនការគោលស្តីពីការអភិវឌ្ឍមធ្យមសិក្សា និងសៀវភៅប្រតិបត្តិសម្រាប់ដំណើរការមជ្ឈមណ្ឌលធនធានសម្រាប់មធ្យមសិក្សា គោលនយោបាយស្តីពីសាលាកុមារមេត្រីនៅមធ្យមសិក្សា និងការកែលម្អកម្មវិធីសិក្សា។ មិនតែប៉ុណ្ណោះប្រព័ន្ធវិក្រឹតការគ្រូបង្រៀន លើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រត្រូវបានរៀបចំ ហើយកម្មវិធីបំណិនជីវិតបច្ចេកវិទ្យា ព័ត៌មាន និងទេសចរណ៍ត្រូវបានអនុម័ត និងស្តង់ដារបណ្ណាល័យនៅមធ្យមសិក្សាក៏កំពុងរៀបចំជាសេចក្តីព្រាងផងដែរ។

---

[15] ក្រសួងអប់រំ យុវជន និងកីឡា , អប់រំកុមារតូច [http://moeys.gov.kh/index.php/kh/early-childhood-education.html#.YJYKDNUzbIU] (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២១)។

[16] ក្រសួងអប់រំ យុវជន និងកីឡា, *បឋមសិក្សា* [http://moeys.gov.kh/index.php/kh/primary-education.html#.YJYLmNUzbIU] (ចូលទស្សនាថ្ងៃទី២២ ឧសភា ២០២១)។

ការចូលរៀន និងគុណភាពនៅកម្រិតនេះមានការប្រែប្រួលតិចតួច ពោលគឺអត្រាត្រួតថ្នាក់បានថយចុះ តិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សាមិនមានការប្រែប្រួលទេ។ សិស្សភាគច្រើនបានជ្រើសរើសយកមុខវិជ្ជា វិទ្យាសាស្ត្រពិត។ ទោះយ៉ាងណាក៏ដោយ គុណភាពនៅកម្រិតនេះមិនទាន់អាចវាស់វែងបាននៅឡើយ ដោយសារពុំទាន់បានធ្វើតេស្តវាយតម្លៃថ្នាក់ជាតិនៅថ្នាក់ទី ១២ ។ អាហារូបករណ៍បានផ្តល់ជារៀងរាល់ឆ្នាំ ហើយសិស្សបានទទួលមេដាយលើមុខវិជ្ជាគណិតវិទ្យានិងវិទ្យាសាស្ត្រ ទៅលើកម្មវិធីប្រកួតអន្តរជាតិផ្សេងៗទៀត។

ការប្រឡងថ្នាក់ជាតិនៅថ្នាក់ទី ៩ និងទី ១២ ត្រូវបានអនុវត្តជាទៀងទាត់។ ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើង ដែលក្នុងនោះសាលាមធ្យមសិក្សាបឋមភូមិ ៥០ ភាគរយ បានអភិវឌ្ឍទៅជាសាលាមធ្យមសិក្សាទុតិយភូមិ ហើយមជ្ឈមណ្ឌលធនធាននៅមធ្យមសិក្សាត្រូវបានក៏សាងនៅគ្រប់រាជធានី ខេត្ត។ លើសពីនេះទៅទៀតសាលាមធ្យមសិក្សាបឋមភូមិចំនួន ១៤១ ក្នុងខេត្ត ៨ មានបន្ទប់កុំព្យូទ័រ។ ប្រព័ន្ធនៃការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ជាពិសេសគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំកំពុងត្រូវបានពង្រីក ហើយស្តង់ដារគ្រូបង្រៀនត្រូវបានពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍជាប្រចាំ។

គុណភាពរបស់សិស្សបញ្ចប់ថ្នាក់ទី ១២ ត្រូវលើកកម្ពស់ និងផ្តល់នូវចំណេះដឹងពាក់ព័ន្ធដទៃទៀតសម្រាប់ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា។ វិធីសាស្ត្រក្នុងការបង្រៀនក្នុងពេលបច្ចុប្បន្នអនុវត្តតាមរបៀបជាមេរៀន ចម្លងតាម ដកស្រង់ និងការចងចាំ ហើយវិធីសាស្ត្រទាំងនេះ ត្រូវបានបញ្ចូលនូវការគិត និងជំនាញវិភាគ។[17]

## ២.២.៤ ការអប់រំឧត្តមសិក្សា

ក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ ការអប់រំនៅឧត្តមសិក្សា មានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងនោះការចូលរៀនរបស់និស្សិតកើនឡើងដល់ ២០៧,០០០ នាក់ និងនិស្សិតទទួលអាហារូបករណ៍មាន ៤,២០០នាក់ ព្រមទាំងការកើនឡើងនៃចំនួនគ្រឹះស្ថានឧត្តមសិក្សា ដែលសម្រេចបានតាមបទដ្ឋាននៃការទទួលស្គាល់។ អគ្គនាយកដ្ឋានឧត្តមសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ក្នុងការងារកសាងផែនការ និងពិនិត្យតាមដាន ការគ្រប់គ្រងមូលនិធិស្រាវជ្រាវ និងអាហារូបករណ៍ និងមានលទ្ធភាពទាញយកមូលនិធិកាន់តែច្រើនដើម្បីធ្វើការពង្រីកកម្មវិធីសិក្សា។ គណៈកម្មការទទួលស្គាល់គុណភាពអប់រំ កម្ពុជាមានសមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រងនឹងដំណើរការប្រព័ន្ធទទួលស្គាល់គុណភាព។ វប្បធម៌នៃការស្រាវជ្រាបានចាប់ផ្តើមផុស

[17] ក្រសួងអប់រំ យុវជន និងកីឡា, អប់រំចំណេះទូទៅ
[http://moeys.gov.kh/index.php/kh/general-secondary-education.html#.YJYL2NUzbIU] (ចូលទស្សនាថ្ងៃទី ២២ ឧសភា ២០២១)។

ឡើង តាមរយៈការអនុវត្តកម្មវិធីផ្តល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិការក្នុងតំបន់រឹងមាំ កិច្ចសហការ និងសកម្មភាពបានអនុវត្តរួមគ្នា។

ការបង្កើនកិច្ចខិតខំប្រឹងប្រែងនិងការផ្តល់ធនធានបន្ថែមជាកត្តាចាំបាច់ ដើម្បីធានាថាសិស្សដែលមានទេពកោសល្យ និងមកពីក្រុមជួបការលំបាកនឹងអាចចូលសិក្សានៅឧត្តមសិក្សា តាមរយៈកម្មវិធីអាហារូបករណ៍ ឬ គម្រោងប្រាក់កម្ចីសិក្សា។

រាជរដ្ឋាភិបាលបានទទួលស្គាល់ពីសារៈសំខាន់នៃការផ្តល់ឱកាស ក្នុងការសិក្សានៅឧត្តមសិក្សា និងអំពីសារៈសំខាន់ក្នុងការធានាគុណភាពនឹងភាពឆ្លើយតប ហើយការធ្វើសមាហរណកម្មអាស៊ាន និងផ្តល់ជាឱកាសសម្រាប់ការសហការរវាងស្ថាប័ន ការស្រាវជ្រាវរួមគ្នា និងការកំណត់ស្តង់ដារគុណភាព។[18]

### ២.២.៥ អប់រំក្រៅប្រព័ន្ធ

ការអប់រំក្រៅប្រព័ន្ធជាប្រព័ន្ធអប់រំមួយដែលផ្តល់នូវឱកាសរៀនសូត្រដល់កុមារ និងយុវជនក្រៅសាលា សិស្សបោះបង់ការសិក្សា និងអនក្ខរជនគ្រប់វ័យ គ្រប់ប្រភេទ ដើម្បីជួយឱ្យពួកគេទទួលបានចំណេះដឹង ចំណេះធ្វើក្នុងការកែលម្អគុណភាពជីវភាពរស់នៅឱ្យកាន់តែប្រសើរឡើង។

នៅក្នុងអំឡុងឆ្នាំ២០០៩-២០១៣ អនុវិស័យអប់រំក្រៅប្រព័ន្ធមានការរីកចម្រើន ដែលគេឃើញថាមានអត្រាអក្ខរកម្មយុវជនអាយុ ១៥-២៤ឆ្នាំ កើនដល់ ៩១,៥% នៅក្នុងឆ្នាំ២០១១។

តារាងទី៥ ៖ បង្ហាញពីទិន្នន័យទាក់ទងនឹងការអប់រំក្រៅប្រព័ន្ធ

| ប្រភេទ | ឆ្នាំ | | |
|---|---|---|---|
| | ២០០៩ | ២០១១ | ២០១២ |
| **អ្នកសិក្សា** | ៥២,០៧៨នាក់ | ៣៤,៩៦៤នាក់ | - |
| **ថ្នាក់អក្ខរកម្ម** | ២,១៤១ថ្នាក់ | ១៥០០ថ្នាក់ | - |
| **មជ្ឈមណ្ឌលសិក្សាសហគមន៍** | ១៥៤កន្លែង | - | ៣២១កន្លែង |
| **ថ្នាក់បណ្តុះបណ្តាលជំនាញ** | ១៥៤ថ្នាក់ | - | ៦៦៧ថ្នាក់ |

ប្រភព : ក្រសួងអប់រំ យុវជន និង កីឡា, ការអប់រំក្រៅប្រព័ន្ធ

សម្រាប់ថ្នាក់បណ្តុះបណ្តាលជំនាញគឺរួមមានជំនាញផ្សេងៗគ្នា; ជំនាញសិប្បកម្ម ជំនាញអ៊ុតសក់នឹងតុបតែង ជំនាញភ្លេងនឹងរបាំ ជំនាញម៉ាស៊ីន និងមានជំនាញផ្សេងៗដ៏ទៃទៀតផងដែរ។

ប៉ុន្តែចំនួនសិស្សក្នុងកម្មវិធីចូលរៀនឡើងវិញបានថយចុះពី ២៦,១៧៦ នាក់ មកត្រឹម ២១,៣៦៦ នាក់ ទាបជាងចំណុចដៅរបស់ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២២,០០០ នាក់ ហេតុដូចនេះក្របខ័ណ្ឌស្ថាប័ននឹង

[18] ក្រសួងអប់រំ យុវជន និងកីឡា, *ឧត្តមសិក្សា*
[http://moeys.gov.kh/index.php/kh/higher-education.html#.YJYMGtUzblU] (ចូលទស្សនាថ្ងៃទី ២២ ឧសភា ២០២១)។

គោលនយោបាយត្រូវបានពង្រឹង តាមរយៈ ការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនឹងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀន ឡើងវិញនិងការរៀបចំសេចក្ដីណែនាំស្ដីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល ហើយជាលទ្ធផលគេទទួលបានអត្រាអក្ខរជនអាយុ១៥ឆ្នាំឡើងមាន៨៧.៧%ក្នុងឆ្នាំ២០១៩។[19]

ក្រាហ្វិចទី១ ៖ អត្រាអក្ខរជនអាយុ១៥ឆ្នាំឡើងពីឆ្នាំ២០១១ ដល់ឆ្នាំ ២០១៩




ប្រភព : របាយការណ៍ពិស្ដារស្ដីពី ការងារអប់រំក្រៅប្រព័ន្ធឆ្នាំ២០២០

លើសពីនេះដើម្បីពង្រឹងបន្ថែមលើអនុវិស័យអប់រំក្រៅប្រព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដែលបានកំណត់វត្ថុបំណងគោលនយោបាយអនុវិស័យអប់រំក្រៅប្រព័ន្ធ ដូចខាងក្រោម៖

- បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ សម្រាប់កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យ ទទួលបានសេវាអប់រំក្រៅប្រព័ន្ធពេញលេញក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា
- ពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលរបស់កម្មវិធីអប់រំក្រៅប្រព័ន្ធ ឱ្យមានដំណើរការពេញលេញ
- លើកកម្ពស់សម្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់។

[19] ក្រសួងអប់រំ យុវជន និងកីឡា, អប់រំក្រៅប្រព័ន្ធ [http://moeys.gov.kh/index.php/kh/non-formal-education.html#.YJYMT9UzbIU] (ចូលទស្សនាថ្ងៃទី ២២ ឧសភា ២០២១)។

សម្រាប់លទ្ធផលក្នុងឆ្នាំ២០២០ ដោយសារតែបញ្ហានៃការរីករាលដាលនៃជម្ងឺកូវីត-១៩ បានធ្វើឱ្យសកម្មភាពមួយចំនួនថយចុះស្ទើរទាំងស្រុង ពោលគឺសកម្មភាពថ្នាក់កម្មវិធីចូលរៀនឡើងវិញមាននៅតែ៣ខេត្តប៉ុណ្ណោះ គឺខេត្តកណ្ដាល ព្រះវិហារ និងតាកែវ ដែលបានបំប៉នសិក្សាបោះបង់ថ្នាក់ទី៣ ដល់ទី៦ ចំនួន៩១ថ្នាក់ មានសិក្សាចូលរៀនសរុប ១៧,៤២នាក់ ស្រី ៧៤៤នាក់ ក្នុងនោះថ្នាក់ទី៣ ចំនួន៤៧៨នាក់ ស្រី១៩២នាក់ ថ្នាក់ទី៤ ចំនួន៤៣៣នាក់ ស្រី១៩៤នាក់ ថ្នាក់ទី៥ចំនួន ៥៨៥នាក់ ស្រី២៤៦នាក់ និងថ្នាក់ទី៦ ចំនួន២៤៦នាក់ ស្រី ១១២ នាក់។

ក្រាហ្វិចទី២ ៖ បង្ហាញពីចំនួនសិស្សចូលរៀនក្នុងកម្មវិធីចូលរៀនឡើងវិញតាមកម្រិតថ្នាក់




ប្រភព : របាយការណ៍ពិស្តារស្តីពី ការងារអប់រំក្រៅប្រព័ន្ធឆ្នាំ២០២០

## ២.៣ ផលប៉ះពាល់នានាលើវិស័យអប់រំ

### ២.៣.១ កត្តាជីវភាព ឬ ភាពក្រីក្រ

កុមារអាយុ ៥-១៤ ឆ្នាំ ២២,៥% ជួបការខ្វះខាតក្នុងសមាសភាគអប់រំ ដែលទំនងជាកើតឡើងដោយសារអត្រាខ្ពស់នៃការមិនបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាក្នុងចំណោមកុមារ ដែលលើសអាយុចូលរៀននៅបឋមសិក្សា (អាយុ ១២, ១៣, ១៤ឆ្នាំ) និងដោយសាតែកុមារ ១៦,៨% ក្នុងក្រុមអាយុនេះមានអាយុច្រើនជាងអាយុដែលត្រូវចូលរៀន ចាប់ពីពីរឆ្នាំឡើងទៅ។ នេះគឺជាការព្រួយបារម្ភដោយហេតុថា បើទោះបីជាអត្រាចុះឈ្មោះចូលរៀនជាមូលដ្ឋានមានកម្រិតខ្ពស់យ៉ាងណាក៏ដោយមានកុមារមួយភាគធំ ដែលពុំបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សាសមស្របទៅតាមអាយុរបស់ពួកគេ។ នេះបង្ហាញពីចំណុចខ្សោយនៃគុណភាពរបស់សាលារៀននៅកម្ពុជា ដែលធ្វើឱ្យកុមារមិនអាចឡើងទៅរៀននៅកម្រិតថ្នាក់ខ្ពស់សមស្របទៅ និងអាយុរបស់ពួកគេឬបង្ហាញពីជីវភាពរស់នៅ ដែលធ្វើឱ្យកុមារពុំអាចបញ្ចប់ការសិក្សាបានដូចជា ចំណូលរបស់គ្រួសារទាប ការជ្រើសរើសរវាងទៅរៀន ឬធ្វើការ ឬការចុះឈ្មោះចូលរៀនលើសអាយុជាដើម។ ការសម្រេចលទ្ធផលទាបនៃសូចនាករអប់រំ ក៏អាចមានទំនាក់ទំនងជាមួយនឹងការផ្តល់សេវាអភិវឌ្ឍន៍កុមារតូច ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយពុំទាន់គ្រប់គ្រាន់ផង

ដែរ ដូចជា ការខ្វះការផ្តល់អាហារឱ្យបានគ្រប់គ្រាន់នៅវ័យកុមារតូច ដែលនាំឱ្យកុមារកាន់តែជួបការលំបាកក្នុងការរៀនសូត្រ នៅពេលដែលកុមារទាំងនេះទៅរៀននៅសាលា។ អត្រាជួបការលំបាកក្នុងសូចនាករនៅកម្រិតគ្រួសារ ដូចជា សមាសភាគលំនៅដ្ឋាន អនាម័យ និងទឹកជាដើម គឺមានកម្រិតខ្ពស់ស្រដៀងគ្នានឹងអត្រារបស់ក្រុមអាយុផ្សេងទៀតផងដែរ។

ក្រាហ្វិចទី៣ ៖ អត្រាជួបការខ្វះខាត រាប់តាមចំនួនមនុស្ស លើវិស័យអប់រំ(%) បែងចែកតាមសូចនាករ កុមារអាយុ ៥-១៤ឆ្នាំ




ប្រភព : UNICEF , របាយការណ៍ភាពក្រីក្ររបស់កុមារនៅក្នុងរបាយការណ៍សង្ខេបរបស់ប្រទេសកម្ពុជាកាលបរិច្ឆេទផ្សព្វផ្សាយ : មិថុនា 2018 https://www.unicef.org/cambodia/reports/child-poverty-report-cambodia

## ២.៣.២ កត្តាសង្គ្រាម

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រជាច្រើនហូរហែរ ហើយកម្ពុជាក៏ជាប្រទេសមួយដែលឆ្លងកាត់មកនូវសង្គ្រាមជាច្រើនផងដែរទម្រាំតែទទួលបាននូវសុខសន្តិភាពដូចបច្ចុប្បន្ននេះ។ ចំពោះវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាវិញ គឺមានការឆ្លងកាត់នូវការកែទម្រង់ជាច្រើនលើកច្រើនសារទៅតាមសម័យកាលនីមួយៗ ដើម្បីឱ្យមានភាពកាន់តែប្រសើរឡើង។ ឆ្លងកាត់មកជាច្រើនសម័យកាល វិស័យអប់រំធ្លាប់បានជួបប្រទះនូវផលប៉ះពាលនានាជាច្រើន ហើយក្នុងនោះកត្តាសង្គ្រាមគឺជាផលប៉ះពាល់ធំមួយផងដែរមកលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ដែលបានបំផ្លិចបំផ្លាញនូវហេដ្ឋារចនាសម្ព័ន្ធជាច្រើនរួមមានសាលារៀនផងនោះ ព្រមទាំងធ្វើ

ឱ្យប្រទេសកម្ពុជាបាត់បង់នូវធនធានមនុស្សជាច្រើននាក់ ចំណែកការការអប់រំក៏មានភាពធ្លាក់ចុះទៅតាមនោះដែរ។

ជាកាពិតណាស់ប្រទេសកម្ពុជាបានឆ្លងកាត់នូវសង្គ្រាមស៊ីវិលអស់រយៈពេល៥ឆ្នាំ (១៩៧០-១៩៧៥) ហើយក្នុងអំឡុងពេលនោះ សង្គ្រាមបានបំផ្លាញអ្វីៗគ្រប់យ៉ាងនៅក្នុងប្រទេសកម្ពុជា សង្គ្រាមបានសម្លាប់ប្រជាជនកម្ពុជាជាងមួយលាននាក់ ព្រមទាំងបន្សល់ទុកនូវអ្នករបួស ជនពិការ ក្មេងកំព្រា ស្ត្រីមេម៉ាយ ប្រជាជនភៀសខ្លួនពីជនបទចូលទីក្រុង រស់ដោយខ្វះស្បៀង ជួបភាពអនាធិបតេយ្យ អំពើហឹង្សាចោរកម្ម អំពើសូកប៉ាន់រីកដុះដាលដល់វិស័យសិក្សាធិការ បំផ្លាញធនធានមនុស្ស គ្រឹះស្ថានសិក្សា វត្តអារាម លំនៅដ្ឋាន ហើយវាបានបង្កមហន្តរាយ និង បំផ្លាញហេដ្ឋារចនាសម្ព័ន្ធ គ្រឹះសេដ្ឋកិច្ច សង្គម និង នាំកម្ពុជាទៅរករបបប្រល័យពូជសាសន៍។[20]

ជាក់ស្តែងនៅក្នុងរបបប្រល័យពូជសាសន៍សាលារៀន និងសាកលវិទ្យាល័យនៅទូទាំងប្រទេសកម្ពុជា ត្រូវមេដឹកនាំខ្មែរក្រហមសម្រេចបិទទ្វាចោល បន្ទាប់ពីជ័យជម្នះ ១៧ មេសា ឆ្នាំ ១៩៧៥(បន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់) ដែលធ្វើឱ្យវិស័យអប់រំនាសម័យនោះបានធ្លាក់ស្ទើរដល់កម្រិតសូន្យ។ ការមិនទទួលស្គាល់សមត្ថភាពអ្នកឯកទេស និងការកាប់សម្លាប់បញ្ញាជន ខ្មែរក្រហមបានធ្វើឱ្យប្រទេសកម្ពុជារងគ្រោះកាន់តែធ្ងន់ធ្ងរឡើង ព្រមទាំងបន្សល់ទុកផលវិបាកជាច្រើនដល់ប្រជាជនកម្ពុជា។[21]

នេះបញ្ជាក់ឱ្យឃើញថា កត្តាសង្គ្រាមបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា ដោយឆ្លងកាត់នៅសង្គ្រាមស៊ីវិលអស់រយៈពេល៥ឆ្នាំ បន្តចូលមកក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ទៀត នោះគឺកាន់តែឱ្យវិស័យអប់រំនៅក្នុងប្រទេសកម្ពុជានាសម័យនោះធ្លាក់ដល់កម្រិតសូន្យ ដោយសារតែហេដ្ឋារចនាសម្ព័ន្ធដែលរួមមានគ្រឹះស្ថានសិក្សាផងនោះត្រូវបានបំផ្លាញស្ទើរតែទាំងស្រុង ហើយពេលចូលដល់សម័យខ្មែរក្រហមទៀតសោត គឺសាលាត្រូវបានបិតទ្វា រួមទាំងការមិនឱ្យតម្លៃលើការអប់រំ សម្លាប់ចោលស្ទើរទាំងអស់នូវបញ្ញាវ័ន ដែលជាហេតុធ្វើឱ្យវិស័យអប់រំគឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

### ២.៣.៣ កត្តាជម្ងឺឆ្លង

ជម្ងឺឆ្លងក៏ជាកត្តាមួយដែលជះឥទ្ធិពល ផ្តល់ផលប៉ះពាល់មកលើវិស័យអប់រំនៅក្នុងប្រទេសទាំងមូលផងដែរ។ ជាក់ស្តែងជម្ងឺកូវីដ-១៩ គឺជាជម្ងឺឆ្លងថ្មីមួយដែលបច្ចុប្បន្នកំពុងតែមានការរាតត្បាតនៅក្នុងប្រទេសកម្ពុជា ហើយវាបានផ្តល់ផលវិបាកជាច្រើនមកលើគ្រប់វិស័យទាំងអស់នៅក្នុងប្រទេស ហើយក្នុងនោះវិស័យអប់រំត្រូវរងផលប៉ះពាល់យ៉ាងដំណំផងដែរ។ ដោយសារតែជម្ងឺឆ្លងមួយនេះ ការអប់រំត្រូវបានផ្លាស់ប្តូរបរិបទសិក្សាភ្លាមៗមក

[20] សារឌី, សម័យសាធារណរដ្ឋ ខ្មែរឆ្នាំ១៩៧០-១៩៧៥ , [https://khmerdeng.com/khmerpublic/] (ចូលទស្សនាថ្ងៃទី ២៣ កក្កដា ២០២១)។

[21] ហ៊ុយ វណ្ណៈ, ការអប់រំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, [https://www.rfa.org/khmer/program/krhistory/Road_To_Death_Field71-05022008040916.html] (ចូលអានថ្ងៃទី២៣ កក្កដា ២០២១)។

ធ្វើការសិក្សាតាមប្រព័ន្ធអនឡាញ(E-learning)។ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យសាលារៀននៅទូទាំងប្រទេសកម្ពុជាត្រូវបានបិទទ្វា ហើយការសិក្សាក៏ដូចជាការបង្រៀនត្រូវធ្វើឡើងតាមរយៈអនឡាញវិញ ដែលធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងចំពោះសិស្ស និស្សិត និងគ្រូ ជាពិសេសគឺអ្នកនៅតាមទីជនបទ។

ចំណែកឯគុណភាពអប់រំវិញ ពិតណាស់ច្បាស់ជាមិនសូវមានគុណភាពដូចកាលដែលរៀនផ្ទាល់នៅក្នុងថ្នាក់រៀនឡើយ ព្រោះប្រព័ន្ធបច្ចេកវិទ្យា ធនធាន បទពិសោធន៍ ក៏ដូចជាចំណេះដឹងទៅលើការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាក្នុងការរៀន និងបង្រៀនគឺនូវមានកម្រិត។

មិនចំពោះតែប្រទេសកម្ពុជាប៉ុណ្ណោះនោះទេ វិស័យអប់រំតាមបណ្តាប្រទេសនៅលើពិភពលោកក៏កំពុងប្រឈមនូវផលប៉ះពាល់មកលើវិស័យអប់រំដោយសារតែកត្តាជម្ងឺឆ្លងនេះ ជាពិសេសគឺចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រព័ន្ធបច្ចេកវិទ្យាមិនសូវមានភាពរីកចម្រើន។ មាននិស្សិតនិងយុវជនជាង ១,៥ ពាន់លាននាក់នៅទូទាំងពិភពលោកត្រូវបានប៉ះពាល់ដោយសាលា និងសាកលវិទ្យាល័យការបិទទ្វាដោយសារការផ្ទុះឡើងនៃជម្ងឺកូវីដ-១៩ ។[22] រដ្ឋាភិបាលភាគច្រើននៅជុំវិញពិភពលោកជាបណ្តោះអាសន្នបានបិទស្ថាប័នអប់រំក្នុងគោលបំណងទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតជម្ងឺឆ្លងមួយនេះ។ ការបិទទូទាំងប្រទេសទាំងនេះកំពុងមានឥទ្ធិពលលើ ៩០% នៃចំនួននិស្សិតពិភពលោក ហើយច្រើនបណ្តាប្រទេសបានអនុវត្តការបិទមូលដ្ឋាន ដែលបានធ្វើឱ្យប៉ះពាល់ដល់អ្នកសិក្សាបន្ថែមរាប់លាននាក់។[23]

កត្តាជម្ងឺឆ្លងគឺពិតជាជះឥទ្ធិពលមួយផ្នែកធំមកលើវិស័យអប់រំយ៉ាងពិតប្រាដកណាស់ ព្រោះក្រៅពីការបិទគ្រឹះស្ថានសិក្សាមិនបានទៅរៀនផ្ទាល់ក្នុងថ្នាក់ សុខភាពសិស្ស និស្សិត និងគ្រូគឺជាបញ្ហាចោទមួយដែលសំខាន់ក្នុងការអភិវឌ្ឍន៍វិស័យអប់រំមួយនៅក្នុងប្រទេសផងដែរ។ ប្រសិនបើគ្មាការរាតត្បាតនៃជម្ងឺឆ្លងណាមួយ នោះគ្រប់គ្នាមានសុខភាពល្អ ការសិក្សា ក៏ដូចជាការបង្រៀនគឺនឹងទទួលបានលទ្ធផលល្អទៅតាមនោះដែរ។ ដូចឧទាហរណ៍ជាក់ស្តែងស្រាប់ចំពោះជម្ងឺកូវីដ-១៩ គឺពិតជាផ្តល់ផលលំបាកយ៉ាងខ្លាំងដល់វិស័យអប់រំ។

## ២.៤ គោលនយោបាយ និង ផែនការយុទ្ធសាស្ត្រលើកកម្ពស់គុណភាពវិស័យអប់រំ

ក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានដើរតួរយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និង ទិសដៅសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ឈរលើមូលដ្ឋាននេះ កម្ពុជាបានសម្រេចគោលដៅធំៗជាច្រើន ដូចជា សន្តិភាព ស្ថេរភាពនយោបាយ វិបុលភាព និងការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនោះកម្ពុជាបានធ្វើ

[22] https://en.unesco.org/covid19/educationresponse/globalcoalition (ចូលទស្សនាថ្ងៃទី២៣ កក្កដា ២០២១)។

[23] Valerie Strauss, [https://www.washingtonpost.com/education/2020/04/06/schools-more-than-90-percent-worlds-students-closed-during-this-pandemic-this-graphic-shows-how-fast-it-happened/] (ចូលទស្សនាថ្ងៃទី២៣ កក្កដា ២០២១)។

មូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍សហវត្សរ៍សកលទៅជាគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា និងបានសម្រេចគោលដៅជាច្រើនមុនកាលកំណត់ឆ្នាំ ២០១៥។[24]

### ២.៤.១ យុទ្ធសាស្ត្រចតុកោណ

នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា បានដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច ដើម្បីឱ្យកម្ពុជាឈានទៅសម្រេចបាននូវឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ គោលដៅយុទ្ធសាស្ត្រ ៤យ៉ាងគឺ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅតែចាំបាច់ និង សមស្របសម្រាប់កម្ពុជាអនុវត្តនៅក្នុង នីតិកាលទី៦ ឆ្នាំ២០១៨-២០២៣ ក្នុងគោលបំណង ១. ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ច ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ក្នុងរង្វង់ ៧% ប្រកបដោយចីរភាព និង ធន់នឹងវិបត្តិតាមការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចថ្មី ២. បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈ ការផ្តល់ជំនាញ, ព័ត៌មានទីផ្សារការងារ, ការកែលម្អលក្ខខណ្ឌការងារ, ការលើកកម្ពស់សកម្មភាពធុរកិច្ច, និង ការជំរុញការវិនិយោគ ទាំងក្នុងប្រទេស និង ក្រៅប្រទេស ៣. សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង១០% ៤. បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ, ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពនៃសេវាសាធារណៈ។

ស្នូលនៃយុទ្ធសាស្ត្រចតុកោណ-ដំនាក់កាលទី៤ គឺជាការបង្កើនល្បឿនការកែទម្រង់អភិបាលកិច្ចដោយផ្តោតសំខាន់លើ ១. ការកែទម្រង់ និង លើកកម្ពស់សមត្ថភាពស្ថាប័ន ២. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ៣. ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង ៤. ការព្រង្រឹងអភិបាលកិច្ចវិស័យឯកជន។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍ "ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន" ដោយការអភិវឌ្ឍធនធានមនុស្ស បន្តផ្តោតលើ ៖ ១. ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ២. ការបណ្តុះបណ្តាលជំនាញ បច្ចេកទេស ៣. ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ និង ៤. ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម ដើម្បីផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម - សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះរាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖ ១. ការបន្តលើកកម្ពស់យកចិត្តទុកដាក់លើគ្រូបង្រៀន ដោយបង្កើនការបណ្តុះបណ្តាល ២. ការពង្រីកវិសាលភាព ៣. ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន សំដៅធានានូវការបង្រៀនឱ្យបានពេញលេញទៅតាមកម្មវិធីសិក្សា និង បង្កើនគុណភាពអភិបាលកិច្ចសាលារៀន ដោយរៀបចំឱ្យមានយន្តការចូលរួមជាប្រចាំពីអ្នកពាក់ព័ន្ធ និង បង្កើតប្រអប់ទទួល

[24] ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០១៩-២០២៣។

ព័ត៌មាន, រៀបចំប្រព័ន្ធពិនិត្យ និង តាមដានដំណើរការសាលារៀន ព្រមទាំងរៀបចំប្រព័ន្ធឆ្លើយតបប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលាពីកម្រិតជាតិ ៤. ការធ្វើបច្ចុប្បន្នភាព និង ការជម្រុញការអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិសំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និងពង្រីកការអប់រំបច្ចេកទេសឱ្យមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស ៥. ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ និងការរស់នៅ ៦. ការរៀបចំក្របខណ្ឌកម្មវិធីសិក្សាគោល គ្រប់ជ្រុងជ្រោយ រួមទាំងការបញ្ចូល STEM និងវិទ្យាសាស្ត្រសង្គមគន្លឹះៗ សម្រាប់ឧត្តមសិក្សា ស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដារតំបន់ និងអន្តរជាតិ, ការពង្រឹងយន្តការទទួលស្គាល់គុណឧត្តមសិក្សា, ការបង្កើនចំនួនសាស្ត្រាចារ្យកម្រិតបណ្ឌិត ប្រកបដោយគុណភាពនៅឧត្តមសិក្សា, ការបង្កើនការវិនិយោគលើឧត្តមសិក្សា និង ការបង្កើនក្របខណ្ឌគោលនយោបាយជាតិ សំដៅអភិវឌ្ឍមូលនិធិអាហារូបករណ៍ និង ឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា, ការជម្រុញការអភិវឌ្ឍសមត្ថភាព និង ធនធានសម្រាប់គាំទ្រការរៀន ការបង្រៀន និងការសិក្សាស្រាវជ្រាវ, ការបង្កើតមូលនិធិសិក្សាស្រាវជ្រាវ និង យន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ, ព្រមទាំងការបង្កើតក្របខណ្ឌគោលនយោបាយជាតិស្តីពីអភិបាលកិច្ច និង ការគ្រប់គ្រងឧត្តមសិក្សា ៧. ការត្រៀមប្រកួតកីឡាស៊ីហ្គេម (SEA Games) ឆ្នាំ២០២៣ ដោយបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាសំខាន់ៗ, រៀបចំប្រភេទកីឡាអាទិភាព បណ្តុះបណ្តាលគ្រូបង្វឹក និង បច្ចេកទេសកីឡាកម្រិតខ្ពស់, ពង្រឹងការបណ្តុះបណ្តាល និង ការហ្វឹកហាត់កីឡាការ-កីឡាការិនីថ្នាល និង ជម្រុញចលនា "**យុវជនម្នាក់ ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត**" និង រៀបចំវិទ្យាសាស្ត្រសុខាភិបាលកីឡា ដើម្បីគាំទ្រដំណើរការប្រកួតកីឡាស៊ីហ្គេម ។

### ២.៤.២ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឱ្យឆ្លើយតបនឹងបរិបទសកលលោក និងថ្នាក់តំបន់ដែលមានមហិច្ឆតានឹងវិសាលភាពធំទូលាយជាងមុន សំដៅលើការកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ក្រសួងអប់រំយុវជន និងកីឡាបានអនុម័តផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ស្តីពីការអប់រំនៅកម្ពុជា នៅដើមឆ្នាំ២០១៩ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនទីបង្ហាញផ្លូវនេះបានកំណត់អាទិភាពគោលនយោបាយអប់រំធំៗចំនួន៥ គឺ ១) កុមារគ្រប់រូបទទួលបានការគាំពារនឹងអភិវឌ្ឍន៍កុមារតូច ការអប់រំកម្រិតមត្តេយ្យសិក្សា ការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានដោយឥត

បង់ថ្លៃនៅកម្រិតបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ ដោយទទួលលបានលទ្ធផលសិក្សាប្រកបដោយ គុណភាព ប្រសិទ្ធភាព សមធម៌ និងភាពឆ្លើតប ២) កុមារនិងយុវជនគ្រប់រូបបញ្ចប់ការសិក្សានៅកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាព និងភាពឆ្លើយតប ៣) ធានាឱ្យអ្នកសិក្សាគ្រប់រូបមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេសវិជ្ជាជីវៈ និងឧត្តមសិក្សាប្រកបដោយគុណភាព ៤) យុវជននឹងមនុស្សពេញវ័យគ្រប់រូបទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនព្វន្ត និងមានឱកាសកាន់តែច្រើនក្នុងការសិក្សាពេញមួយជីវិត ៥) អភិបាលកិច្ចនឹងការគ្រប់គ្រងវិស័យអប់រំ មានភាពល្អប្រសើរជាងមុននូវគ្រប់កម្រិត។

– គោលដៅនៃការអប់រំជាតិ គឺ៖

១. បណ្តុះមនសិការជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិ តាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ។

២. ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មាតី។

៣. ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិត និងសមត្ថភាព ដែលស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ដែលអាចប្រកួតប្រជែងនៅថ្នាក់តំបន់ និងសកលលោក។

៤. រៀបចំអ្នកសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងពឹងអាស្រ័យគ្នាទៅវិញទៅមក និងអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់នឹងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព។

ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា បានដាក់ចេញ នូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗឆ្ពោះទៅសម្រេចគោលដៅអប់រំ ឆ្នាំ២០៣០ ដូចខាងក្រោម ៖

- កម្ពុជាត្រូវមានប្រព័ន្ធអប់រំរឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។ ប្រព័ន្ធអប់រំ ត្រូវមានធនធានគ្រប់គ្រាន់ មានអភិបាលកិច្ចល្អ និងមានតុល្យភាព ដោយចាត់ទុកជា សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងស្តង់ដារគុណភាពខ្ពស់ជាគោលការណ៍សំខាន់របស់ខ្លួន។ ប្រព័ន្ធអប់រំត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយទូទាំងវិស័យដែលអនុវិស័យនីមួយៗ និងសមាសភាគទាំងអស់នៃប្រព័ន្ធអប់រំត្រូវឆ្លើយតបទៅនឹងតម្រូវការនៃការសិក្សាពេញមួយជីវិតនៅគ្រប់ដំណាក់កាលទាំងអស់នៃជីវិតតាមរយៈ

បង្កើតឱកាសក្នុងការសិក្សាគ្រប់បរិបទ និងទម្រង់ (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ) សម្រាប់ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់។

- ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្តល់នូវការអប់រំ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកបដោយគុណភាព ដើម្បីក្លាយជាចលករក្នុងការឈានទៅពេញសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ ក្រសួងត្រូវមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញមុខងារទាំងផ្នែកបច្ចេកទេសដូចជា ការរៀបចំផែនការ ការពិនិត្យតាមដាន ការអភិវឌ្ឍកម្មវិធីសិក្សាការបណ្តុះបណ្តាលគ្រូ ការវាយតម្លៃ អភិបាលកិច្ចវិស័យ។ល។ ក្រសួងរៀបចំ និងអនុវត្តគោលនយោបាយ ផែនការអប់រំ គោលបំណង ស្តង់ដារសម្រាប់គ្រប់កម្រិត គ្រប់សមាសភាគនៃការអប់រំ និងសម្របសម្រួលការគ្រប់គ្រងកំណែទម្រង់ដែលជាធាតុផ្សំផ្សេងៗ នៃវិស័យអប់រំ (រដ្ឋបាល កិច្ចការសិក្សាធិការ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស)។ ក្រសួងរៀបចំទិស ដៅនៃការអភិវឌ្ឍវិស័យអប់រំ ហើយធានាឱ្យបាននូវអភិបាលកិច្ចល្អសម្រាប់អ្នកផ្តល់សេវាអប់រំទាំងអស់ និងពិនិត្យតាមដានលទ្ធផលនៃប្រព័ន្ធអប់រំ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃការអប់រំរបស់ប្រទេស។ ប្រព័ន្ធនេះមានគោលបំណងធានាឱ្យបាននូវភាពប្រសើរឡើងលើការទទួលសេវាប្រកបដោយសមធម៌ គុណភាព និងភាពឆ្លើយតប ក៏ដូចជាអភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាគ្រប់ប្រទេសទាំងអស់នៅគ្រប់កម្រិតថ្នាក់។
- សាលារៀន គឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀននឹងទទួលបានការបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការរៀន បង្រៀនប្រកបដោយគុណភាពខ្ពស់ដោយប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។
- គ្រូបង្រៀនកម្ពុជាមានសមត្ថភាពទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។ ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្តទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុនវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រលាញ់ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ដើម្បីឱ្យការទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍិខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារបានល្អ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងសមត្ថភាពសម្រាប់លើកកម្ពស់

ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះគ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដារវិជ្ជាជីវៈ និងសីលធម៌ខ្ពស់បំផុត ដើម្បីធានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ។

- បន្ទប់រៀនកម្ពុជា ជាបន្ទប់វៃឆ្លាតដែលផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការរៀនសូត្រ។ បន្ទប់រៀនត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យាដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលដល់ការសិក្សាសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នាតាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបអន្តរកម្ម បែបសហការ និងវិធីសាស្ត្រចម្រុះ។
- សិស្សមានសុខភាពល្អមានការលើកទឹកចិត្ត និងមានការប្តេជ្ញាចិត្តសម្រាប់អនាគតរបស់កម្ពុជា។ កម្ពុជានឹងមានសិស្សដែលមានសុខភាពល្អ ត្រៀមខ្លួនបានល្អ និងទទួលបានការលើកទឹកចិត្តក៏ដូចជាប្តេជ្ញាចិត្តសិក្សារៀនសូត្រ ដោយមិនប្រកាន់ពីសាវតាខ្លួន និងទទួលបានបរិយាកាសសិក្សាដែលមានលក្ខណៈអំណោយផល។ សិក្សនឹងទទួលបានការគាំទ្រពីគ្រូបង្រៀនដែលមានសមត្ថភាព និងគុណវុឌ្ឍិវិជ្ជាជីវៈ ក៏ដូចជាពីសំណាក់សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ។ បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេនឹងមានជំនាញទាំងរឹង ទាំងទន់ ចេះធ្វើការវិនិច្ឆ័យប្រកបដោយក្រមសីលធម៌បានល្អមានភាពវៃឆ្លាតខាងអារម្មណ៍ ក៏ដូចជាមានស្មារតីជាតិ និងភាពជាប្រជាពលរដ្ឋសកលក្នុងកម្រិតមួយខ្ពស់ ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចរួមចំណែក និងចូលរួមក្នុងសង្គមយ៉ាងសកម្ម។

អាទិភាពគោលនយោបាយទាំងនេះ នឹងត្រូវអនុវត្តតាមដំណាក់កាលនីមួយៗនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ រហូតដល់ឆ្នាំ២០៣០ ដើម្បីឈានទៅសម្រេចគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំនៅកម្ពុជា ដោយមានកំណត់យន្តការ យុទ្ធសាស្ត្រ និងកម្មវិធី ព្រមទាំងការគាំទ្រហិរញ្ញវត្ថុសម្រាប់ការអនុវត្តផងដែរ។

### ២.៤.៣ ចក្ខុវិស័យ បេសកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា

**ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា** គឺកសាង និង អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

**បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា** ៖ ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសាកលលោក។

**វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា** គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និង បណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមនសិការស្នេហាជាតិ មោទនភាពជាតិ សីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

**វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា** គឺធានាថាយុវជន និងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព គុណធម៌ និងសីលធម៌ល្អ ស្របតាមស្តង់ដារមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជម្រុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

### ២.៤.៤ គោលនយោបាយអប់រំរយៈពេលមធ្យម

ក្នុងគោលបំណងរួមចំណែកសម្រេចយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ រាជរដ្ឋាភិបាល និងអាទិភាពគោលនយោបាយនៃផែនទីបង្ហាញផ្លូវសម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានប្តូរគោលនយោបាយអប់រំពី បី មកត្រឹមពីរក្នុងផែនការយុទ្ធសាស្ត្រវិស័យអបរំ ២០១៩-២០៣០ ដូចខាងក្រោម ៖

- គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និង លើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

**វត្ថុបំណងគោលនយោបាយទី១** ៖ កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត ព្រមទាំងផ្តល់នូវជម្រើសផ្សេងទៀតដល់កុមារ និងយុវជនដែលពុំមានលទ្ធភាពទទួលបានសេវាអប់រំក្នុងប្រព័ន្ធ។ កុមារ យុវជនគ្រប់រូបទទួលបានលទ្ធផលសិក្សានៅគ្រប់កម្រិតប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ជាពិសេសកុមារមកពីគ្រួសារជួបការលំបាក យុវជនក្រៅសាលា និងទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេស បំណិនគិត និងបំណិនអរូបវន្ត ឆ្លើយតបនឹងបរិបទសង្គមពុទ្ធិ និងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សាត្រូវមានការគាំទ្រ និងចូលរួមពីមាតាបិតា សហ

គមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេចការពិនិត្យតាមដាន និងរបាយការណ៍។

**វត្ថុបំណងគោលនយោបាយទី២** ៖ ការផ្តល់សេវាអប់រំអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយភាពស័ក្តិសិទ្ធិផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ ពេលវេលាការពិនិត្យតាមដាន និងរបាយការណ៍សមិទ្ធកម្ម និងយោបល់ត្រឡប់វិធានការប្រកបដោយគណនេយ្យភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយយុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ត្រូវបង្កើនស្វ័យភាព និងទទួលខុសត្រូវគណនេយ្យភាពចំពោះលទ្ធផលនៃការសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។

**២.៤.៥ ការជម្រុញលើវិស័យបច្ចេកវិទ្យា** E-learning, EDU 4.0

បច្ចុប្បន្ន ដោយសារតែប្រទេសកម្ពុជាជាប្រទេសមួយដែលមានសក្តានុពលខ្ពស់ក្នុងការក្តាប់យកនូវកាលានុវត្តភាព ពីបដិវត្តន៍ឧស្សាហកម្ម០.៤ និងសេដ្ឋកិច្ចឌីជីថល ដែលកំពុងផុលផុសឡើងក្នុងបរិបទសកល និង បរិបទតំបន់។ ដោយសារវឌ្ឍនភាពនៃបច្ចេកវិទ្យាឌីជីថលមានសន្ទុះលឿន ដូច្នេះប្រទេសកម្ពុជាត្រូវពិនិត្យឡើងវិញ និងរៀបចំប្រព័ន្ធនៃការអប់រំ ការបណ្តុះបណ្តាល និងការបញ្ជ្រាបការយល់ដឹងអំពីបច្ចេកវិទ្យាឌីជីថលឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព ដើម្បីធ្វើឱ្យយុវជនជំនាន់ក្រោយមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទាញយកប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗនិងទីផ្សារឌីជីថល យោងតាមប្រសាសន៍សម្តេចក្រឡាហោម។ បន្ថែមលើសពីនេះកម្ពុជាក៏ត្រូវពិនិត្យឡើងវិញនូវការគាំទ្រ និងតម្រង់ទិសនៅកម្រិតឧត្តមសិក្សាឱ្យឆ្ពោះទៅរកការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីពង្រឹងសមត្ថភាព និងជំនាញរបស់ធនធានមនុស្សនៅកម្ពុជាឱ្យសមស្របទៅនឹងបរិបទថ្មីនៃការអភិវឌ្ឍផងដែរ។[25]

ពីមួយជំនាន់ទៅមួយជំនាន់ ក៏ដូចជាក្នុងពេលបច្ចុប្បន្នការសិក្សាគឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីកសាង និងអភិវឌ្ឍន៍ប្រទេសជាតិប្រកបដោយប្រសិទ្ធភាព។ ហេតុដូចនេះហើយទើបមាននូវការធ្វើកំណែទម្រង់លើប្រព័ន្ធអប់រំជារឿយៗ ទៅតាមសម័យកាលនីមួយៗដើម្បីឱ្យស្របទៅនឹងស្ថានការណ៍នៃយុគ្គសម័យទាំងនោះ។ រហូតមកដល់សម័យបច្ចុប្បន្ន យើងឃើញថាក្រសួងអប់រំយុវជន និងកីឡា បានយកចិត្តទុកដាក់យ៉ាងខ្លាំងមកលើវិស័យអប់រំ ជាពិសេសគឺក្រសួងបានបង្ហាញឱ្យឃើញថាការជម្រុញការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាយន្តការណ៍ដ៏មានប្រសិទ្ធភាពដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យឆ្លើយតបទៅនឹងយុគ្គសម័យបដិវត្តន៍ឧស្សាហកម្ម៤.០។

[25] ក្រសួងមហាផ្ទៃ, សម្តេចក្រឡាហោម ស ខេង ជំរុញដល់លោកគ្រូ អ្នកគ្រូ ក៏ដូចជាសាស្ត្រាចារ្យទាំងអស់ត្រូវពង្រឹងសមត្ថភាពរបស់ខ្លួនឱ្យស្របតាមយុគសម័យឌីជីថល, [https://interior.gov.kh/news/detail/1176] (ចូលទស្សនាថ្ងៃទី២៣ កក្កដា ២០២១)។

ដើម្បីឆ្លើយតបបដិវត្តន៍ឧស្សាហកម្ម៤.0 គឺមិនអាចខ្វះបានទេក្នុងការពង្រីកព្រំដែននៃការសិក្សា និងបង្កើតច្រកទ្វានៃការរៀនសូត្រក្នុងបរិបទសម័យភាវូបនីយកម្មនេះ។ បើតាមបណ្ឌិតសភាចារ្យហង់ជួនណារុង លោកបានបញ្ជាក់ថា ចាប់ពីពេលនេះតទៅ បច្ចេកវិទ្យា ជាផ្នែកមួយសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាល។ ជាក់ស្តែង ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតបណ្ណាល័យអេឡិចត្រូនិក ឬ E-library ដែលមានឯកសម្រាប់ស្រាវជ្រាវរាប់ពាន់ក្បាល និងមេរៀនរាប់ពាន់ប្រភេទ។

កាលពីឆ្នាំ ២០១៣ តាមរយៈ ផែនការគោល ICT ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតកម្មវិធីសិក្សាលម្អិតបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបណ្តុះបណ្តាលគរុសិស្ស និងបានផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈផ្អែកលើ ICT ទៅដល់បានប្រមាណជា ៨០% នៃគ្រូមធ្យមសិក្សាទុតិយភូមិ ដែលបង្រៀនកុំព្យូទ័រនៅវិទ្យាល័យដែលមានបន្ទប់កុំព្យូទ័រសម្រាប់ បង្រៀនសិស្សដែលជួយបង្កើនសមត្ថភាពសិស្សព្រមទាំងជួយឱ្យពួកគេអាចសម្របខ្លួនទៅនឹងមជ្ឈដ្ឋានការងារបច្ចុប្បន្នក្នុងសម័យបច្ចេកវិទ្យាព័ត៌មាន ហើយក៏បានបញ្ចៀបបំណិនត្រិះរិះគិតយ៉ាងចាំបាច់ផងដែរ។[26]

នៅក្នុងឆ្នាំ ២០១៨ ក្រសួងអប់រំ យុវជន និងកីឡាបានអនុមតិ"គោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ក្នុងវិស័យអប់រំ"។[27]

បើយោងតាមប្រសាសន៍របស់ ឯកឧត្តម បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងបទសម្ភាសន៍ស្តីពី «ការអប់រំតាមបែបឌីជីថល» ថា ក្រសួងបានដាក់ចេញនូវកម្មវិធីសិក្សាថ្មីមួយ គឺសាលារៀនជំនាន់ថ្មី ក្នុងបំណងធ្វើឱ្យការអប់រំនៅកម្ពុជាកាន់តែល្អប្រសើរ ដូចទៅនឹងប្រទេសមួយចំនួន ក្នុងតំបន់ និងលើពិភពលោក ហើយក្នុងពេលបច្ចុប្បន្នមានសាលាចំនួន១០ហើយ កំពុងដាក់ឱ្យអនុវត្តកម្មវិធីសិក្សាសាលារៀនជំនាន់ថ្មីនេះ ។ ក្នុងនោះសាលាបឋមសិក្សាមានចំនួន៤ និងសាលាមធ្យមសិក្សាមានចំនួន៦ ។ កម្មវិធីសិក្សានេះ ត្រូវបានយកចិត្តទុកដាក់ខ្ពស់ លើការបញ្ចូលប្រព័ន្ធបច្ចេកវិទ្យាទៅក្នុងការអប់រំ ទាំងអ្នករៀន និងអ្នកបង្រៀន ព្រមទាំងបំពាក់នូវឧបករណ៍សិក្សាសម្បូរបែប ។[28]

---

[26] ក្រសួងអប់រំ យុវជន និងកីឡា, "សេចក្តីប្រកាសព័ត៌មានស្តីពី កម្មវិធីសាលារៀនបើកចំហ ជំហាន២", រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣។

[27] បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុង, កំណែទម្រង់សាលារៀននៅកម្ពុជា, ២០២០។

[28] ក្រសួងអប់រំ យុវជន និងកីឡា, រដ្ឋមន្ត្រីក្រសួងអប់រំ ជំរុញដល់សិស្សានុសិស្ស បង្កើនស្វ័យសិក្សាក្នុងយុគសម័យឌីជីថល។

# ជំពូកទី៣

# វិស័យអប់រំនៅក្នុងអំឡុង
# ពេលការរីករាលដាលនៃ
# ជម្ងឺកូវីដ-១៩

# ជំពូកទី៣

# វិស័យអប់រំនៅក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩

## ៣.១ អំពីស្ថានភាពទូទៅនៃជម្ងឺកូវីដ-១៩នៅក្នុងប្រទេសកម្ពុជា

បើយោងទៅតាមការអង្គការយូនីហ្វេស វីរុសកូរ៉ូណាប្រភេទថ្មី (CoV) គឺជាវីរុសថ្មីនៃអម្បូរវីរុសកូរ៉ូណា ហើយជម្ងឺដែលបង្កដោយវីរុសកូរ៉ូណាប្រភេទថ្មីនេះ ត្រូវបានគេរកឃើញដំបូងនៅក្នុងទីក្រុងវូហ៊ាន ប្រទេសចិន ដែលត្រូវបានគេដាក់ឈ្មោះថា ជម្ងឺវីរុសកូរ៉ូណាឆ្នាំ២០១៩ (កូវីដ-១៩/COVID-19) ដែលពាក្យកាត់ "CO" តំណាងឱ្យពាក្យ corona (កូរ៉ូណា) "VI" តំណាងឱ្យពាក្យ virus (វីរុស) និង "D" តំណាងឱ្យពាក្យ disease (ជម្ងឺ)។[29]

ជម្ងឺកូវីដ-១៩ នេះបានរីករាលដាលយ៉ាងឆាប់រហ័សពីប្រទេសមួយ ទៅប្រទេសមួយដែលវាបានក្លាយជាបញ្ហាដ៏ធំមួយដែលពិភពលោកកំពុងតែប្រឈម។

នៅក្នុងប្រទេសកម្ពុជា សេចក្តីប្រកាសព័ត៌មានលើកដំបូងរបស់ក្រសួងសុខាភិបាលស្តីពី ករណីវិជ្ជមានវីរុសកូរ៉ូណាថ្មី ១ករណីនៅខេត្តព្រះសីហនុ និងវិធានការការពារជម្ងឺរលាកសួតដោយវីរុសកូរ៉ូណា(2019-nCoV)គឺនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ ដែលមានអ្នកដំណើរជនជាតិចិត្តចំនួន៤នាក់មានវិជ្ជមាននូវវីរុសមួយនេះ ។ នេះរាប់ថាជាករណីជម្ងឺកូវីដដំបូងបង្អស់ដែលមាននៅក្នុងប្រទេសកម្ពុជា។[30]

បន្តបន្ទាប់មកទៀតប្រទេសកម្ពុជាចាប់ផ្តើមរកឃើញនូវអ្នកដំណើរដែលវិជ្ជមានកូវីដ-១៩ នេះជាហូរហែរ ដែលក្នុងនោះដែរ ប្រទេសកម្ពុជាបានរកឃើញនូវករណីឆ្លងទី៦ និងទី៧ ដែល ជាករណីដំបូងផងដែរដែលត្រូវបានរកឃើញនៅរាជធានីភ្នំពេញ និងបានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ នៅខេត្តសៀមរាបកាលពីដើមខែមីនា ឆ្នាំ២០២០ ផងដែរ ។ បន្ទាប់មកក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចប្រកាសបិទទ្វាសាលារៀនក្នុងរាជធានីភ្នំពេញ និងទីក្រុងសៀមរាប ទាំងរដ្ឋ និងឯកជន ដោយដាក់ឱ្យចូលវិស្សមកាល ឬឈប់សម្រាកមុនកាលកំណត់ ។[31]

---

[29] https://www.unicef.org/cambodia/coronavirus-disease-covid-19-what-parents-should-know, ចូលទស្សនាថ្ងៃទី១ ខែឧសភា ឆ្នាំ ២០២១

[30] វីរុសកូរ៉ូណា (កូវីដ១៩/COVID19)៖ ចំណេះដឹងឪពុកម្តាយគួរស្វែងយល់, [https://www.unicef.org/cambodia/coronavirus-disease-covid-19-what-parents-should-know] (ចូលទស្សនាថ្ងៃទី២៤ កក្កដា ២០២១)។

[31] សុខ ខេមរា, ថ្ងៃទី15 ខែមីនា ឆ្នាំ2020, VOA, "កម្ពុជាប្រកាសបិទសាលាក្នុងក្រុងសំខាន់ចំនួនពីរដើម្បីទប់ស្កាត់វីរុសកូរ៉ូណា", [https://khmer.voanews.com/a/cambodia-closes-all-schools-in-two-big-cities-amid-coronavirus-outbreak/5329023.html] (ចូលទស្សនាថ្ងៃទី ២៤ កក្កដា ២០២១)។

### ៣.១.១ មុនពេលឆ្លងជាសហគមន៍

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ បានបញ្ជាក់ថាៈ «យោងតាមរបាយការណ៍ស្ថានភាពរាតត្បាតនៃវីរុសកូវីដ-១៩ របស់អង្គការសុខភាពពិភពលោក (WHO) និងពេលថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាបានរកឃើញជាបន្តបន្ទាប់នូវវីរុសកូវីដ-១៩ លើជនបរទេសមានសញ្ជាតិផ្សេងៗ ដែលតម្រូវឱ្យមានវិធានការការពារទប់ស្កាត់ជាបន្ទាន់ ក្រសួងសូមណែនាំគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន នៅរាជធានីភ្នំពេញ និងក្រុងសៀមរាបត្រូវចាប់អនុវត្តវិស្សមកាលតូចមុន កាលកំណត់ពីថ្ងៃចេញសេចក្តីប្រកាសព័ត៌មាននេះ រហូតដល់ពេលចូលរៀនឡើងវិញ»។ ជាបន្តបន្ទាប់មកទៀត ក្រៅពីសាលារៀនខេត្តសៀមរាប និងក្នុងទីក្រុងភ្នំពេញ ក្រសួងអប់រំយុវជននិងកីឡាបានធ្វើការបិទនៅទូទាំងប្រទេសតែម្តងនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

ការបិទសាលារៀនបានបន្តធ្វើឡើងរហូតដល់ក្នុងអំឡុងខែកញ្ញា ឆ្នាំ២០២០ ដែលស្ថានភាព ជម្ងឺកូវីដ-១៩ មានភាពល្អប្រសើរឡើងវិញ ទើបក្រសួងអប់រំ យុវជន និងកីឡា សម្រេចប្រកាសឱ្យសាលារៀនរដ្ឋ និងឯកជនបើកដំណើរការឡើងវិញ ។

### ៣.១.២ អំឡុងពេលឆ្លងជាសហគមន៍

បន្ទាប់ពីស្ថានភាពនៃជម្ងឺកូវីដ-១៩ បានមានភាពល្អប្រសើរឡើងវិញ សាលារៀនចាប់ផ្តើមបើកឡើងវិញ សិស្សអាចទៅរៀននៅក្នុងសាលាបានជាធម្មតា អាជីវកម្មផ្សេងៗក៏បានបើកដំណើរការឡើងវិញផងដែរ បន្ទាប់ពីកន្លែងមួយចំនួនដែលត្រូវបានបិទក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ ក្នុងករណីនាំចូលពីក្រៅប្រទេស និងមានការឆ្លងក្នុងសហគមន៍ទ្រង់ទ្រាយតូចចំនួនពីរដងនោះ។

ករណីឆ្លងជម្ងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាគឺកើតមានករណីដំបូងកាលពីដើមឆ្នាំ២០២០ ហើយក៏បានស្ងប់ស្ងាត់ទៅវិញនៅអំឡុងចុងឆ្នាំ២០២០ ផងដែរ មុនពេលកើតមាននូវករណីឆ្លងជាសហគមន៍ទ្រង់ទ្រាយធំនៅថ្ងៃទី២០ កុម្ភះ ឆ្នាំ២០២១ ដែលរាប់ថាជាការឆ្លងក្នុងសហគមន៍លើកទី៣ផងដែរ។

កាលពីដើមឆ្នាំ២០២១ នៅថ្ងៃទី២០ ខែកុម្ភះនៅក្នុងប្រទេសកម្ពុជាបានផ្ទុះមាននៅករណីឆ្លង ជម្ងឺកូវីដ-១៩ឡើងម្តងទៀត បន្ទាប់ពីមានភាពស្ងប់ស្ងាត់អស់រយៈពេលជាច្រើនខែមកហើយ ដែលរាប់ជា « ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ » នេះបើយោងតាមប្រសាសន៍របស់សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន ក្នុងសេចក្តីថ្លែងការណ៍ពិសេស កាលពីថ្ងៃទី២០ ខែកុម្ភះ ២០២១។[32]

[32] ស្តីការគណៈរដ្ឋមន្ត្រី, សេចក្តីថ្លែងសារពិសេស សម្តេចតេជោ ហ៊ុន សែន ទៅកាន់បងប្អូនជនរួមជាតិទូទាំងប្រទេស ពាក់ព័ន្ធនឹងករណីជំងឺកូវីដ-១៩ ឆ្លងចូលសហគមន៍« ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ » (2021), [https://pressocm.gov.kh/archives/69825] (ចូលទស្សនាថ្ងៃទី២៤ កក្កដា ២០២១)។

ក្រោយមានមានផ្ទុះឡើងនូវព្រឹត្តិការណ៍២០កុម្ភៈមក ស្ថានភាពការរីករាលដាលនៃជម្ងឺកូវីដ-១៩ កាន់តែមានសភាពតឹងតែងឡើងៗដែលបណ្ដាលឱ្យក្រសួងអប់រំ យុវជន និងកីឡាសម្រេចធ្វើការប្រកាសបិទសាលារៀនគ្រប់កម្រិត ទាំងសាធារណៈ និងឯកជនទាំងអស់នៅទូទាំងប្រទេសចាប់ពីថ្ងៃទី២០ខែមីនាតទៅ ដោយមិនកំណត់ពេលជាក់លាក់ ហើយការប្រកាសបិទសាលារៀនទូទាំងប្រទេសជាថ្មីទៀតនេះ គឺដោយសារតែជំងឺកូវីដ-១៩បានបន្តឆ្លងរាលដាលទៅដល់ខេត្ត-ក្រុងមួយចំនួន ខណៈព្រឹត្តិការណ៍សហគមន៍២០កុម្ភៈមិនទាន់អាចគ្រប់គ្រងបាន ។[33]

## ៣.២ ការបិទសាលា

ជាការពិតណាស់ នេះគឺព្រឹត្តិការណ៍ថ្មីមួយសម្រាប់ពិភពលោកហើយក៏សម្រាប់ប្រទេសកម្ពុជាយើងផងដែរ ដែលសាលារៀននៅទូទាំងប្រទេសត្រូវបានបិទទ្វា ហើយការបង្រៀនត្រូវបានផ្លាស់ប្ដូរភ្លាមៗមកធ្វើការសិក្សាតាមប្រព័ន្ធអនឡាញ(E-learning) ដោយសារតែមានការរាតត្បាតពីជម្ងឺកូវីដ-១៩។

ជាក់ស្ដែងដូចដែលបានរៀបរាប់នូវចំណុច ៣.១ ម្ដងរួចមកហើយទាក់ទងនឹងស្ថានភាពជម្ងឺកូវីដ-១៩នៅក្នុងប្រទេសកម្ពុជា គឺបានបង្ហាញឱ្យឃើញថា ករណីវិជ្ជមានជម្ងឺកូវីដ-១៩ករណីដំបូងដែលមាននៅក្នុងប្រទេសកម្ពុជាគឺមាននៅក្នុងក្រុងព្រះសីហនុ ដែលជាករណីនាំចូលពីខាងក្រៅប្រទេស។ ហើយសម្រាប់ប្រទេសកម្ពុជាចំពោះករណីរីករាលដាលនៃជម្ងឺនេះផងដែរ គឺចាប់ផ្ដើមកើតមានជាបន្តបន្ទាប់រហូតធ្វើឱ្យមានការបិទសាលា នៅតាមតំបន់ដែលមានការរាតត្បាតដោយជម្ងឺនេះ និងបានឈានទៅដល់ការបិទសាលានៅទូទាំងប្រទេសទាំងមូលផងដែរ។ ហើយចំពោះការបិទសាលានៅក្នុងប្រទេសកម្ពុជា គឺត្រូវបានធ្វើឡើងដល់ទៅពីរដងគិតចាប់ពីឆ្នាំដើមឆ្នាំ២០២០ និងឆ្នាំ២០២១នេះ ដែលការពិតលើកទីមួយត្រូវបានបញ្ចប់ទៅវិញនៅអំឡុងចុងឆ្នាំ២០២០ ដោយសារស្ថានភាពនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ត្រូវបានប្រសើរឡើងវិញ។ ប៉ុន្តែឈានចូលមកដល់ដើមឆ្នាំ២០២១ នៅក្នុងខែមីនា ប្រទេសកម្ពុជាគឺមានការឆ្លងរីករាលដាលជាសហគមន៍សារជាថ្មីម្ដងទៀត ដែលស្ថានភាពថ្មីនេះមានការឆ្លងច្រើនជាងពេលមុនៗដែលជាហេតុធ្វើឱ្យសាលារៀនត្រូវផ្អាកសារជាថ្មីម្ដងទៀត និងធ្វើការបន្តការសិក្សាពីចម្ងាយ(Online)។

### ៣.២.១ ការបិទសាលាតាមតំបន់

សាលាក្នុងតំបន់មួយចំនួននៅក្នុងប្រទេសកម្ពុជាត្រូវបានបិទ និងផ្លាស់ប្ដូរបរិបទមកសិក្សាតាមប្រព័ន្ធអ៊ិនធីណេតវិញ នៅពេលដែលតំបន់ទាំងនោះមានការរាតត្បាតចូលនៃជម្ងឺកូវីដ-១៩។ ជាក់ស្ដែងសាលារៀននៅក្រុងសៀមរាបត្រូវបិទទ្វា បន្ទាប់ពីរកឃើញបុរសម្នាក់ មានវិជ្ជមានកូវីដ-១៩ ខណៈ ៤៧ នាក់កំពុងស្ថិតក្រោមការពិនិត្យកាលពីដើមឆ្នាំ២០២០កន្លងទៅ ហើយនេះគឺជាករណីទីមួយដែលវិជ្ជមានទៅលើជនជាតិខ្មែរផងដែរ ប៉ុន្តែបើ

[33] អ៊ឹង ប៊ុនថន, ក្រសួងអប់រំសម្រេចបិទសាលារៀនទូទាំងប្រទេស ខណៈកូវីដ១៩បន្តឆ្លងរាលដាលដល់ខេត្ត-ក្រុង (២០២១),rfi ។

យោងតាម លោក **រស់ សុវាចា** អ្នកនាំពាក្យក្រសួងអប់រំ បញ្ជាក់ថា "ការបិទសាលារៀនបណ្តោះអាសន្ននោះធ្វើឡើងតែសម្រាប់សាលាដែលស្ថិតនៅក្រុងសៀមរាបប៉ុណ្ណោះមិនមែននៅទូទាំងខេត្តនោះទេ"។ ក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីប្រកាសព័ត៌មាន ជូនដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ មាតាបិតា អាណាព្យាបាល សិស្សានុសិស្ស និងសាធារណជនទាំងអស់ថា គ្រឹះស្ថានសិក្សាសាធារណៈទាំងរដ្ឋ និងឯកជនទាំងអស់នៅក្រុងសៀមរាប ខេត្តសៀមរាបត្រូវបិទទ្វាផ្អាកការសិក្សាបណ្តោះអាសន្នចាប់ពីថ្ងៃទី ៧ មីនាតទៅរហូតដល់មានការជូនដំណឹងជាថ្មី។

ស្រដៀងគ្នានេះក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាសអំពីការផ្អាកបណ្តោះអាសន្ននូវការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វីជ្ជាជីវៈ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលនៃទីភ្នាក់ងារជ្រើសរើសឯកជនដែលស្ថិតក្រោមឱសានវាទក្រសួងការងារនៅក្រុងសៀមរាប ខេត្តសៀមរាបផងដែរ។ វិធានការនេះធ្វើឡើងបន្ទាប់ពីក្រសួងសុខាភិបាលកាលពីល្ងាចថ្ងៃសៅរ៍បានប្រកាសថា បុរសម្នាក់អាយុ ៣៨ ឆ្នាំដែលមានប្រវត្តិប៉ះពាល់ផ្ទាល់ជាមួយជនជាតិជប៉ុនអាយុ ៤០ ឆ្នាំមានផ្ទុកវីរុសកូវីដ-១៩ ។

ក្រោយពីមានការរីរាលដាលនៅក្នុងតំបន់មួយចំនួនក្នុងខេត្តសៀមរាប ជម្ងឺកូវីដ-១៩ បានគឺបានរកឃើញមាននៅក្នុងទីក្រុងភ្នំពេញ ដែលក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការប្រកាសព័ត៌មានស្តីពីការអនុវត្តវិស្សមកាលតូចមុនកាលកំណត់ សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈនិងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាបផងដែរ។

ក្នុងស្ថានការរីករាលដាលនៃជម្ងឺកូវីដ-១៩មានស្ថានភាពអាចគ្រប់គ្រងបែបនេះ ការបិទសាលាគឺធ្វើឡើងនៅតាមតែតំបន់ណាដែលមានការផ្ទុះរាតត្បាតនៃជម្ងឺនេះតែប៉ុណ្ណោះ ចំណែកឯតំបន់ផ្សេងទៀតដែលគ្មានហានិភ័យ សាលានៅបើកឱ្យសិស្សទៅរៀនផ្ទាស់ជាធម្មតា។ បន្តរហូតមកដល់ក្នុងឆ្នាំ២០២១ ការបិទសាលាបានធ្វើឡើងសារជាថ្មីម្តងទៀតដែលផ្តើមឡើងពីការបិទនៅតាមតំបន់ដែលមានការឆ្លងជម្ងឺនេះ ទៅតាមស្ថានភាពនៃការឆ្លងនៅតាមកន្លែងក៏ដូចជាតំបន់នីមួយៗ មុនពេលឈានទៅដល់ការបិទសាលាទូទាំងប្រទេសតែម្តង។

### ៣.២.២ ការបិទសាលាទូទាំងប្រទេស

តាមរយៈសេចក្តីណែនាំលេខ ១៣ អយក សណន ស្តីពី ការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់ សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធាណៈនឹងឯកជន នៅទូទាំងប្រទេស ក្រោយពីស្ថានភាពនៅនៃការរាតត្បាតរបស់ជម្ងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាមានសភាពកាន់តែអាក្រក់ឡើង ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការសម្រេចចេញសេចក្តីប្រកាសក្នុងការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជននៅទូទាំងប្រទេស កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដែលនេះគឺជាការបិទសាលាក្នុងដំណាក់កាលលើ

ទី១ សម្រាប់ប្រទេសកម្ពុជានៅទូទាំងប្រទេស ដោយសារតែមានការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដែលជាហេតុធ្វើឱ្យមានការមានការរាំងស្ទះដល់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយការប្រឡងត្រូវបានលើកពេលក្នុងការប្រឡងអស់ចំនួន៣ដង ហើយចុងបញ្ចប់គឺមិនមានការប្រឡងត្រូវបានធ្វើឡើងឡើយ, សិស្សទាំងអស់ត្រូវបានឱ្យជាប់ជាស្ថាបពរតែម្តង ដោយសារតែស្ថានភាពនៃការឆ្លងជម្ងឺកូវីដ-១៩ មិនមានភាពប្រសើរឡើង។ សិស្ស និស្សិត ក៏ដូចជាគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាត្រូវបានផ្លាស់ប្តូរបរិបទក្នុងការសិក្សាបែបថ្មីគឺការសិក្សាតាមអនឡាញ រហូតដល់មានការជូនដំណឹងសារជាថ្មីអំពីការបើកដំណើរការគ្រឹះស្ថានសិក្សាម្តងទៀត។[34]

ក្រោយពីស្ថានភាពល្អឡើងវិញ សាលាត្រូវបានបើដំណើរការឡើងវិញហើយសិស្ស និស្សិត ត្រូវបានអនុញ្ញាតឱ្យចូលរៀនផ្ទាល់ក្នុងសាលារៀនឡើងវិញមិនទាន់បានស្រួលបួលផង ការផ្ទុះនៃការឆ្លង ជម្ងឺកូវីដ-១៩ ត្រូវបានលេចឡើងសារជាថ្មីម្តងទៀតកាលពីអំឡុងខែមីនា ឆ្នាំ២០២១។

ការសិក្សាពីចម្ងាយតាមរយៈប្រព័ន្ធអនឡាញ(E-learning) ត្រូវចាប់ផ្តើមឡើងជាថ្មីម្តងទៀតដោយសារតែសាលារៀនចាប់ផ្តើមធ្វើការបិទជាបណ្តើរដែលចាប់ផ្តើមពីទីក្រុងភ្នំពេញ រហូតនៅតាម បណ្តាខេត្តដែលមានការឆ្លងជម្ងឺនេះ ហើយក៏បានឈានចូលដល់ការប្រកាសស្តីពីការផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន គ្រប់កំរិតជាបណ្តោះអាសន្ន នៅទូទាំងប្រទេសជាថ្មីម្តងទៀត កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២១។ ត្បិតតែសាលារៀននៅទូទាំងប្រទេសត្រូវបានបិទ ហើយសិស្ស និស្សិត ក៏ដូចជាគ្រូ ត្រូវធ្វើការសិក្សា និងបង្រៀនពីចម្ងាយតាមអនឡាញក្តី តែក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកយ៉ាងខ្លាំងមកការការផ្លាស់ប្តូរថ្មីនេះ ដោយចាប់ផ្តើមបង្កើតនូវកម្មវិធីសិក្សាថ្មីៗ ធ្វើយ៉ាងណាដើម្បីឱ្យស្របទៅនឹងបរិបទថ្មីនេះ ហើយដើម្បីឱ្យសិស្ស និស្សិតនៅទូទាំងប្រទេសទទួលបាននូវមេរៀនប្រកបដោយប្រសិទ្ធភាពផងដែរ។

## ៣.៣ ការផ្លាស់ប្តូរបរិបទនៃការសិក្សាពីចម្ងាយ (Online study) ក្នុងវិស័យរដ្ឋ

ជម្ងឺរាតត្បាតកូវីដ-១៩ គឺជាគ្រោះមហន្តរាយមួយក្នុងចំណោមគ្រោះមហន្តរាយអាក្រក់បំផុតដែលពិភពលោកធ្លាប់បានជួបប្រទះកន្លងមក។ វាបានសម្លាប់ជីវិតមនុស្សអស់ជាច្រើននាក់ ហើយមិនត្រឹមតែធ្វើឱ្យសេដ្ឋកិច្ចពិភពលោកឈានទៅរកភាពជាប់គាំងប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្កឱ្យមានការរឹតត្បិតក្នុងការធ្វើដំណើរជាសកលដែលមិនធ្លាប់មានពីមុនមកដែលប៉ះពាល់ដល់ចលនារបស់មនុស្ស និងទំនិញនៅទូទាំងពិភពលោក។ គិតត្រឹមថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ប្រជាជនទៅទាំងពិភពលោក ១១៨,៦២៣,០៣៤លាននាក់បានឆ្លងវីរុសមួយនេះ

[34] សេចក្តីណែនាំស្តីពីការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់ សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជន នៅទូទាំងប្រទេស ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០។

(កូវីដ-១៩)។ ក្នុងចំណោមនោះមានមនុស្ស ៤,០៦៥,៩០១លាននាក់បានស្លាប់ហើយប្រហែលជា ១៧២,៤៤០,៩៥៤ លាននាក់បានជាសះស្បើយ។[35]

ដោយសារតែការរីករាលដាលនៃជម្ងឺកូវីដ-១៩ បានបង្ខំឱ្យសាលាមធ្យមសិក្សា ក៏ដូចជាសាលកវិទ្យាល័យនានាជាច្រើននៅលើពិភពលោកបិទទ្វា ហើយផ្លាស់ប្ដូរបរិបទពីការសិក្សាផ្ទាល់ក្នុងសាលា មករៀនពីចម្ងាយតាមប្រព័ន្ធអនឡាញវិញ ដែលនេះជាព្រឹត្តិការណ៍ថ្មីមួយដែលពិភពលោកមិនធ្លាប់ជួបប្រទះពីមុនមក ឡើយ។ ចាប់តាំងពីខែមីនាឆ្នាំ ២០២១ ស្ថាប័នអប់រំទាំងអស់នៅក្នុងប្រទេសកម្ពុជាត្រូវបានបញ្ជាឱ្យធ្វើបិទ ហើយការសិក្សាត្រូវបានផ្លាស់ប្ដូរមកសិក្សាតាមអ៊ិនធឺណេតម្ដងទៀត បន្ទាប់ពីការបិទសាលាលើកទីមួយដែលបានធ្វើឡើងក្នុងខែមីនា ឆ្នាំ២០២០។[36] ដោយសារតែជំងឺរាតត្បាតសិស្ស និងគ្រូទាំងអស់ត្រូវបានតម្រូវឱ្យសម្របខ្លួនទៅនឹងកម្មវិធីថ្មីនៃរៀន និងបង្រៀនដែលធ្វើឱ្យពួកគេប្រឈមនឹងការលំបាកនិងឧបសគ្គជាច្រើន។

### ៣.៣.១ ភាពប្រឈម

ការរីករាលដាលនាំជម្ងឺកូវីដ-១៩ បានបង្ខំឱ្យគ្រឹះស្ថានសិក្សានានានៅទូទាំងពិភពលោករួមទាំងនៅក្នុងប្រទេសកម្ពុជាផ្លាស់ប្ដូរពីការរៀនទល់មុខគ្នា ឬ ការរៀនផ្ទាល់នៅតាមសាលារៀន ទៅការរៀនតាមអ៊ិនធឺណេត ឬ E-learningដែលជាបទពិសោធន៍ថ្មីចំពោះការអប់រំនៅក្នុងប្រទេសកម្ពុជា។ សម្រាប់គ្រូនៅក្នុងប្រទេសកម្ពុជាភាគច្រើននៅតែពឹងផ្អែកលើការបង្រៀនផ្ទាល់នៅក្នុងថ្នាក់ជាមធ្យោបាយក្នុងការផ្ដល់មេរៀនដល់សិស្ស។[37] ដើម្បីផ្ដល់ការអប់រំក្នុងអំឡុងពេលមានជម្ងឺរាតត្បាតកូវីដ-១៩ គ្រូបង្រៀនត្រូវបានផ្លាស់ប្ដូរការបង្រៀនភ្លាមៗតាមអ៊ិនធឺណេតដោយគ្មានការបណ្ដុះបណ្ដាលត្រឹមត្រូវ ឬ បទពិសោធន៍ច្រើនឡើយ។

ជាការពិតណាស់ ប្រទេសកម្ពុជាពិតជាមិនបានត្រៀមខ្លួនគ្រប់គ្រាន់សម្រាប់ការអប់រំតាមអ៊ិនធឺណេតឡើយ។ ហើយនៅពេលដែលការអប់រំត្រូវបានផ្លាស់ប្ដូរភ្លាមៗដូចនេះ វាពិតជាផ្ដល់ផលលំបាកយ៉ាងខ្លាំងមក ដល់សិស្ស និស្សិត ក៏ដូចជាគ្រូបង្រៀនផងដែរក្នុងការសម្របខ្លួនក្នុងបរិបទថ្មីនេះ។ ដោយសារតែមានការគំរាមកំហែងពីការរីករាលដាលនៃជម្ងឺកូវីដ-១៩ គ្រូ និងនិស្សិតកម្ពុជាជាច្រើនប្រឈមនឹងបញ្ហាប្រឈមភ្លាមៗនៃការធ្វើការកែប្រែយ៉ាងឆាប់រហ័សដើម្បីទទួលយកការរៀន និងបង្រៀនតាមអេឡិចត្រូនិច ហើយនេះក៏ជាការផ្លាស់ប្ដូរមួយដែលកំពុងតែកើតឡើងនៅទូទាំងប្រទេសកម្ពុជាទាំងមូលផងដែរ។ ការផ្លាស់ប្ដូរបរិបទសិក្សាភ្លាមៗបែបនេះ

[35] https://www.worldometers.info/coronavirus/ (ចូលទស្សនាថ្ងៃទី ២៤ កក្កដា ២០២១)។

[36] ស្ថាប័នអប់រំសាធារណៈ និងឯកជនទាំងអស់នៅកម្ពុជាត្រូវបានផ្អាក, [https://www.khmertimeskh.com/50827832/all-public-and-private-educational-institutions-in-cambodia-suspended/] (ចូលទស្សនាថ្ងៃទី២៦ កក្កដា ២០២១)។

[37] Som Kanika, ការសិក្សាតាមអេឡិចត្រូនិចបង្ហាញពីវិសមភាពអប់រំ, [https://www.khmertimeskh.com/707759/e-learning-highlights-educational-inequality/] (ចូលទស្សនាថ្ងៃទី២៦ កក្កដា ២០២១)។

នៅក្នុងប្រទេសកម្ពុជា បានផ្តល់នូវការលំបាកមួយចំនួនមកលើប្រព័ន្ធអប់រំ ពោលគឺទាំងសិស្ស និស្សិត និងគ្រូបង្រៀនសុទ្ធតែខ្វះខាតនូវបទពិសោធន៍សម្រាប់ការសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតនេះ។

### ៣.៣.១.១ កត្តាប្រឈមផ្នែកសម្ភារៈ

បញ្ហាប្រឈមដំបូងនោះ គឺការខ្វះឧបករណ៍ដើម្បីចូលមើលវីដេអូមេរៀនតាមអ៊ិនធឺ ណេត និងការរៀនសូត្រតាមអេឡិចត្រូនិកដូចជាទូរទស្សន៍ ឬវេទិកាតាមអ៊ិនធឺណេតផ្សេងៗទៀត ហើយបញ្ហាប្រឈមនេះ គឺបានជះឥទ្ធិពលខ្លាំងជាងគេសម្រាប់សិស្សសាលាបឋមសិក្សានៅជនបទ។ ការដែលក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតឱ្យមានការផ្សព្វផ្សាយមេរៀនលើទូរទស្សន៍នៅក្នុងអំឡុងពេលបិទសាលាបែបនេះ គឺជារឿងមួយដែលល្អ ប៉ុន្តែវាប្រហែលជាមិនមានប្រសិទ្ធិភាពសម្រាប់សិស្សដែលរស់នៅតាមជនបទទេ។ ឪពុកម្តាយមួយចំនួនបានបាត់បង់ការងារខណៈពេលដែលពួកគេត្រូវចំណាយទ្រព្យសម្បត្តិដើម្បីទិញទូរទស្សន៍ នេះមិនទាន់និយាយដល់កុំព្យូទ័រ ឬស្មាតហ្វូនដែលជាសម្ភារៈចាំបាច់សម្រាប់ទទួលបានមេរៀនតាម អ៊ិនធឺណេតផងនោះ។[38] ហើយចំពោះឪពុកម្តាយមួយចំនួនពុំសូវមានជីវភាពធូរធា និងមានបញ្ហាហិរញ្ញវត្ថុតាំងពីមុនពេលមានជម្ងឺរាតត្បាតគឺកាន់តែមានការលំបាកបន្ថែមទៀតក្នុងអំឡុងពេលផ្ទុះជម្ងឺកូវីដ-១៩ ដូច្នេះមានកុមារនៅតំបន់ជនបទប្រហែលជាបាត់បង់ឱកាសដើម្បីបន្តការសិក្សាការអប់រំ ដោយសារតែឪពុកម្តាយរបស់ពួកគេមិនអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការទិញសម្ភារៈបច្ចេកវិទ្យាដើម្បីរៀនតាមអ៊ិនធឺណេតឡើយ។

### ៣.៣.១.២ កត្តាខ្វះខាតនូវចំណេះដឹងផ្នែកបច្ចេកវិទ្យា និង ជំនាញ

បញ្ហាលំបាកផ្សេងៗដែលសិស្ស និស្សិត និងគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជាកំពុងតែជួបប្រទះនោះគឺកង្វះឧបករណ៍ធនធាន និងចំណេះដឹងនៃការរៀនសូត្រនិងការបង្រៀនតាមអ៊ិនធឺណេត។[39] បញ្ហាប្រឈមទាំងនេះហាក់ដូចជាមានច្រើនហើយធ្ងន់ធ្ងរ នៅក្នុងសាលារៀនដែលគ្រប់គ្រងដោយរដ្ឋាភិបាល(សាលារៀនរដ្ឋ) ជាពិសេសនៅតាមតំបន់ជនបទ។ ទោះបីជាសាលារៀនមួយចំនួនត្រូវបានបំពាក់ដោយកម្មវិធី ព័ត៌មាននិងការទំនាក់ទំនងបច្ចេកវិទ្យា(ICT) ដែលមាននិន្នាការផ្តោតសំខាន់លើចំណេះដឹងជាមូលដ្ឋានក្នុងការប្រើសូហ្វវែរកុំព្យូទ័រដូចជា Microsoft Word, Microsoft Excel និងMicrosoft PowerPointជាដើម។ ទាំងនេះក៏បញ្ជាក់យ៉ាងច្បាស់ថា សិស្សនិស្សិត ក៏ដូចជាគ្រូបង្រៀនគឺនូវមានបទពិសោធន៍តិចតួចនៅឡើងក្នុងសិក្សាតាមE-learning បែបនេះ ព្រោះតែពីមុនមក ការបង្រៀនគឺធ្វើឡើងនៅក្នុងថ្នាក់រៀន ហើយចំណែកឯកម្មវិធីសិក្សាខាងផ្នែកបច្ចេក

[38] និស្សិតជនបទនៅប្រទេសកម្ពុជាបានរៀនសូត្រពីចម្ងាយ, [https://www.nst.com.my/world/region/2020/05/589197/cambodias-rural-students-left-behind-distance-learning] (ចូលទស្សនាថ្ងៃទី២៧ កក្កដា ២០២១)។

[39] Corado, R., Flinn, R. E., & Tungjan, P. (2019). Can ICT help Cambodian students become the solution for improving education in the country? [https://jomeino.com/journal/can-ict-help-cambodian-students-become-solution-improving-education-country] (ចូលទស្សនាថ្ងៃទី២៧ កក្កដា ២០២១)។

វិទ្យានៅក្នុងសាលារៀនគឺមិនទាន់មានភាពទូលំទូលាយនៅឡើយទេ ហេតុដូចនេះហើយគឺធ្វើឱ្យមានការលំបាកក្នុងការសម្របខ្លួនរៀនតាមបែបថ្មីនេះ (E-learning)។

និស្សិតដែលមានបទពិសោធន៍តិចតួច ក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាដើម្បីសិក្សាតាមប្រព័ន្ធអ៊ិនធរណេតអាចនឹងជួបនូវបញ្ហាស្មុគស្មាញ ក្នុងការប្រើប្រាស់ដើម្បីចូលទៅកាន់កម្មវិធីសិក្សាផ្សេងៗ និងបញ្ចូលការងាររបស់ពួកគេលើបណ្តាញ។ ពួកគេអាចមានអារម្មណ៍មិនស្រួល ពោលគឺមិនទម្លាប់ក្នុងការចាប់យកសកម្មភាពជាច្រើនដែលពួកគេត្រូវការក្នុងអំឡុងពេលសិក្សាតាមអ៊ិនធឺណេត។

យុវតី សុខ វណ្ណនីកា សិស្សថ្នាក់ទី១២ម្នាក់ទៀតដែលរៀននៅវិទ្យាល័យអង្គរ ខេត្តសៀមរាបបានបញ្ជាក់ថាកញ្ញាចាប់ផ្តើមរៀនអនឡាញតាំងពីខែមីនា ពេលមានការប្រកាសបិទសាលាដោយសារជំងឺកូវីដ-១៩។ កញ្ញាបន្តថាការរៀនតាមអនឡាញធ្វើឱ្យលទ្ធផលនៃការរៀនរបស់កញ្ញាមានកម្រិតថយជាងការរៀនក្នុងថ្នាក់ដោយផ្ទាល់ជាមួយគ្រូ។[40]

### ៣.៣.១.៣ កត្តាប្រឈមក្នុងការសម្របខ្លួន

គួរកត់សម្គាល់ថាការបង្រៀនសិស្សតាមរយៈ អ៊ិនធឺណេតគឺជាការងារដែលមិនងាយស្រួលឡើយសម្រាប់គ្រូបង្រៀនភាគច្រើន។ ជាក់ស្តែងគ្រូបង្រៀនត្រូវការទទួល វគ្គបណ្តុះបណ្តាលជាមុនសិនដើម្បីអាចដំណើរការកម្មវិធីរៀនតាមអ៊ិនធរណេតប្រកបដោយប្រសិទ្ធភាពបាន។ ហើយភាគច្រើនគ្រូបង្រៀនត្រូវប្រឈមមុខ និងការកើនឡើងនូវបន្ទុកការងារមួយចំនួនបន្ថែមដូចជា; ពួកគេត្រូវទាមទារផលិតមេរៀនជាទំរង់អូឌីយ៉ូវីដេអូរឺបទបង្ហាញជាស្លាយ(PowerPoint) ពោលគឺគ្រូបង្រៀនចាំបាច់ត្រូវប្រើខ្សែអាត់វីដេអូដើម្បីទាក់ទងជាមួយសិស្ស។

ជាការពិតណាស់ប្រព័ន្ធអ៊ិនធឺណេត គឺពិតជាមានភាពទូលំទូលាយយ៉ាងខ្លាំង ដែលប្រមូលផ្តុំទៅដោយព័ត៌មានរាប់មិនអស់ ហើយការប្រើប្រាស់វាក៏ផ្តល់ទាំងផលវិជ្ជមាន និងអវិជ្ជមានផងដែរអាស្រ័យទៅលើអ្នកប្រើប្រាស់ម្នាក់ៗ។ បើនិយាយឱ្យចំទៅ គឺការរៀនតាមអ៊ិនធឺណេតអាចបណ្តាលឱ្យសិស្សបាត់បង់ការគ្រប់គ្រងខ្លួនឯង។ ជាក់ស្តែងគេមើលឃើញនៅក្នុងប្រទេសផ្សេងទៀតសិស្សមួយចំនួនអាចនឹងប្រព្រឹត្តនូវរឿងអវិជ្ជមាន, ការចែករំលែករូបភាពជាក់ស្តែង, ស្រែមអាសអាភាស និងផលិតសំលេងរំខានចូលរួមការសន្ទនាជាក្រុម។[41] នេះអាចបង្កើតជាបញ្ហាដែលអាចធ្វើឱ្យសិស្សមួយចំនួនដែលជាអ្នកខិតខំប្រឹងរៀនពិតប្រាកដ, ខកចិត្តខ្លះអាចធ្វើឱ្យពួកគេបាត់បង់ចំណាប់អារម្មណ៍ចូលរៀនតាមអ៊ិនធឺណេត។ ក្រៅពីនេះនិស្សិតអាចធ្វើលួចចម្លងគ្នានៅពេលធ្វើលំហាត់

[40] កាន់ វិច្ឆិកា, ការរៀនតាមអនឡាញនាំឱ្យមានការបារម្ភថា សិស្សដែលមិនមានលទ្ធភាពត្រូវបាត់បង់ឱកាសរៀន, [https://khmer.voanews.com/a/online-class-in-cambodia-during-covid-19/5477128.html] (ចូលទស្សនាថ្ងៃទី១៥ មិថុនា ២០២១)។

[41] 'zoombies' Take Over Online classrooms, [https://www.insidehighered.com/news/2020/04/03/zoombombing-isn%E2%80%99t-going-away-and-it-could-get-worse] (ចូលទស្សនាថ្ងៃទី២៧ កក្កដា ២០២១)។

ឬតេស្តតាមអ៊ិនធឺណែត។ ពួកគេអាចសួរអ្នកផ្សេងដើម្បីបំពេញកិច្ចការដែលបានកំណត់ ឬចំលងចម្លើយពីមិត្តរួមថ្នាក់របស់ពួកគេជំនួសវិញនៃការបំពេញភារកិច្ចដោយខ្លួនឯង។

### ៣.៣.១.៤ កត្តាប្រឈមផ្នែកប្រព័ន្ធអ៊ិនធឺណែត

ល្បឿនអ៊ិនធឺណែត និងបណ្តាញក្នុងការចូលប្រើអ៊ិនធឺណែតក៏ជាបញ្ហាធំដែរ។ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យារួមទាំងអ៊ិនធឺណែតការតភ្ជាប់នៅតែ ជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់សាលារៀនជាច្រើនជាពិសេសសាលារៀនជនបទ។ ខណៈពេលដែលការរៀនសូត្រតាមអ៊ិនធឺណែតកំពុងកើតឡើងការចូលប្រើមិនស្មើគ្នាការអប់រំត្រូវបានរាយការណ៍។[42] សិស្សមួយចំនួនអាចប្រឈមនឹងការជាប់ចំណាត់ថ្នាក់ដដែលៗ ដោយសារអសមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងថ្នាក់រៀនតាមអ៊ិនធឺណែតខណៈ មានន័យថា ពេលខ្លះកន្លែងដែលពួកគេរស់នៅគឺមានប្រព័ន្ធInternet ខ្សោយ ជាមូលហេតុធ្វើឱ្យការរៀនរបស់ពួកគេគឺមិនបានដិតដល់ដូចសិក្សាដ៏ទៃទៀតដែលគេមានអ៊ិនធឺណែតប្រើគ្រប់គ្រាន់។ "តាមខ្ញុំសង្កេតមើលទៅ ការរៀនរបស់ខ្ញុំដូចវារាងមានកម្រិតវាអាចធ្លាក់ចុះជាងមុន។ ពិបាកក៏ថាបានដែរ ដោយសាររឿងចម្បង គឺអ៊ិនធឺណែតហ្នឹងហើយបង"។ យុវសិស្សវ័យ១៧ ឆ្នាំរូបនេះបន្ថែមថា ផ្ទះរបស់នាងមានភ្ជាប់អ៊ិនធឺណែតWIFI ទើបនាងមិនសូវខ្វល់អំពីការចំណាយលើអ៊ិនធឺណែតជាប្រចាំ។ ប៉ុន្តែនាងត្អូញត្អែរថានាងតែងប្រឈមនឹងការបាត់បង់ការយកចិត្តទុកដាក់ដោយសារអ៊ិនធឺណែតមានភាពរអាក់រអួល។ ពេលខ្លះមានការរំខានដោយសំឡេងនៅផ្ទះ និងពេលខ្លះត្រូវជួយធ្វើការងារផ្សេងៗពេលកំពុងរៀនជាដើម។[43]

### ៣.៣.២ ឱកាស

នៅរាល់ស្ថានភាព ឬ ព្រឹត្តិការណ៍មិនល្អក៏អាចនឹងមានផលវិជ្ជមានក្នុងនោះផងដែរ។ ជាក់ ស្តែងការរីករាលដាលនៃជម្ងឺកូវីដ-១៩ វាបានផ្តល់ផលអាក្រក់ជាច្រើនទៅលើបណ្តាប្រទេសនៅលើពិភពលោក ហើយក្នុងនោះប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលទទួលរងគ្រោះយ៉ាងដំណំពីការរីករាលដាលនៃជម្ងឺកូវីដ-១៩នេះផងដែរ។ ក្រោយមានព្រឹត្តិការណ៍រីករាលដាលនៃជម្ងឺកូវីដ-១៩ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាបានទទួលនូវផលអវិជ្ជមានជាច្រើន តែក្នុងនោះក៏មាននូវផលវិជ្ជមានមួយចំនួនផងដែរ។

នៅក្នុងប្រទេសកម្ពុជាចំពោះប្រព័ន្ធអប់រំក្នុងអំឡុងពេលវិបត្តិនៃជម្ងឺកូវីដ-១៩ ក្រៅពីផលប៉ះពាល់ដែលជះឥទ្ធិពលដល់វិស័យអប់រំ ក៏ដូចជាផលពិបាកផ្សេងៗដែលសិស្ស-និស្សិតបានជួបប្រទះ វាក៏មាននូវផលវិជ្ជមាន

[42] Som Kanikaç E-learning highlights educational inequality, [https://www.khmertimeskh.com/707759/e-learning-highlights-educational-inequality/] (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

[43] កាន់ វិច្ឆិកា,ការរៀនតាមអនឡាញនាំឱ្យមានការបារម្ភថា សិស្សដែលមិនមានលទ្ធភាពត្រូវបាត់បង់ឱកាសរៀន, [https://khmer.voanews.com/a/online-class-in-cambodia-during-covid-19/5477128.html] (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

មួយចំនួនផងដែរ។[44] សម្រាប់ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានអ្នកប្រើប្រាស់អ៊ិនធឺណែតរហូតដល់ទៅ ៩.៧លាននាក់(មាន៥៨% ក្នុងចំណោមប្រជាជនសរុបចំនួន១៦.៧លាននាក់)។[45]

ការផ្លាស់ប្តូរការរៀនសូត្រ និងការបង្រៀនតាមអ៊ិនធឺណែតគឺជាបញ្ហាប្រឈមដ៏ពិតប្រាកដនៅក្នុងប្រទេសកម្ពុជាហើយស្របគ្នានោះដែរវាក៏ជាការកែសម្រួលដ៏លំបាកសម្រាប់សិស្ស គ្រូ ខាងសាលារៀន និងឪពុកម្តាយជាច្រើនផងដែរ។ ទោះយ៉ាងណាក៏ដោយនៅក្នុងពេលវេលានៃការផ្លាស់ប្តូរបែបនេះបាន ផ្តល់នូវឱកាសពិសេសមួយសម្រាប់ការផ្លាស់ប្តូរប្រព័ន្ធអប់រំរបស់ប្រទេសតាមបែបឌីជីថល។

### ៣.៣.២.១ ការពន្លឿនក្នុងការចាប់យកនូវបច្ចេកវិទ្យា

ស្របពេលដែលប្រទេសកម្ពុជា កំពុងតែមានការខិតខំយ៉ាងខ្លាំងនៅក្នុងការជម្រុញវិ- ស័យអប់រំនៅទូទាំងប្រទេសឱ្យស្របទៅនឹងយុគ្គសម័យឌីជីថល ឬបដិវត្តឧស្សាហកម្ម៤.0 ដោយមានការដាក់ចេញនូវកម្មវិធីសិក្សាថ្មីៗដែលរួមមាន E-library, STEM ព្រមទាំងបង្កើតឱ្យមាននូវសាលារៀនជំនាន់ថ្មីផងដែរ។ ដោយសារតែវិបត្តិនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យសាលារៀននៅក្នុងប្រទេសកម្ពុជាត្រូវបង្ខំចិត្តធ្វើការផ្លាស់ប្តូរមកសិក្សាតាមប្រព័ន្ធអនឡាញវិញ ដែលក្រសួងអប់រំយុវជន និងកីឡា បានផ្តល់នូវ និងធ្វើការផ្សព្វផ្សាយមេរៀននៅលើទូរទស្សន៍ និងបង្កើតជាវេទិការនិម្មិតផងដែរសម្រាប់ការសិក្សាថ្នាក់បឋមសិក្សា និងថ្នាក់វិទ្យាល័យ។ ត្បិតតែការផ្លាស់ប្តូរភ្លាមៗមិនបានត្រៀមទុកមុននេះ ផ្តល់ផលពិបាកដល់សិស្ស ក៏ដូចជាគ្រូក្តី តែទោះយ៉ាងណាការផ្លាស់ប្តូរពីការរៀនក្នុងថ្នាក់ផ្ទាល់ ទៅរៀននិងបង្រៀនតាមអ៊ិនធឺណែតបានផ្តល់មេរៀនដ៏មានតម្លៃដើម្បីឱ្យសិស្សគ្រូនិងអ្នកគ្រប់គ្រងសាលាយល់ពីបញ្ហាប្រឈម ឱកាស និងលទ្ធភាពនៃការទទួលយកនិងបញ្ចូលបច្ចេកវិទ្យាព័ត៌មានវិទ្យាទៅក្នុងសាលារៀន។

ដែលនេះក៏រាប់ជាឱកាសថ្មីមួយដែលសិស្ស និស្សិតនៅក្នុងប្រទេសកម្ពុជាត្រូវធ្វើការសម្របខ្លួនតាមបែបថ្មីមួយ ពោលគឺការសិក្សាត្រូវពឹងផ្អែកលើប្រព័ន្ធអ៊ិនធឺណែត ហើយការបង្រៀនក៏ត្រូវធ្វើឡើងតាមបែបឌីជីថលផងដែរ។

### ៣.៣.២.២ ការកែទម្រង់លើវិស័យអប់រំ

ការយល់ដឹងដែលទទួលបានពីការផ្លាស់ប្តូរបែបថ្មីនេះគឺផ្តល់នូវបទពិសោធន៍ នឹងជះឥទ្ធិពលវិជ្ជមាន ទៅលើការត្រៀមខ្លួនរបស់ប្រទេសកម្ពុជាឆ្ពោះទៅរកការរៀនតាមអេឡិចត្រូនិច និងការរៀនបញ្ចូលគ្នាទាំងនៅក្នុងសាលារៀននិងសាកលវិទ្យាល័យ។ បទពិសោធន៍ផ្ទាល់ជាមួយការរៀនតាមអេឡិចត្រូនិច និងការបង្រៀនតាមអេ

---

[44] Sok Chan, Financial ruin for private school, [https://www.khmertimeskh.com/713130/financial-ruin-for-private-schools/] (ចូលទស្សនាថ្ងៃទី១៦ កក្កដា ២០២១)។

[45] https://datareportal.com/reports/digital-2020-cambodia (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

ឡិកត្រូនិកក្នុងពេលមានជំងឺរាតត្បាតនឹងក្លាយជាមូលដ្ឋានគ្រឹះដ៏សំខាន់ ហើយក៏នឹងជួយបំផុសគំនិតសម្រាប់ការអនុម័តនាពេលអនាគតក្នុង ផ្នែកបច្ចេកវិទ្យាដើម្បីលើកកម្ពស់ការរៀនសូត្រ និងការបង្រៀននៅតាមសាលារៀន និងដល់មនុស្សមួយចំនួនធំនៅតាមសាកលវិទ្យាល័យនានាដែលជួយក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍។[46]

ដូច្នេះក្រសួង អប់រំ យុវជន និងកីឡាគួរតែទាញយកប្រយោជន៍ពីឱកាសដែលមិននឹកស្មានដល់នេះដោយបន្តប្រើប្រាស់ជាមួយនឹងប្រព័ន្ធអាយស៊ីធី(ICT) ក្នុងមធ្យោបាយដែលជួយលើកកម្ពស់ក្នុងការរៀន និងបង្រៀននៅតាមសាលារៀននិងសាកលវិទ្យាល័យទូទាំងប្រទេសបើទោះជាក្នុងករណីនៅពេលដែលជំងឺរាតត្បាតបានចប់ហើយក៏ដោយ។ ដើម្បីបង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានឱ្យកាន់តែច្រើន ត្រូវធ្វើការយកចិត្តទុកដាក់បន្ថែមទៀតរួមទាំងធ្វើអន្តរាគមន៍នយោបាយប្រកបដោយភាពច្នៃប្រឌិតហើយ បង្កើនការវិនិយោគក៏គួរតែត្រូវបានដឹកនាំឆ្ពោះទៅរកការលើកទឹកចិត្ត និងគាំទ្រដល់ការធ្វើសមាហរណកម្មបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការរៀបចំថ្នាក់រៀនជាពិសេស នៅតាមទីជនបទតំបន់ដែលការបែងចែកឌីជីថលនិងវិសមភាពអប់រំត្រូវកំពុងយកចិត្តទុកដាក់។[47] ដើម្បីភ្ជាប់ការបែងចែកឌីជីថល ទាំងធនធានបច្ចេកវិទ្យានិងធនធានមនុស្សត្រូវដើរទន្ទឹមគ្នា។ ការវិនិយោគទាំងពីរគឺចាំបាច់ប្រសិនបើប្រទេសកម្ពុជាត្រូវសម្រេចឱ្យបាននូវការផ្លាស់ប្តូរឌីជីថលនៃប្រព័ន្ធអប់រំរបស់ខ្លួន។[48]

### ៣.៣.២.៣ វិធីសាស្ត្រ និង ព័ត៌មានទាក់ទងទៅនឹងមេរៀនកាន់តែមានភាពសម្បូរបែប

សម្រាប់និស្សិតអត្ថប្រយោជន៍សំខាន់មួយគឺ ពួកគេអាចរៀនគ្រប់គ្រងលើការសិក្សាដោយខ្លួនឯង។ ពួកគេក៏អាចទទួលបាននូវចំណេះដឹងបន្ថែមទៀតទៅលើមុខវិជ្ជាផ្សេងៗហើយអាចសិក្សានៅពេលណាដែលពួកគេចង់បាន ព្រមទាំងអាចចូលរួមរៀននៅគ្រប់ទីកន្លែងដែលទុកឱ្យពួកគេមានសេរីភាពក្នុងការជ្រើសរើសពេលវេលាសម្រាប់សិក្សា ចំណេញពេលវេលា និងកន្លែងសិក្សា ពង្រីកចំណេះដឹង និងការស្រាវជ្រាវថ្មីៗ រួមទាំងឱកាសផ្សេងៗដើម្បីទទួលយកវគ្គសិក្សា និងការធ្វើតេស្តតាមអ៊ិនធរណេតផងដែរ ។ [49]

និស្សិតក៏អាចប្រើឧបករណ៍ឌីជីថល ដើម្បីបង្កើនជំនាញ និងចំណេះដឹងតាមរយៈវេទិការៀនអេឡិចត្រូនិកជាច្រើនដែលសាកលវិទ្យាល័យជាច្រើនបានបញ្ចូល។ វិធីសាស្ត្រទាំងនេះក៏ជួយដល់និស្សិត តាមបណ្តាខេត្តភាគច្រើនកាត់បន្ថយហានិភ័យក្នុងការធ្វើដំណើរការ ចំណាយប្រចាំថ្ងៃក្នុងទីក្រុងផងដែរ។ លោកឌិម រ៉ុនីអគ្គនាយក

---

[46] Voun Dara, E-learning center to open at high school, [https://www.phnompenhpost.com/national/e-learning-centre-open-high-school] (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

[47] Flynn & Himel, [https://cambodianess.com/article/school-closures-highlight-inequality-in-education-as-classes-move-online] (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

[48] https://cambodia.oxfam.org/bridging-digital-divide-cambodia, (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

[49]Sen David & Yesenia Amaro, Practice for grade-12 test goes online, [https://www.phnompenhpost.com/national/practice-grade-12-test-goes-online], (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានមានប្រសាសន៍ថា "នៅលើវេទិកាឌីជីថលថា និស្សិតអាចមើលនិងវាយតម្លៃមេរៀនបានច្រើនដងតាមដែលពួកគេចង់ក៏ដូចជាកត់ចំណាំសំណួរដើម្បីសួរសាស្ត្រាចារ្យ"។ លោកបានបន្ថែមថា" និស្សិតមានឆន្ទៈក្នុងការសួរសំណួរក្នុងអំឡុងពេលសិក្សាតាមអ៊ិនធឺណេតជាជាងនៅក្នុងថ្នាក់រៀនជាក់ស្តែង ពីព្រោះបន្ទាប់ពីមើលមេរៀនឡើងវិញពួកគេហាក់ដូចជាចង់ដឹង"។[50]

## ៣.៤ ការសិក្សាតាមរយៈអនឡាញក្នុងអំឡុងពេល Lockdown របស់វិស័យឯកជន

បើនិយាយពីវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា គឺមានពីរធំៗ គឺវិស័យរដ្ឋ(សាធារណៈ) និងវិស័យឯកជន។ ផលពិបាកក៏ដូចជាផលប៉ះពាល់ដែលបណ្តាលមកពីការបិទសាលា ក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ គឺបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើការវិស័យអប់រំមិនមែនតែរដ្ឋប៉ុណ្ណោះនោះទេ តែវិស័យឯកជនផងដែរ។ ដូចដែលបានរៀបរាប់ពីបញ្ហាប្រឈម ក៏ដូចជាឱកាសដែលវិស័យអប់រំក្នុងវិស័យរដ្ឋទទួលបានរួចមកហើយ ក្នុងចំណុច ៣.៣ ខាងលើ ហើយចំពោះក្នុងចំណុចនេះយើងនឹងលើកយកបង្ហាញពីគុណភាពអប់រំ បញ្ហាប្រឈម ក៏ផលវិជ្ជមានផ្សេងៗ មួយចំនួនដែលវិស័យអប់រំរបស់វិស័យឯកជនទទួលបានក្នុងអំឡុងពេលការរាតត្បាតនៃជម្ងឺកូវីដ-១៩នេះ។

មិនខុសគ្នាពីវិស័យរដ្ឋប៉ុន្មានទេឡើយ គឺទាំងសិស្ស និស្សិតរួមទាំងគ្រូបង្រៀនផងនោះគឺបានទទួលរងនូវបញ្ហាប្រឈមជាច្រើន ដោយសារតែវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាយើងមានបទពិសោធន៍តិចតួចបំផុតក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងការសិក្សា។

### ៣.៤.១ បញ្ហាប្រឈមនៅក្នុងការសិក្សាតាមរយៈអនឡាញ

ចំពោះបញ្ហាប្រឈមក្នុងការសិក្សាតាមរយៈប្រព័ន្ធអនឡាញរបស់វិស័យឯកជន គឺមានមិនខុសគ្នាពីសាលារដ្ឋឡើយគឺទាក់ទងនឹងកង្វះខាតក្នុងការប្រើប្រាស់នូវបច្ចេកវិទ្យាក្នុងការរៀនក៏ដូចជាបង្រៀនផងដែរ ហើយមួយវិញទៀតគឺបញ្ហាអ៊ិនធឺណេតក៏ជាបញ្ហាចម្បងមួយផងដែរ ហើយអ្វីដែលជាបញ្ហាចម្បងនោះគឺគុណភាពអប់រំដែលសិស្សទទួលបានគឺនៅមានកម្រិត។

#### ៣.៤.១.១ គុណភាពនៃការសិក្សាតាមរយៈប្រព័ន្ធអនឡាញ

សម្រាប់ផលប៉ះពាល់ពីកូវីដ-១៩ មកលើវិស័យអប់រំក្នុងវិស័យឯកជនគឺមានច្រើន នេះបើតាមកិច្ចសម្ភាសន៍ពីលោក ប៊ូច បូឡែន អគ្គនាយកនៃក្រុមហ៊ុនវេសឡាញអេឌ្យូខេសិនគ្រុប ។ លោកបន្តថាបញ្ហាដែលធំបំផុតនោះគឺ ត្រង់ថាពិបាកក្នុងការបញ្ជូននូវខ្លឹមសារមេរៀន និងការបង្រៀនដែលខាងសាលាចង់បានជូនដល់សិស្ស ឱ្យដូចដែលចិត្តយើងចង់បាន និងអាណាព្យាបាលសិស្សចង់បាន ពោលគឺការផ្គត់ផ្គង់និងតម្រូវការមិនជួបគ្នា។

[50] Som Kanika, Pros and cons of E-learning in universities, [https://www.khmertimeskh.com/50736457/pros-and-cons-of-e-learning-in-universities/] (ចូលទស្សនាថ្ងៃទី១៤ កក្កដា ២០២១)។

លោកបាននិយាយថា ខាងសាលាពិតជាមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើឯកសារមេរៀន ថតជាវីដេអូ ដើម្បីផ្ញើរទៅឱ្យសិស្ស ប៉ុន្តែអាណាព្យាបាលនូវតែមិនទាន់បានទទួលនូវគុណភាព បរិមាណ ដូចដែលខាងសាលាចង់ឱ្យខាងសិស្សទទួលបាន បញ្ហាជាពិសេសនោះគឺចំពោះកុមារតូច ហើយទំហំនៃការធ្វើការសម្រាប់គ្រូក្នុងអំឡុងពេលកូវីដ-១៩នេះ គឺមានការហត់នឿយ និងពិបាកច្រើនជាងមុនប៉ុន្តែគុណភាពនៃការបង្រៀនគឺនៅមានកំណត់ មិនទាន់ត្រូវចិត្តអាណាព្យាបាលសិស្ស។

### ៣.៤.១.២ ការសម្របខ្លួន

ពិតណាស់សម្រាប់ការសម្របខ្លួននូវតែជារឿងពិបាកមួយសម្រាប់សិស្សនិស្សិត ក៏ដូចជាគ្រូបង្រៀនផងដែរ ដោយសារតែនេះគឺជាការផ្លាស់ប្តូរភ្លាមៗ ដែលគ្រប់គ្នាមិនទាន់មានការត្រៀមខ្លួនទុកមុននៅឡើយ។ ផលពិបាកធំបំផុតនោះគឺចំពោះកុមារតូចៗ ដោយសារតែគាត់ចាំបាច់ត្រូវមានអាណាព្យាបាលនៅជិតពួកគាត់ ដើម្បីមើលការសិក្សារបស់ពួកគាត់ បើដូចនោះទេភាគច្រើនគឺពួកគាត់មិនសូវជាយកចិត្តទុកដាក់ក្នុងការរៀនឡើយព្រោះពួកគាត់អាចពិបាកសម្របខ្លួនជាងមនុស្សធំ ដោយសារតែធ្លាប់រៀននៅក្នុងថ្នាក់ គ្រូមានសកម្មភាពផ្សេងៗឱ្យអនុវត្តខុសពីរៀនតាមប្រព័ន្ធអនឡាញដោយគ្រាន់តែអង្គុយរៀនស្តាប់គ្រូនៅនឹងមុខទូរស័ព្ទ ឬកុំព្យូទ័រតែម្យ៉ាង។

### ៣.៤.១.៣ ការក្ស័យធន

បើយោងតាមសេចក្តីអំពាវនាវលេខ BOD០១៤/២០ សគឧក នៃសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ បានទទួលនូវលទ្ធផលនៃការប្រជុំសមាជិកសមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា កាលពីថ្ងៃទី៣ ខែមេសា ឆ្នាំ២០២០ គឺមានគ្រឹះស្ថានអប់រំឯកជនចំនួន១១៣ ដែលបានជួបនូវការលំបាក និងផលប៉ះពាល់យ៉ាងខ្លាំង។[51]

ការអប់រំនៅក្នុងវិស័យឯកជន គឺមិនសូវខុសគ្នាពីការអប់រំនៅក្នុងវិស័យរដ្ឋប៉ុន្មាន នោះទេ។ ការអបរំនៅក្នុងវិស័យឯកជន គឺត្រូវមានការចំណាយផ្នែកហិរញ្ញវត្ថុនៅទៅលើ ធនធានមនុស្សក្នុងគ្រឹះស្ថាន ទីតាំង ជាពិសេសទៅនោះ គឺប្រាក់ដើមដែលគ្រឹះស្ថានបានខ្ចីពីធនាគារ។ល។ ដូច្នោះហើយបានគ្រឹះស្ថានអប់រំឯកជន ប្រឈមមុខទៅនឹងការក្ស័យធន និងបិទគ្រឹះស្ថានទាំងស្រុង ជាមូលហេតុដោយសារតែចំណូលផ្នែកហិរញ្ញវត្ថុមានកម្រិតទាប សម្រាប់បែងចែងទៅគ្រប់ផ្នែក នៅក្នុងគ្រឹះស្ថាន។

ហេតុដូចនេះហើយ ការផ្អាកបណ្តោះអាសន្នសេវាអប់រំឯកជននៅក្នុងអំឡុងពេលដែលកំពុងរាតត្បាតនៃជម្ងឺកូវីដ-១៩ គឺវាបានប៉ះពាល់យ៉ាងធ្ងន់ធរទៅលើគ្រឹះស្ថានអប់រំមួយចំនួនធំ ហើយវាអាចវិវត្តដល់ការបិទសាលា។

---

[51] សមាគមន៍គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា លេខ BOD០១៤/២០ សគឧក, សេចក្តីអំពាវនាវ, ចុះថ្ងៃ០៦ មេសា ២០២០។

### ៣.៤.២ ឱកាសផ្សេងៗសម្រាប់សិស្ស-និស្សិតក្នុងអំឡុងពេលសិក្សាតាមរយៈអនឡាញ

ប្រទេសកម្ពុជាជាប្រទេសមួយដែលសាលាភាគច្រើន នៅពឹងផ្អែកលើការបង្រៀននៅក្នុងថ្នាក់រៀនផ្ទាល់ ដោយមិនទាន់មានភាពជឿនលឿនខ្លាំងលើផ្នែកបច្ចេកវិទ្យាឡើយ។ ដោយសារតែការផ្លាស់ប្តូរភ្លាមៗមកសិក្សាតាមប្រព័ន្ធអនឡាញ និងពឹងផ្អែកទាំងស្រុងលើបច្ចេកវិទ្យាក្នុងការរៀន និងបង្រៀនដូចនេះគឺពិតណាស់បញ្ហាប្រឈមជាច្រើនពិតជាសម្រាប់សិស្ស និស្សិត និងគ្រូ។ ប៉ុន្តែស្របពេលក្នុងដែលមាននូវបញ្ហាប្រឈមមួយចំនួនសម្រាប់វិស័យឯកជន ដូចដែលបានរៀបរាប់នៅកក្នុងចំណុច៣.៣ខាងលើ គេក៏មើលឃើញនូវឱកាសមួយចំនួនផងដែរសម្រាប់សិស្ស និស្សិត ក៏ដូចជាគ្រូ ហើយនិងចំពោះវិស័យអប់រំទាំងមូលផងដែរក្នុងការអភិវឌ្ឍន៍ដើម្បីស្របទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.០ នាពេលអនាគត។

សម្រាប់គ្រូ គឺទទួលបានឱកាសក្នុងការទទួលបាននូវបទពិសោធន៍ថ្មីក្នុងការបង្រៀនតាមប្រព័ន្ធអនឡាញនេះ ហើយមានឱកាសសិក្សាស្រាវជ្រាវទៅលើផ្នែកបច្ចេកវិទ្យាបន្ថែមដើម្បីឱ្យការបង្រៀនកាន់តែមានប្រសិទ្ធភាពហើយនឹងស្របទៅនឹងយុគ្គសម័យឌីជីថលផងដែរ។

សម្រាប់សិស្ស និស្សិត គឺទទួលបានឱកាសក្នុងការយល់ដឹងបន្ថែមទៅលើការសិក្សាស្រាវជ្រាវនៅតាមបណ្តាញអ៊ិនធឺណេត ហើយពេលច្រើនជាងមុនក្នុងការធ្វើការស្រាវជ្រាវខ្លួនឯងបន្ថែមទាក់ទាងទៅនឹងចំណេះដឹងផ្សេងៗទៀតដែលមាននៅបណ្តាញអ៊ិនធឺណេត។ចំពោះវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាទាំងមូល ដែលជាពិសេសចំពោះវិស័យឯកជនផងដែរនោះ គឺនឹងទទួលបាននូវការកែទម្រង់ថ្មីមួយដែលអាចនឹងជួយជាមូលដ្ឋានគ្រឹះ ក៏ដូចផ្តល់ជាបទពិសោធន៍ថ្មីមួយសម្រាប់ឱ្យវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាឈានទៅរកការអភិវឌ្ឍន៍ឱ្យស្របទៅនឹងយុគ្គសម័យឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម៤.០ ដែលជាគោលដៅនៃការអភិវឌ្ឍន៍របស់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជានាពេលអនាគតផងដែរនោះ។

## ៣.៥ ការវិភាគទៅលើការស្ទង់មតិរបស់សិស្ស-និស្សិតពីផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ទៅលើវិស័យអប់រំ

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រព័ន្ធអ៊ិនធឺណេត តាមគេហទំព័រផ្សេងៗ តាមសៀវភៅមួយចំនួនដែលទាក់ទងនឹងផលប៉ះពាល់ ក៏ដូចជាផលវិបាកដែលវិស័យអប់រំជួបប្រទះក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩ រួចមកយើងក៏ទទួលបាននូវទិន្នន័យដែលបានរៀបរាប់យ៉ាងក្បោះក្បាយនៅក្នុងចំណុចខាងលើៗ។ ប៉ុន្តែការស្រាវជ្រាវទៅលើឯកសារផ្សេងៗ ដែលមាននៅក្នុងអ៊ិនធឺណេត ក៏ដូចជាក្នុងសៀវភៅផងដែរនោះគឺនូវមិនទាន់គ្រាប់គ្រាន់នៅឡើយទេ។ ដើម្បីឱ្យការស្រាវជ្រាវរបស់ក្រុមយើងខ្ញុំកាន់តែមានប្រសិទ្ធភាពទៀតនោះ ពួកយើងបានសម្រេចចិត្តធ្វើការស្ទង់មតិតាមប្រព័ន្ធអនឡាញទៅលើសិស្ស និស្សិតចំនួន ១០០នាក់បន្ថែមទៀត

ដើម្បីជាភស្តុតាងជាក់ស្តែងដែលបញ្ជាក់ពីបញ្ហាផ្សេងៗគ្នាដែលសិស្ស និស្សិតកំពុងតែជួបប្រទះក្នុងការសិក្សារបស់ពួកគេក្នុងអំឡុងពេលមានការរាតត្បាតពីជម្ងឺកូវីដ-១៩នេះ។

### ៣.៥.១ គោលបំណងនៃការធ្វើការស្ទង់មតិ

ដោយមើលឃើញពីផលវិបាក និងផលប៉ះពាល់មួយចំនួនធំដែលវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាកំពុងតែជួបប្រទះ ពោលគឺដោយសារតែមានវិបត្តិនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យសាលារៀននៅទូទាំងប្រទេសកម្ពុជាត្រូវបិទទ្វា ហើយត្រូវបន្តសិក្សាតាមប្រព័ន្ធអ៊ីនធឺណេតវិញ។ ចំពោះការផ្លាស់ប្តូរបរិបទសិក្សាភ្លាមៗបែបនេះពិតជាជះឥទ្ធិពលយ៉ាងខ្លាំងមកលើប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជា រួមមានទាំងឥទ្ធិពលអវិជ្ជមាន និងវិជ្ជមានផងដែរ។

ការស្ទង់មតិនេះធ្វើឡើងក្នុងគោលបំណងដើម្បីរកឱ្យឃើញពីផលប៉ះពាល់ ផលវិបាកផ្សេងៗដែលសិស្ស និស្សិតកំពុងតែប្រឈមក្នុងអំឡុងពេលនៃការផ្លាស់ប្តូរមករៀនតាមប្រព័ន្ធអនឡាញ ដោយសារតែមានការរីករាលដាលនៃជម្ងឺកូវីដ-១៩ នេះ ហើយមិនត្រឹមតែផលវិបាកតែប៉ុណ្ណោះនោះទេ តែក្នុងនោះពួកយើងក៏ចង់ដឹងពីឱកាសផ្សេងៗ និងផលវិជ្ជមានមួយចំនួនផងដែរដែលសិស្ស និស្សិតទទួលបានក្នុងអំឡុងស្ថានការណ៍ដ៏លំបាកមួយនេះ។

### ៣.៥.២ លទ្ធផលនៃការស្ទង់មតិ

យោងតាមលទ្ធផលនៃការស្ទង់មតិដែលទទួលបានពីសិស្ស និស្សិតចំនួន១០០នាក់ ក្នុងនោះមានសិស្ស និស្សិតស្រីចំនួន (៧២នាក់=៧២%) និងសិស្ស និស្សិតប្រុស (២៨នាក់=២៨%) ហើយពួកគេភាគច្រើនជាសិស្ស និស្សិតដែលកំពុងបន្តការសិក្សា(៧៥%) និងមានអាយុនៅចន្លោះពី ១៩-២១ឆ្នាំ(៣៩%)។

ចំពោះការស្ទង់មតិរបស់ពួក សំណាកដែលទទួលបាន មានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១.សិស្ស និស្សិតមានអាយុចន្លោះពី ១៥ ទៅ ២៦ ឆ្នាំ

២.ភាគច្រើនទទួលបានពីសិស្សនិស្សិតដែលនៅទីក្រុងភ្នំពេញ និងតាមខេត្តទីប្រជុំជនមួយចំនួន

៣. ហើយភាគច្រើនគឺជានិស្សិតសាកលវិទ្យាល័យ។

តាមរយៈទិន្នន័យដែលទទួលបាននេះ ពួកយើងនឹងធ្វើការវិភាគ និងបកស្រាយតាមរយៈក្រាហ្វិចដូចខាងក្រោម៖

ក្រាហ្វិចទី៤ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ទាក់ទងនឹងកម្រិតបទពិសោធន៍របស់ពួកគេក្នុងការរៀនតាមអនឡាញ



តាមរយៈក្រាហ្វិចបានបង្ហាញឱ្យឃើញថា ក្នុងចំណោមសិស្ស និស្សិតចំនួន១០០នាក់ មានសិស្ស និស្សិតចំនួន ៧៩% ដែលពួកគេធ្លាប់មានបទពិសោធន៍ក្នុងការសិក្សាតាមអនឡាញ(E-learning) ស្របពេលដែល ២១%ទៀតគឺពួកបានសិក្សាតែនៅក្នុងសាលាឬថ្នាក់រៀនផ្ទាល់តែប៉ុណ្ណោះ ពោលគឺមិនធ្លាប់សិក្សាតាមប្រព័ន្ធអ៊ិនធឺណេតឡើយ នេះអាចបណ្តាលមកពីខាងសាលារៀនរបស់ពួកគេគឺមិនធ្លាប់អនុវត្តការរៀនតាមបែបបច្ចេកវិទ្យានេះ ហើយក្នុងអំឡុងពេលផ្លាស់ប្តូរបរិបទមកសិក្សាតាមប្រព័ន្ធអនឡាញភ្លាមៗបែបនេះ ពួកគេប្រាដកជាទទួលរងនូវផលវិបាកច្រើន។

ក្រាហ្វិចទី៥ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីការពេញចិត្តរបស់ពួកគេក្នុងការរៀនតាមអ៊ិនធឺណេត




ចំពោះក្រាហ្វិចខាងលើបានបង្ហាញឱ្យឃើញថា សិស្ស និស្សិតរហូតដល់ទៅ៨៤%ដែលពួកគេពេញចិត្តក្នុងការសិក្សាតាមប្រព័ន្ធអនឡាញនេះ ហើយបើភ្ជាប់គ្នាជាមួយនឹងក្រាហ្វិចទី៥ ដែលនេះក៏អាចបង្ហាញថាជាមូលហេតុដែលភាគច្រើននៃពួកគេពេញចិត្តក្នុងការរៀនតាមប្រព័ន្ធអ៊ិនធឺណេត ព្រោះតែធ្លាប់មានបទពិសោធន៍សិក្សាកន្លងមក។ ប៉ុន្តែមាន(១៦នាក់=១៦%)ផងដែរដែលគិតថាមិនសូវល្អឡើយ ពោលគឺពួកគេមិនសូវពេញចិត្តក្នុងការសិក្សាពីចម្ងាយនេះឡើយ យើងអាចសន្មតបានថាអ្នកទាំង១៦នាក់នោះគឺមានមិនធ្លាប់មានបទពិសោធន៍ក្នុងការសិក្សាពីចម្ងាយកន្លងមក ឬពួកគេប្រឈមនូវបញ្ហាផ្សេងៗក្នុងអំឡុងពេលកំពុងសិក្សាពីចម្ងាយនេះ។

ក្រាហ្វិចទី៦ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីលទ្ធភាពរបស់ពួកគេក្នុងការប្រើឧបករណ៍រៀនតាមអ៊ិនធឺណេត




តាមរយៈក្រាហ្វិចបានបង្ហាញថា មានសិស្ស និស្សិតចំនួនរហូតទៅដល់៩៩% ក្នុងចំណោម១០០នាក់ ដែលពួកគេមានឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់សម្រាប់ការសិក្សាតាមរយៈអនឡាញ គ្រាន់តែពួកគេភាគច្រើន (៥៧%)គឺមានបញ្ហាជាមួយនឹងឧបករណ៍ប្រើប្រាស់របស់ពួកគេ ព្រោះដំណើការមិនសូវល្អ ពោលគឺមានសម្ភារៈ និងឧបករណ៍ក្នុងការប្រើប្រាស់សម្រាប់សិក្សាដែរប៉ុន្តែពេលខ្លះក៏មានបញ្ហាផងដែរ(ពិបាកប្រើប្រាស់, របស់ចាស់, គាំងជាដើម)។

ក្រាហ្វិចទី៧ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីលទ្ធភាពរបស់ពួកគេក្នុងការប្រើអ៊ិនធឺណេត




តាមក្រាហ្វិចបានបង្ហាញពីចំនួនសិស្ស និស្សិតដែលបញ្ជាក់ពីលទ្ធភាពក្នុងការប្រើប្រាស់អ៊ិនធឺណេតរបស់ពួកគេ ដែលក្នុងនោះពួកគេចំនួន ៩៥% ក្នុងចំណោម១០០% គឺមានអ៊ិនធឺណេតក្នុងការប្រើប្រាស់សម្រាប់ការ

សិក្សាតាមរយៈអនឡាញ ប៉ុន្តែក្នុងនោះផងដែរ គឺអ៊ិនធឺណេតរបស់ពួកគេចំនួន ៦០នាក់(៦០%)មានដំណើការមិនសូវល្អ ពោលគឺមានអ៊ិនធឺណេតក្នុងការប្រើប្រាស់សម្រាប់សិក្សាដែរប៉ុន្តែពេលខ្លះឃើត ឬដាច់អ៊ិនធឺណេតតែម្តង ហើយ៥%នៃ១០០នាក់គឺមិនមានអ៊ិនធឺណេតក្នុងការប្រើប្រាស់នោះទេ ដែលបញ្ហានេះអាចបណ្តាលមកពីទីកន្លែងដែលពួកគេរស់នៅ ឬកង្វះខាតជីវភាពផងដែរ។ ក្នុងចំណោមពួកគេទាំង១០០នាក់ នោះមាន៥%ប៉ុណ្ណោះគឺមិនមានអ៊ិនធឺណេតក្នុងការប្រើប្រាស់នោះទេ។

ក្រាហ្វិចទី៨ ៖ បង្ហាញពីលទ្ធភាពពេលវេលាដែលសិស្ស និស្សិតមាន បើប្រៀបធៀបទៅនឹងការសិក្សាផ្ទាល់ក្នុងថ្នាក់




តាមរយៈក្រាហ្វិចបានបង្ហាញពីគុណភាពក្នុងការរៀនតាមប្រព័ន្ធអនឡាញរបស់សិស្ស និស្សិត បើប្រៀបធៀបទៅនឹងការសិក្សាផ្ទាល់ក្នុងថ្នាក់រៀន ដោយក្នុងនោះក្រាបបញ្ជាក់ថានិស្សិតចំនួន(៦៨%=៦៨នាក់)ក្នុងចំណោមសិស្ស និស្សិតទាំង១០០នាក់ មិនសូវមានពេលវេលាគ្រប់គ្រាន់ក្នុងការរៀនទេ ព្រោះពួកគេពិបាកផ្តោតអារម្មណ៍ ហើយក៏មានការបង្ហាញផ្ទុយពីនេះ២៩% គឺមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាពីចម្ងាយនេះ។

ក្រាហ្វិចទី៩ ៖ បង្ហាញពីបញ្ហាប្រឈមរបស់សិស្ស និស្សិតក្នុងអំឡុងពេលសិក្សាតាមអនឡាញ




ក្រាហ្វិចខាងលើនេះ បានបង្ហាញឱ្យឃើញពីបញ្ហាប្រឈម ក៏ដូចជាផលវិបាកមួយចំនួនរបស់សិស្ស និស្សិតក្នុងអំឡុងពេលសិក្សាតាមអនឡាញនេះ ដែលក្នុងចំណោមសិស្ស និស្សិតចំនួន១០០នាក់ មានរហូតដល់៥៣% ដែលពួកគេមានបញ្ហាទៅលើអ៊ិនធឺណេត(យឺត, ពិបាកប្រើប្រាស់ ឬដាច់ជាដើម) ហើយមានសិស្ស និស្សិតចំនួន ១៧%មានបញ្ហាទៅលើការសម្របខ្លួន ពោលគឺនេះអាចជាបទពិសោធន៍ថ្មីសម្រាប់ពួកគេ ដែលខុសពីការរៀនផ្ទាល់ក្នុងថ្នាក់រៀន។

លើសពីនេះសិស្ស និស្សិតចំនួន២៥% គឺបានបញ្ជាក់ថាពួកគេកំពុងមានមានបញ្ហាពិបាកក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាសម្រាប់រៀនអនឡាញ ពោលគឺនូវខ្វះចំណេះដឹងផ្នែកបច្ចេកវិទ្យា និងជំនាញក្នុងការប្រើប្រាស់ ហើយក៏មានចំនួនសិស្ស៥%ផងដែរ ដែលបង្ហាញថាពួកគេខ្វះសម្ភារៈក្នុងការរៀនតាមអ៊ិនធឺណេតនេះ។

ដែលនេះសបញ្ជាក់អោយឃើញថាការសិក្សាតាមប្រព័ន្ធអនឡាញគឺពិតជាធ្វើអោយសិស្ស និស្សិតប្រឈមនូវបញ្ហាមួយចំនួនផ្សេងៗគ្នា ទៅតាមស្ថានភាពរបស់ពួកគេរៀងៗខ្លួនដែលផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ការទទួលនូវចំណេះដឹង ក្នុងអំឡុងពេលមានជម្ងឺឆ្លងបែបនេះ។

ក្រាហ្វិចទី១០ ៖ បង្ហាញពីចំនួនម៉ោងដែលសិស្ស និស្សិតចំណាយពេលក្នុងការសិក្សាពីចម្ងាយ




តាមរយៈក្រាហ្វិចទី១០នេះ បានបង្ហាញពីចំនួនម៉ោងដែលសិស្ស និស្សិតបានប្រើប្រាស់ក្នុងការសិក្សាពីចម្ងាយរបស់ពួកគេ។ ក្នុងចំណោមសិស្ស និស្សិតទាំង១០០ នាក់ ពួកគេភាគច្រើន(៥៧%)គឺបានចំណាយពេលសិក្សាត្រឹមតែ១-៣ម៉ោងប៉ុណ្ណោះក្នុងការសិក្សាតាមអ៊ិនធឺណេតនេះ។ ស្របគ្នានេះដែរ ក៏មានសិស្ស និស្សិតចំនួន២៥%គឺបានចំណាយពេលក្នុងការរៀន ពី៣-៥ម៉ោងក្នុងមួយថ្ងៃ ហើយក៏មាន១១%ផងដែរបានប្រើពេលរបស់ពួកគេពី៥-៧ម៉ោងក្នុងការរៀនអនឡាញនេះ។

នេះបញ្ជាក់ឱ្យឃើញថា ការសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតគឺធ្វើឱ្យពេលវេលាក្នុងការសិក្សារបស់សិស្ស និស្សិតមានតិចជាងមុន ដោយសារតែមានបញ្ហាប្រឈមមួយចំនួនសម្រាប់ពួកគេដូចដែលការបង្ហាញក្នុងក្រាហ្វិក៩ រួចមកនោះ ហើយពួកគេក៏ធ្លាប់បានបញ្ជាក់ផងដែរក្នុងក្រាហ្វិច៨ ដែលបង្ហាញពីការគ្រប់គ្រងពេលវេលាក្នុងការសិក្សារបស់ពួកគេ គឺមិនសូវបានល្អនោះទេឡើយ។

ក្រាហ្វិចទី១១ ៖ បង្ហាញពីប្រសិទ្ធភាពនៃការរៀនពីចម្ងាយក្នុងអំឡុងពេលកូវីដ-១៩




តាមរយៈក្រាហ្វិចគឺបង្ហាញពីកម្រិតនៃប្រសិទ្ធភាពដែលសិស្ស និស្សិតគិតថាពួកគេទទួលបានក្នុងអំឡុងពេលសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតក្នុងអំឡុងពេលកូវីដ-១៩ ដែលក្នុងនោះមានសិស្ស និស្សិត ប្រមាណជា៨៥% នៃចំនួនសិស្ស១០០នាក់ បានយល់ស្របថាការសិក្សាតាមអនឡាញគឺមានប្រសិទ្ធភាពសម្រាប់ពួកគេបើទោះជាពួកគេមានប្រឈមនូវបញ្ហាមួយចំនួនធំក្តី ហើយផ្ទុយមកវិញគឺមានសិស្ស និស្សិតចំនួន(១៥%=១៥នាក់)ដែលបង្ហាញថាការសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតគឺមិនមានប្រសិទ្ធភាពសម្រាប់ពួកគេឡើយ ដែលនេះអាចបណ្តាមកពីបញ្ហាប្រឈមផ្សេងៗដែលពួកគេបានបញ្ជាក់នៅក្នុងក្រាហ្វិចខាងលើៗ។

ក្រាហ្វិចទី១២ ៖ បង្ហាញពីកម្រិតនៃផលវិបាកក្នុងការសិក្សាតាមអនឡាញរបស់សិស្ស និស្សិត




ក្នុងក្រាហ្វិចបានបង្ហាញថា ក្នុងចំណោមសិស្ស និស្សិតទាំង១០០ នាក់ ក្នុងនោះមានរហូតដល់៩៣% ដែលបានបញ្ជាក់ថាការផ្លាស់ប្តូរបរិបទសិក្សា រៀនពីចម្ងាយក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវី-១៩ មាន

ការលំបាកសម្រាប់ពួកគេ ដែលក្នុងនោះមាន២៤នាក់គឺបង្ហាញថាពួកគេពិតជាមានការពិបាកខ្លាំងណាស់ ក្នុងការរៀនតាមអនឡាញនេះ តែក៏មាន៧%ផងដែរ ដែលបញ្ជាក់ថាពួកគេគ្មានការពិបាកក្នុងការរៀនពីចម្ងាយនេះទើ្បយ។

តាមលទ្ធផលដែលទទួលបានក្នុងក្រាហ្វិច១២នេះគឺបានបញ្ជាក់យ៉ាងច្បាស់ថា ការផ្លាស់ប្តូរមកសិក្សាតាមប្រព័ន្ធអនឡាញពិតជាផ្តល់ការពិបាកយ៉ាងខ្លាំងដល់សិស្សភាគច្រើននៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើននៃពួកគេ គឺប្រឈមនឹងបញ្ហាអ៊ិនធឺណេតផងដែរ(ក្រាហ្វិច៩)។

ក្រាហ្វិចទី១៣ ៖ បង្ហាញពីកម្រិតនៃការគ្រប់គ្រងពេលវេលាក្នុងការសិក្សាតាមអនឡាញរបស់សិស្ស និស្សិត




តាមក្រាហ្វិចខាងលើនេះ បានបង្ហាញថាសិស្ស និស្សិតភាគច្រើនគឺអាចគ្រប់គ្រងពេលវេលាសិក្សាបានល្អ (មានចំនួនរហូតដល់៨៤% ក្នុងចំណោម១០០នាក់) ហើយក្នុងចំណោមពួកគេទាំង៨៤%នោះ គឺមាន៨%ដែលបានបញ្ជាក់ថាពួកគេ គឺពិតជាអាចគ្រប់គ្រងពេលវេលាសិក្សាបានល្អខ្លាំងណាស់ក្នុងអំឡុងពេលកូវីដ-១៩នេះ តែក៏មានសិស្ស និស្សិតមួយចំនួនផងដែរ ដែលបង្ហាញពីការពិបាករបស់ពួកគេក្នុងការគ្រប់គ្រងពេលវេលាសិក្សាក្នុងអំឡុងពេលសិក្សាតាមអនឡាញនេះផងដែរ(ក្នុងនោះមាន១៦%នាក់) ដែលបញ្ហានេះអាចបណ្តាលមកពីបរិស្ថាននៅជុំវិញខ្លួនរបស់ពួកគេ ឬពួកគេមិនទាន់សម្របខ្លួនបានជាមួយនឹងបរិបទថ្មីនេះ ហើយមួយវិញទៀតអាចមកពីស្ថានភាពជីវភាពគ្រួសាររបស់ពួកគេផងដែរ។

ក្រាហ្វិចទី ១៤ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីការចំណូលចិត្តសម្រាប់ការរៀនតាមអនឡាញ




តាមរយៈក្រាហ្វិច បានបង្ហាញថាក្នុងចំណោមសិស្ស និស្សិត១០០នាក់ គឺមាន៥៩%ដែលចូលចិត្តក្នុងការរៀនតាមអ៊ិនធឺណេត ហើយមាន៤០%ដែលមិនចូលចិត្តក្នុងការសិក្សាតាមប្រព័ន្ធអនឡាញនេះឡើយ។

តាមការបង្ហាញនេះ យើងអាចសន្និដ្ឋានបានថាជាទូទៅមានសិស្ស និស្សិតដែលចូលចិត្តក្នុងការរៀនតាមអ៊ិនធឺណេត ហើយស្របគ្នានោះដែរមួយចំនួនធំក៏មិនចូលចិត្ត ដោយសារតែពួកគេពិបាកសម្របខ្លួន ឬប្រឈមមុខនូវបញ្ហាលំបាកផ្សេងៗ ចំណែកឯអ្នកដែលចូលចិត្ត ពួកគេអាចជាអ្នកដែលធ្លាប់មានបទពិសោធន៍ក្នុងការសិក្សាអនឡាញកន្លងមក ឬពួកគេមើលឃើញឱកាសផ្សេងៗដែលពួកគេអាចទទួលបានក្នុងការរៀនតាមអនឡាញនេះ។

ក្រាហ្វិចទី១៥ ៖ បង្ហាញពីចំនួនសិស្ស និស្សិត ពីលទ្ធផលនៃការសិក្សារបស់ពួកគេក្នុងពេលរៀនតាមអនឡាញ កាលពីឆ្នាំ២០២០




តាមរយៈការបង្ហាញដែលមាននៅក្នុងក្រាហ្វិចទី១៥នេះ គឺបានបញ្ជាក់អំពីលទ្ធផលនៃការសិក្សារបស់សិស្ស និស្សិតទាំង១០០នាក់ ក្នុងអំឡុងពេលដែលពួកគេរៀនតាមអនឡាញកាលពីឆ្នាំសិក្សា២០២០កន្លងទៅ ដែលក្នុងនោះគឺមានមាន៤៦%នៃសិស្ស និស្សិតទទួលបានលទ្ធផលល្អមធ្យម ៣៥%ទទួលបានលទ្ធផលល្អបង្គួរ និង១៨%គឺទទួលបានលទ្ធផលខ្សោយ ហើយមានតែ១នាក់ប៉ុណ្ណោះក្នុងចំណោមអ្នកទាំង ១០០នាក់នេះ ដែលបញ្ជាក់ថាគេទទួលបានលទ្ធផលល្អក្នុងការសិក្សាតាមអនឡាញក្នុងឆ្នាំ២០២០កន្លងទៅ ហើយតាមលទ្ធផលនេះគឺបញ្ជាក់ថាការសិក្សាតាមអ៊ិនធឺណេតគឺ ពិតជាជះឥទ្ធិពលអវិជ្ជដល់គុណភាពនៃការសិក្សារបស់សិស្ស និស្សិតយ៉ាងពិតប្រាដកមែន តែក៏បានបង្ហាញពីការព្យាយាមប្រឹងប្រែងរបស់ពួកគេផងដែរ ទោះជាមិនទទួលបានលទ្ធផលល្អខ្លាំងក្តី តែពួកគេភាគច្រើនគឺធ្វើបាននៅក្នុងកម្រិតមធ្យម បើទោះជាមានផលលំបាកច្រើនក៏ដោយ។

## ៣.៦ លទ្ធផលនៃការស្រាវជ្រាវ

ឆ្លងតាមការសិក្សាស្រាវជ្រាវ ព្រមទាំងធ្វើការស្ទង់មតិលើសិស្ស និស្សិតចំនួន១០០នាក់រួចមក យើងសង្កេតឃើញថា ការផ្លាស់ប្តូរការសិក្សាមករៀនតាមអនឡាញ(E-learning) ពិតជាផ្តល់នូវផលប៉ះពាល់មួយចំនួនធំមកលើសិស្ស និស្សិត និងគ្រូ ព្រមទាំងមកលើវិស័យអប់រំទាំងមូលផងដែរ បន្ថែស្របគ្នានេះដែរ បញ្ហាប្រឈមក៏ដូចជាផលវិបាកទាំងនោះក៏បានផ្តល់ជាផលវិជ្ជមាន និងឱកាសមួយចំនួនមកដល់ សិស្ស និស្សិត គ្រូ ព្រមទាំប្រព័ន្ធអប់រំនៅក្នុងប្រទេសកម្ពុជាទាំងមូលផងដែរ។

### ៣.៦.១ ចំណុចខ្លាំង

ត្បិតតែសិស្ស និស្សិតមួយចំនួនធំកំពុងតែប្រឈមនូវផលពិបាកមួយចំនួន ពីការសិក្សាតាមE-learning នេះក៏ពិតមែន តែស្របគ្នានេះដែរ ពួកគេក៏ទទួលបាននូវឱកាស ក៏ដូចជាបទពិសោធន៍ថ្មីមួយក្នុងការសិក្សាតាម អ៊ិនធឺណេតនេះ។ ខាងក្រោមនេះជាលទ្ធផលដែលជាមតិស្រង់ចេញពីការស្ទង់មតិក្នុងចំណោមសិស្ស និស្សិត ទាំង១០០នាក់ អំពីផលវិជ្ជមានមួយចំនួនដែលពួកគេទទួលបានពីការរៀនតាមអនឡាញក្នុងអំឡុងពេលការរីក រាលដាលនៃជម្ងឺកូវីដ-១៩នេះ៖

- អាចការពារសុវត្ថិភាពរបស់យើងពីជម្ងឺវីរុសដ៏កាចសាហាវនេះ និងងាយស្រួលក្នុងការប្រលង
- ធ្វើឱ្យការសិក្សាមានភាពស្រាវជ្រាវជាងមុននិងស្វែងយល់ខ្លួនឯងច្រើនជាងមុន
- ចំណេញក្នុងការបង់ថ្លៃផ្ទះជួល រាល់ការចំណាយផ្សេងៗត្រូវបានកាត់ បន្ថយ, បានជួយសម្រាលការងារ ឪពុកម្តាយ និងមិនពិបាកធ្វើដំណើរទៅសាលា
- ធ្វើឱ្យយើងចេះសម្របខ្លួនទៅនឹងបរិបទសិក្សាថ្មី, ចេះប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាក្នុងការធ្វើការ ក៏ដូចជា ការបញ្ជូនឯកសារផ្សេងៗទៅកាន់គ្រូ, កាត់បន្ថយហានិភ័យនៃការឆ្លងរាលដាលនៃជំងឺកូវីដ១៩ (ព្រោះ រៀនតែក្នុងផ្ទះ)
- នៅផ្ទះមិនសូវខ្លាចឆ្លងជំងឺ សុខសុវត្ថិភាព និងជួយការងារផ្ទះម៉ាក់បានច្រើន បាននៅជួបជុំគ្រួសារ និង បានយល់ដឹងពីកម្មវិធីថ្មីៗ ដែលទាក់ទងទៅនឹង E-learning
- ចេះរបៀបរៀនតាមonline ស្គាល់ផលវិបាកនៃការរៀន ជួយកាត់បន្ថយការីករាលដាលនៃជំងឺកូវីដ រក្សាគ ម្លាតបានល្អជាងមុន
- ចៀសផុតពីហានិភ័យ ដែលកំពុងមានសព្វថ្ងៃ ងាយស្រួលគ្រប់គ្រងពេលវេលា អាចសិក្សាមុខវិទ្យាដទៃ ទៀតដែលមិនមាននៅក្នុងសាលា
- ចំណេញពេលវេលា បានរៀននូវអ្វីដែលថ្មីទាក់ទងនឹងទម្រង់សិក្សាថ្មីនេះ(E-learning)
- អាចសិក្សាស្រាវជ្រាវដោយខ្លួនឯងបានច្រើន មានពេលវេលាគ្រប់គ្រាន់ មិនចាំបាច់ប្រញាប់ប្រញាល់ទៅ ថ្នាក់រៀនដូចរាល់ដង គួបផ្សំនឹងចរាចរណ៍ដ៏មមាញឹក
- យើងអាចសិក្សាបានគ្រប់ទៅកន្លែង បង្កើនចំណេះដឹងដោយការស្រាវជ្រាវដោយខ្លួនឯង មានការរីកចំរើ នទៅលើប្រព័ន្ធអេឡិចត្រូនិក
- បង្កើនការស្រាវជ្រាវតាមអ៊ីនធើណែត ចេះសមរបខ្លួនទៅតាមបរិបទ។
- កាត់បន្ថយការជួបជុំ ការប្រមូលផ្តុំគ្នា,បានធ្វើស្វ័យសិក្សាដោយខ្លួនឯង,កាត់បន្ថយការចំណាយនានា ពេលមិនបានទៅសិក្សាផ្ទាល់

- មិនបាច់ចំណាយពេលវេលាទៅសាលាផ្ទាល់ ហើយសន្សំការចំណាយមួយចំនួន ហើយក៏ចំណេះដឹងផ្នែកបច្ចេកវិទ្យា ឱ្យស្គាល់និស្សិតយល់ដឹងពីការសិក្សាបែបទំនើប
- ងាយស្រួលសួរគ្រូ video អាចមើលម្តងហើយម្តងទៀតបាន research បានច្រើន មានពេលមើលមេរៀនក្នុងពេលសិក្សា
- ចំណេញ ពេលវេលា មានការយល់ដឹងអំពីផ្នែកបច្ចេកវិទ្យាបានកាន់តែច្រើន សុវត្ថិភាពមិនចាំបាច់ត្រូវទៅសាលា ងាយស្រួល
- បានរៀនសូត្រទោះត្រូវមានជំងឺកូវីដ១៩អាចមានចំណេះដឹងទោះមិនបានពេញលេញតែជាផ្នែកមួយក្នុងការសម្រួលដល់ការសិក្សា
- ជាបទពិសោធន៍ថ្មីសម្រាប់វិស័យអប់រំក្នុងប្រទេសយើងក្នុងការពន្លឿនផ្នែកបច្ចេកវិទ្យា
- ការរៀនតាមE-learningបានផ្តល់ផលវិជ្ជមានដូចជា អាចជួយអោយយើងបានរៀនពីមុខវិជ្ជាខ្លះដែលអាចងាយយល់ ចំណេញពេលវេលា ចំណេញថវិការ
- មានពេលត្រៀមខ្លួនជាការស្រេចមុនចាប់ផ្តើមសិក្សា ព្រមទាំងចេះស្វ័យសិក្សាខ្លួនឯង
- អាចរៀននៅគ្រប់កន្លែងក្រៅពីសាលារៀន មានចំណេះដឹងបន្ថែមអំពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា យល់ដឹងពីរបៀបនៃធ្វើកិច្ចការនឹងធ្វើកិច្ចការឱ្យលោកគ្រូតាមប្រពន្ធ័បច្ចេកវិទ្យា
- មិនចាំបាច់ធ្វើដំណើរទៅសាលាផ្លូវឆ្ងាយ អាចយល់ដឹងពីបច្ចេកវិទ្យា កាត់បន្ថយការចំណាយផ្សេងៗ អាចស្តាប់គ្រូ និងមើលslide បានច្បាស់ប្រសិនinternetដើរបានល្អ( ព្រោះពេលខ្លះនៅសាលាអង្គុយខាងក្រោយពិបាកក្នុងការមើលនិងស្តាប់)។

សរុបមក ដោយយោងតាមការពិនិត្យទៅលើចម្លើយដែលទទួលបានពីសិស្ស និស្សិតចំនួន១០០នាក់នោះគឺបានបង្ហាញឱ្យឃើញថា ក្រៅតែពីបញ្ហាលំបាកផ្សេងៗដែលពួកគេកំពុងជួបប្រទះក្នុងការសិក្សាពីចម្ងាយ (Online)អំឡុងពេលវិបត្តិនៃជម្ងឺកូវីដ-១៩នេះ ពួកគេក៏បានបញ្ជាក់ផងដែរពីផលវិជ្ជមានមួយចំនួនដែលពួកគេទទួលបានពីស្ថានភាពដ៏លំបាកមួយនេះ ដែលភាគច្រើននៃសិស្ស និស្សិតទាំងនោះគឺពួកគេយល់ថាអាចចំណេញពេលវេលាក្នុងការធ្វើដំណើរទៅសាលារៀន ហើយអាចរៀននៅទីកន្លែងផ្សេងៗបានក្រៅតែក្នុងសាលារៀន ព្រមទាំងជួយកាត់បន្ថយហានិភ័យពីការឆ្លងជម្ងឺកូវីដ-១៩បានច្រើនទៀតផង។ លើសពីនេះទៅទៀតពួកគេក៏បានបញ្ជាក់ផងដែរថា ពួកគេអាចធ្វើការសិក្សាស្វែងយល់បន្ថែមពីបច្ចេកវិទ្យា ចេះស្វ័យសិក្សា និងស្រាវជ្រាវបន្ថែមពីអ្វីដែលថ្មីក្រៅតែពីមេរៀនដែលគ្រូដាក់ឱ្យ ហើយអាចបង្កើនចំណេះដឹងបន្ថែមលើប្រព័ន្ធបច្ចេកវិទ្យាដើម្បីត្រៀមខ្លួនសម្រាប់ពេលអនាគត។

### ៣.៦.២ ចំណុចខ្សោយ

យោងតាមការធ្វើការស្ទង់មតិលើសិស្ស និស្សិតចំនួន១០០នាក់ បានបង្ហាញថាសិស្ស និស្សិតពិតជាបានប្រឈមនូវផលលំបាកមួយចំនួនធំ ក្នុងអំឡុងពេលនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដែលការសិក្សារបស់ពួកគេត្រូវផ្លាស់ប្តូរធ្វើឡើងតាមរយៈអនឡាញវិញនោះ។ ខាងក្រោមនេះជាមតិមួយចំនួនដែលបានមកពីសិស្ស និស្សិតទាំង១០០នាក់ទាក់ទងនឹងការលំបាករបស់ពួកគេក្នុងអំឡុងពេលរៀនអនឡាញនេះ៖

- ពិបាកក្នុងការផ្តោតអារម្មណ៍ទៅលើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងពិបាកក្នុងការទំនាក់ទំនងមិត្តរួមថ្នាក់ អំពីកិច្ចការ គ្រូដាក់ឱ្យ ពិបាកក្នុងការយល់ និងដឹងមិនគ្រប់ជ្រុងជ្រោយដូចកាលដែលរៀនក្នុងថ្នាក់ផ្ទាល់។ ឧទាហរណ៍ នៅពេលធ្វើលំហាត់អត់ចេញហើយពិបាកពិភាក្សាព្រោះនៅឆ្ងាយពីមិត្តរួមថ្នាក់ និងលោកគ្រូអ្នក ហើយណាមួយមកពីសេវាអ៊ីនធើណេតមិនសូវមានទៀត
- ចំណេះដឹងមានកម្រិតទាបជាងមុន
- រៀនចាប់មិនសូវបាន អត់មានសេវា ពិបាកសិក្សា internetយឺត រៀនមិនសូវបានល្អ ខ្វល់ខ្វាយច្រើន រៀនបានតិច អ៊ីនធើណេតដើរយឺត ហើយរវល់ការងារផ្ទះច្រើនមិនសូវផ្តោតអារម្មណ៍និងការសិក្សា
- មិនបានរៀននៅសាលាផ្ទាល់,រៀនមិនសូវបានពេញលេញ ដោយសារនៅក្នុងតំបន់គ្មាន internet(អត់សេវា) និស្សិតនៅតាមខេត្តមានការលំបាកទៅលើបញ្ហាអ៊ីនធើណេត(រអាក់រអួលពិបាករៀន), រៀនតាមអនឡាញមិនសូវយល់ដូចរៀនក្នុងថ្នាក់ផ្ទាល់, ចំណាយប្រាក់ច្រើនទៅលើការទិញកាតបញ្ចូលទូរស័ព្ទ, គ្មានសមាធិក្នុងការរៀន
- រៀនចប់គ្រប់តាមគោលការណ៍របស់សាលា ប៉ុន្តែមិនសូវមានគុណភាព វាមាននៅខ្វះចន្លោះមួយចំនួន
- មានផលប៉ះពាល់ខ្លាំងដល់ការសិក្សានឹងមួយចំនួនទៀតវាប៉ះពាល់ដល់សេដ្ឋកិច្ចទាំងមូលនៅទូទាំងប្រទេស
- ប៉ះពាល់ដល់ការសិក្សា សិស្សមិនសូវចាប់អារម្មណ៏លើការរៀនសូត្រ
- បាត់បង់ធនធានមនុស្សបន្តិចម្តងៗ
- ពេលរៀននៅផ្ទះពិបាកណាស់ រៀនមិនសូវចូល គ្មានពេលទំនេរគ្រប់គ្រាន់ និងគ្មានសៀវភៅមើលមេរៀនគ្រប់គ្រាន់ទេ
- មិនមានឯកសារ ឬសៀវភៅគ្រប់គ្រាន់សម្រាប់សិក្សាស្រាវជ្រាវទេក្នុងអំឡុងពេល Covid 19 នេះ
- ពិបាកសម្របនៅពេល សិស្សមួយចំនួនមិនយកចិត្តទុកដាក់ហើយបង្កសម្លេងរំខាន
- ពិបាកក្នុងការចូលរួមឆ្លើយឆ្លងជាមួយគ្រូ ការសិក្សាមិនបានពេញលេញ(ដោយសារinternet)

- មានការលំបាកក្នុងការប្រឡងប្រចាំខែ ផលប្រព័ន្ធអ៊ិនធឺណេតរបស់អ្នកគ្រូលោកគ្រូមិនសូវល្អ ដោយសារតែគាត់មិនសូវចេះប្រើប៉ុន្មាន
- មាបញ្ហាជីវភាព ខ្វះខាតសម្ភារៈប្រើប្រាស់
- មិនមានពេលស្តាប់គ្រូពន្យល់ភ្លាមៗ ពេលឆ្លល់ឱ្យបានគ្រប់គ្រាន់ទេ,បញ្ហាសេវាប្រព័ន្ធអ៊ិនធឺណេតតាមទីតំបន់នីមួយៗ គ្រប់និស្សិតទាំងអស់ក៏មិនប្រាកដថាគាត់មានសម្ភារៈគ្រប់គ្រាន់សម្រាប់ការសិក្សាពីចម្ងាយដែរ,មិនសូវមានសកម្មភាពរៀនសូត្រទេ
- ការទទួលបាននូវចំណេះដឹងមានកម្រិត ខ្វះសៀវភៅសម្រាប់អានបន្ថែម មិនសូវមានពេល ត្រូវជួយធ្វើការផ្ទះម៉ាក់ប៉ា និយាយរួមគឺនៅគ្មានភាពស្ងៀមស្ងាត់
- បញ្ហាសេដ្ឋកិច្ច, បញ្ហាសុខភាពផ្លូវចិត្ត
- ទទួលបានចំណេះដឹងបានតិច ពិបាកក្នុងការពិភាក្សាជាក្រុម ប្រលងក៏ពិបាក មិនសូវមានការយកចិត្តទុកដាក់ដូចនៅក្នុងថ្នាក់ ភាគច្រើនគឺមិនសូវចេះទោះបីonlineរឺofflineក៏ដោយ មិនសូវមានការផ្តោតអារម្មណ៍លើរៀនច្រើនទេ គឺមិនដូចនៅសាលា
- មិនមានការពិភាក្សារគ្នារវាងលោកគ្រូ និង សិស្សឱ្យបានស៊ីជម្រៅទាក់ទង ទៅនឹងមេរៀន ពីព្រោះពេលវេលាតិច មិនមានការចូលរួមពីសិស្ស និស្សិតច្រើនទេ នៅក្នុងការបង្រៀន
- រៀនខ្សោយជាងមុន
- ពិបាកក្នុងការត្រូវជួប ឬពិភាក្សាគ្នាពេលមានកិច្ចធ្វើជាក្រុម
- ផ្តល់ផលវិបាកដោយសារការរៀនពីចម្ងាយគឺយើងត្រូវរៀនដោយប្រើSmart phone ហើយសម្រាប់នៅតាមស្រុកស្រែជនបទគឺមិនសូវមានinternet សម្រាប់រៀនពេលខ្លះគឺត្រូវផ្អាករយៈពេលពីរបីថ្ងៃដោយសារគ្មានinternet ហើយជួនកាលមានភ្លៀងផ្គររន្ទះសិស្សខ្លះក៏មិនសូវបានរៀនព្រោះខ្លាចដូចនេះហើយគឺធ្វើឱ្យខាតពេលវេលាសម្រាប់សិក្សាជាច្រើន ហើយអ្នកខ្លះទៀតដោយគ្រួសារខ្វះខាតក៏មិនមាន Smart Phone សម្រាប់រៀនដូចគេ ហើយបញ្ហាមួយទៀតគឺលោកគ្រូអ្នកគ្រូដែលគាត់ចាស់ៗគឺពួកគាត់មិនចេះប្រើប្រាស់smart phoneដើម្បីបង្រៀនសិស្សពីចម្ងាយ ហើយចំណែកឯសិស្សខ្លះទៀតពោលគឺមិនសូវយកចិត្តទុកដាក់ទៅលើការរៀនពីចម្ងាយ(ដោយគិតថាវាអត់ប្រយោជន៍ ទោះជារៀនក៏រៀនមិនចេះ)
- គ្រូមិនសូវយកចិត្តទុកដាក់ដូចរៀនផ្ទាល់
- កុមារមានភាពទទួលបានចំណេះដឹងមិនស្មើគ្នា កុមារនៅទីក្រុងបានរៀនពីចម្ងាយ តែនៅជនបទមិនបានរៀនគ្រប់គ្រាន់ គ្រួសារគ្មានលិទ្ធភាព គ្មាថ្នាក់អនឡាញ មិនយល់ដឹងពីប្រព័ន្ធអ៊ីនធើណេត

- ខ្ជិលរៀនជាងមុន
- ចំណាយថវិការច្រើនជាងមុនលើអ៊ិនធឺណេត
- មិនទាន់បានសម្របខ្លួនជាមួយនឹងការរៀនអនឡាញនៅឡើយទេ
- ប្រឈមមុខនិងកាប្រឡងបាកឌុបធ្លាក់ព្រោះឆ្នាំត្រូវប្រឡងហើយមិនសូវបានរៀន
- គ្មានពេលវេលាគ្រប់គ្រាន់
- ថ្លៃសិក្សាគ្មានការបញ្ចុះតម្លៃខ្លះក្នុងអំឡុងពេលលំបាកនេះ ទាំងដែលសិស្សជាអ្នករាប់រងគ្រប់យ៉ាងសម្រប់ការសិក្សាទាំងមូល ហើយលទ្ធផលដែលសិស្សទទួលបានគឺមានកម្រិតទាបជាងការរៀនក្នុងថ្នាក់។

ជារួមមកក្រោយពីធ្វើការសិក្សាលើមតិដែលទទួលបានពីសិស្ស និស្សិតរួចមកអាចឱ្យយើងសន្និដ្ឋានបានថា នៅក្នុងអំឡុងពេលនៃការសិក្សាតាមប្រព័ន្ធអ៊ិនធឺណេត យើងឃើញថា សិស្ស និស្សិតភាគច្រើនប្រឈមនូវបញ្ហាពិបាកផ្សេងៗគ្នាអាស្រ័យទៅតាមតំបន់ដែលពួកគេរស់នៅ មួយចំនួនធំហើយដែលមានបញ្ហាទាក់ទងទៅនឹងអ៊ិនធឺណេត ពោលគឺពិបាកក្នុងការរៀនដោយសារតែអ៊ិនធឺណេតរបស់ពួកគេដើរយឺត ឬខ្សោយដាច់។ ក្រៅពីនេះយើងក៏ឃើញមាននូវបញ្ហាមួយចំនួនទៀតដូចជាការពិបាកផ្តោតអារម្មណ៍ក្នុងការសិក្សា មិនមានពេលវេលាគ្រប់គ្រាន់ ខ្វះខាតសម្ភារៈ មិនសូវចេះប្រើបច្ចេកវិទ្យា ព្រមទាំងធ្វើឱ្យការសិក្សារបស់ពួកគេមានការធ្លាក់ចុះជាងមុនទៀតផង។

# សេចក្តីសន្និដ្ឋាន និង
# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី "**ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ**" មកពួកខ្ញុំបានស្វែងយល់ ទទួលបាននូវចំណេះដឹងថ្មីៗទាក់ទងទៅនឹងផលប៉ះពាល់ផ្សេងៗទៅលើវិស័យអប់រំ ដោយសារតែជម្ងឺរាតត្បាតកូវីដ-១៩។ ការរីករាលដាលនៃជម្ងឺកូវីដ-១៩បានធ្វើឱ្យគ្រឹះស្ថានសិក្សាមួយចំនួនធំនៅតាមបណ្តាប្រទេសទូទាំងពិភពលោកបានត្រូវបិទទ្វា ហើយផ្លាស់ប្តូរការសិក្សាមកធ្វើតាមប្រព័ន្ធអ៊ិនធឺណេតជំនួសវិញ។ បើចំពោះប្រទេសអភិវឌ្ឍន៍ដែលជឿនលឿនស្រាប់លើផ្នែកបច្ចេកវិទ្យានេះ គឺគេឃើញថាមិនមានជាបញ្ហាចោទអ្វីច្រើននោះទេ តែផ្ទុយមកវិញចំពោះប្រទេសដែលកំពុងអភិវឌ្ឍន៍គឺពិតជាទទួលរងនូវផលប៉ះពាល់ ក៏ដូចជាផលវិបាកជាច្រើនចំពោះវិស័យអប់រំនៅក្នុងប្រទេសរបស់ខ្លួន។

ជាក់ស្តែងប្រទេសកម្ពុជាយើងផ្ទាល់ក៏ជាប្រទេសមួយដែលកំពុងតែទទួលរងនូវវិបត្តនៃជម្ងឺកូវីដ-១៩នេះ ដែលគ្រឹះស្ថានសិក្សានៅទូទាំងប្រទេសត្រូវបានបិទ ហើយត្រូវបន្តការសិក្សាតាមប្រព័ន្ធអនឡាញ(E-learning)វិញ។ បើយើងក្រឡេកមកមើលវិស័យអប់រំនៅក្នុងប្រទេសកម្ពុជា គឺឃើញថាប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡាបានកំពុងប្រឹងប្រែងយ៉ាងខ្លាំងដើម្បីអភិវឌ្ឍន៍លើវិស័យអប់រំឱ្យស្របទៅនឹងយុគ្គសម័យឌីជីថល ហើយដើម្បីត្រៀមខ្លួនឱ្យសមទៅនឹងបដិវត្តន៍ឧស្សាហាកម្ម៤.0 ដោយក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍន៍សមត្ថភាពសិស្ស ក៏ដូចជាបញ្ចូលនូវកម្មវិធីសិក្សាថ្មីៗដែលផ្តោតទៅលើផ្នែកបច្ចេកវិទ្យាដែលរួមមាន ICT និងSTEM ជាដើម។ យ៉ាងណាមិញក្នុងបរិបទនៃជម្ងឺឆ្លងកូវីដ-១៩ គឺការអប់រំត្រូវបានផ្លាស់ប្តូរភ្លាមៗ ដោយតម្រូវឱ្យការបង្រៀន និងរៀនគឺត្រូវធ្វើឡើងតាមរយៈអនឡាញ(E-learning) ដែលនេះគឺពិតជាផ្តល់ផលពិបាកយ៉ាងច្រើនសម្រាប់សិស្ស និស្សិត និងគ្រូ ជាពិសេសគឺអ្នកដែលនៅតាមទីជនបទ។ ដោយហេតុថាទាំងសិស្ស និស្សិត ព្រមទាំងគ្រូផងនោះគឺមិនទាន់មានបទពិសោធន៍គ្រប់គ្រាន់នៅឡើយក្នុងការសិក្សា ក៏ដូចជាបង្រៀនតាមអ៊ិនធឺណេតនេះ ហើយបញ្ហាប្រឈមរួមជាមួយនឹងផលវិបាកមួយចំនួនធំគឺមានសម្រាប់ពួកគេដែលជាហេតុធ្វើឱ្យគុណភាពអប់រំក្នុងប្រទេសកម្ពុជាមានការធ្លាក់ចុះ។ បញ្ហាទាំងនេះបានបង្អាក់ នូវការអភិវឌ្ឍន៍ធនធានមនុស្ស សេដ្ឋកិច្ចជាតិ ជាពិសេសនោះគឺ ទៅលើការអភិវឌ្ឍន៍ប្រទេសជាតិទាំងមូលតែម្តង។ ដើម្បីឆ្លើយតបទៅ នឹង បញ្ហាទាំងនេះ ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជា ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំស្វះស្វែង ដើម្បីដោះស្រាយរាល់បញ្ហាដែលកើតមានឡើងក្នុងអំឡុងកាលជម្ងឺរាលត្បាតកូវីដ១៩នេះ ដូចជាការបង្រៀនពីចម្ងាយ (E-learning) តាមរយៈកម្មវិធីមួយចំនួនដូចជា; Zoom, Facebook Group chat, google meeting, Microsoft Team ជាដើម ដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស-និស្សិត។ ទោះបីជាមានដោះស្រាយមួយចំនួនហើយក្តី បញ្ហាមួយចំនួននៅតែកើតមានឡើងសម្រាប់សិស្ស-និស្សិត ដោយសារតែការមិនបានសិក្សាស្វែងយល់ឱ្យបានច្រើនពីប

បច្ចេកវិទ្យា អ៊ិនធឺណេត និងកង្វះសម្ភារៈបច្ចេកវិទ្យាសម្រាប់សិស្ស-និស្សិតដែលមានជីវភាពក្រីក្រ ក៏ដូចជាសិស្ស-និស្សិតដែលនៅទីជនបទ។

ស្របគ្នានេះដែរ ឱកាសថ្មីៗក៏ដូចជាបទពិសោធន៍ថ្មីៗ ក៏មានសម្រាប់ពួកគេផងដែរ។ ការអប់រំនៅក្នុងប្រទេសកម្ពុជាគឺកំពុងតែធ្វើការអភិវឌ្ឍន៍ខ្លួនដើម្បីឆ្ពោះ ទៅរកបដិវត្តន៍ឧស្សាហកម្ម៤.០នាពេលអនាគត ហើយនេះគឺជាឱកាសដ៏ល្អមួយសម្រាប់សិស្ស និស្សិត និងគ្រូក្នុងការរៀនសម្របខ្លួន និងទទួលយកបទពិសោធន៍ថ្មី ពោលគឺវាជួយលើការពន្លឿនក្នុងការចាប់យកនូវបច្ចេកវិទ្យា និងការកែទម្រង់លើវិស័យអប់រំដ៏សមស្របមួយសម្រាប់សម្រាប់ត្រៀមខ្លួននាពេលអនាគតផងដែរ។ ត្បិតតែមានផលប៉ះពាល់ និងការលំបាកច្រើនចំពោះសិស្ស និស្សិត និងគ្រូ តែការសិក្សាតាមប្រព័ន្ធអនឡាញនេះក៏ជាវិធីសាស្ត្រមួយដែលល្អហើយអាចឱ្យសិស្ស និស្សិតធ្វើការស្រាវជ្រាវព័ត៌ទាក់ទងទៅនឹងមេរៀនកាន់តែមានភាពសម្បូរបែបថែមទៀតផង។

**អនុសាសន៍**

បច្ចុប្បន្នវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាគឺមានភាពល្អប្រសើរឡើងគួរឱ្យកត់សម្គាល់ ដោយមានការកំណែទម្រង់វិស័យអប់រំលើមធ្យមសិក្សា។ថ្វីត្បិតតែការរីករាលដាលនៃជម្ងឺកូវីដ-១៩ បានធ្វើឱ្យប្រទេសកម្ពុជាទទួលរងនូវផលប៉ះពាល់ និងផលវិបាកមួយចំនួនធំមកដល់វិស័យអប់រំ ពោលគឺសិស្ស និស្សិ និងគ្រូមានការលំបាកក្នុងការសម្របខ្លួនក្នុងបរិបទសិក្សាតាមប្រព័ន្ធអ៊ិនធឺណេតនេះ តែស្របគ្នានោះដែរវាក៏ជាឱកាសមួយសម្រាប់វិស័យអប់រំក្នុងប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍន៍ខ្លួនឱ្យស្របទៅនឹងបដិវត្តន៍ឧស្សាហកម្ម៤.០ផងដែរ។ ក្រសួងអប់រំយុវជននិងកីឡាបានធ្វើអ្វីៗជាច្រើនដើម្បីផ្តល់ដល់និស្សិត ជាមួយនឹងឱកាសដើម្បីបន្តការសិក្សារបស់ពួកគេក្នុងពេលមានការរាតត្បាតជម្ងឺកូវីដ-១៩នេះផងដែរ។ ទោះយ៉ាងណាក៏ដោយការទទួលបានមេរៀន និងធនធានតាមអ៊ិនធឺរណេតនៅតែជាបញ្ហាសម្រាប់សិស្សមកពីគ្រួសារក្រីក្រ។

ប៉ុន្តែដោយឡែកការអប់រំនៅក្នុងបរិបទនៃជម្ងឺរាតត្បាតកូវីដ១៩ វិស័យអប់រំ មានការប្រែប្រួលដោយក្រសួងអប់រំ យុវជន និងកីឡា តម្រូវឱ្យសិស្ស-និស្សិតត្រូវសិក្សាតាមចម្ងាយ (Online) ដោយហេតុធ្វើឱ្យមានផលប៉ះពាល់មួយចំនួនធំដើម្បីចូលរួមក្នុការដោះស្រាយលើផលពិបាកដែលវិស័យអប់រំនៅក្នុងប្រទេសកម្ពុជាកំពុងតែប្រឈមនៅក្នុងអំឡុងពេលការរីករាលដាលនៃជម្ងឺកូវីដ-១៩នេះ ក្រុមរបស់យើងខ្ញុំសូមចូលរួមផ្តល់អនុសាសន៍ដូចតទៅ៖

- ពង្រឹងការសិក្សារបស់សិស្ស-និស្សិតឱ្យបានទៀងទាត់ ទាក់ទងនឹងអវត្តមាន
- ពង្រឹងការទំនាក់ទំនងរវាង សិស្ស-និស្សិត ជាមួយ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ
- ក្រសួងអប់រំ យុវជន និងកីឡា គួរតែពិចារណាធ្វើការជាមួយនាយកសាលានិងប្រធានសហគមន៍ដើម្បីស្វែងរក និងស្នើសុំជំនួយពីគ្រួសារណាដែលមានទូរទស្សន៍ច្រើនជាងមួយ។ ប្រសិនបើវិធីសាស្ត្រនេះមិន

ដំណើរការទេក្រសួងអប់រំយុវជននិងកីឡានិងអាជ្ញាធរមូលដ្ឋានគួរពិចារណាទិញទូរទស្សន៍មួយឈុត ដំឡើងនៅកន្លែងដែលមានសុវត្ថិភាពគ្រប់គ្រាន់ និងរៀបចំដោយសាលារៀនដើម្បីអនុញ្ញាតឱ្យមានក្រុមតូចៗរបស់កុមារដើម្បីរៀនពីមេរៀនតាមទូរទស្សន៍

- សម្រាប់សិស្សដែលអវត្តមានជាញឹកញាប់ គ្រូអាចមកលេងផ្ទះរបស់ពួកគេដើម្បីផ្តល់ការបញ្ជាក់ និងជំនួយបើចាំបាច់។ ធ្វើអន្តរាគមន៍ និងការលើកទឹកចិត្តដល់ឪពុកម្តាយមួយចំនួនដែលមានទំនោរស្នើសុំកូន ៗ របស់ពួកគេឱ្យជួយជាមួយការងារនៅផ្ទះឬនៅកសិដ្ឋាន ឪពុកម្តាយទាំងនោះគួរតែជាលើកទឹកចិត្តឱ្យកូនប្រុសស្រីរបស់ពួកគេទៅប្រមូលយកការងារផ្ទះពីគ្រូរបស់ពួកគេដើម្បីធ្វើការសិក្សាដោយខ្លួនឯង ហើយជំរុញឱ្យកូន ៗ របស់ពួកគេបន្តការសិក្សារបស់ពួកគេក្នុងកំឡុងពេលនៃក្របទី ១៩ការរាតត្បាតសកល
- ទាក់ទងនឹងកង្វះនៃការចូលរួមមេរៀនជាមួយគ្រូ, ក្រសួងអប់រំ យុវជន និងកីឡាគាំទ្រដោយមន្ទីរអប់រំក្នុងតំបន់នាយកសាលា និងគ្រូបង្រៀនថ្នាក់រៀនគួរពិភាក្សាពីលទ្ធភាពនៃការផ្តល់ការបណ្តុះបណ្តាលបន្ថែមដល់សិស្សដែលមិនអាចចូលរួមពេញលេញក្នុងការសិក្សាពីចម្ងាយក៏ដូចជាការសិក្សាដោយខ្លួនឯង ។

# ឯកសារយោង

# ឯកសារយោង

## ភាសាខ្មែរ

ក្រសួងអប់រំ យុវជន និងកីឡា. *អប់រំកុមារតូច*. អាចរកបាននៅ http://moeys.gov.kh/index.php/kh/early-childhood-education.html#.YJYKDNUzbIU (ចូលទស្សនាថ្ងៃទី១៨ ឧសភា ២០២១) ។

ក្រសួងអប់រំ យុវជន និងកីឡា. អាចរកបាននៅ https://www.moeys.gov.kh/index.php/kh/about-us.html#.YRtM-ogzZPZ (ចូលទស្សនាថ្ងៃទី៦ ឧសភា ២០២១) ។

ច្បាប់ស្តីពីការអប់រំ, លេខ នស/រកម/១២០៧/០៣២. ១៩ ធ្នូ ២០០៧។

នឿន វ (២០២០) តើអ្វីទៅជា eLearning. *BizKhmer*. អាចរកបាននៅ https://www.bizkhmer.com/articles/75605 (ចូលទស្សនាថ្ងៃទី៦ ឧសភា ២០២១) ។

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩ - ២០២៣.* ក្រសួងអប់រំ យុវជន និងកីឡា (ចូលទស្សនាថ្ងៃទី៥ មេសា ២០២១)។

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០២១) *របាយការណ៍ពិស្តាស្តីពីការអប់រំក្រៅប្រព័ន្ធឆ្នាំ២០២០*. ក្រសួងអប់រំ យុវជន និងកីឡា (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២១)។

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន (២០១៨). *ឯកសារ ស្តីពី យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និង កីឡា ២០១៨-២០២៣*, ក្រសួងអប់រំ យុវជន និងកីឡា. អាចរកបាននៅ https://www.moeys.gov.kh/index.php/kh/policies-and-strategies/3885.html#.YSmu-I4zZPY (ចូលទស្សនាថ្ងៃទី១៨ មេសា ២០២១)។

សេចក្តីប្រកាសព័ត៌មានស្តី ពីការអនុវត្តវិស្សមកាលតូចមុនកាលកំណត់សម្រាប់គ្រឹះស្ថានសិក្សាចំណេះទូទៅសាធារណៈ និងឯកជននៅរាជធានីភ្នំពេញ និងក្រុងសៀមរាប. *ក្រសួងអប់រំ យុវជន និងកីឡា*.

អាចរកបាននៅ

https://www.facebook.com/moeys.gov.kh/photos/a.308228509203770/3446757862017470/?type=3&theater (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២១)។

សាលារៀនមួយចំនួន ចាប់ផ្ដើមបើកទ្វារបង្រៀនវិញហើយ ក្រោយបិទទ្វារ៦ខែ. ២០២០. *ក្រសួងអប់រំ យុវជន និង កីឡា*. អាចរកបាននៅ

https://www.moeys.gov.kh/index.php/kh/dgaf/3946.html#.YMSzqNUzbIV (ចូលទស្សនាថ្ងៃទី ១៤ មិថុនា ២០២១)។

សារឌី (២០១៨) សម័យសាធារណរដ្ឋ ខ្មែរឆ្នាំ១៩៧០-១៩៧៥. *KhmerDeng*. អាចរកបាននៅ https://khmerdeng.com/khmerpublic/ (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២១) ។

សម្ដេចព្រះសង្ឃរាជ ជួន ណាត, វចនានុក្រមខ្មែរ។

ហេតុអ្វីចាំបាច់ត្រូវរៀនតាម E-learning? (២០១៧) *ឡារ៉ែន*. អាចរកបាននៅ https://www.lareine.com.kh/news/education/1777/ (ចូលទស្សនាថ្ងៃទី២ ឧសភា ២០២១) ។

## ភាសាបរទេស

All public and private educational institutions in Cambodia suspended (2021). *Khmer Times*. អាចរកបាននៅ

https://www.khmertimeskh.com/50827832/all-public-and-private-educational-institutions-in-cambodia-suspended/ (ចូលទស្សនាថ្ងៃទី៥ ឧសភា ២០២១) ។

Cambodia's rural students left behind in distance learning (2020). *New Straits Times*. អាចរកបាននៅ https://www.nst.com.my/world/region/2020/05/589197/cambodias-rural-students-left-behind-distance-learning (ចូលទស្សនាថ្ងៃទី៦ មិថុនា ២០២១) ។

Cambodia's failing education system (2020). *The ASEAN Post*. អាចរកបាននៅ

https://theaseanpost.com/article/cambodias-failingeducation-system (ចូលទស្សនាថ្ងៃទី២ មិថុនា ២០២១) ។

Cambodia's rural students left behind in distance learning (2020). *New Straits Times*. អាចរកបាននៅ https://www.nst.com.my/world/region/2020/05/589197/cambodias-rural-students-left-behind-distance-learning (ចូលទស្សនាថ្ងៃទី៥ ឧសភា ២០២១) ។

COVID-19 Responsein Cambodia Building Back Better. *UNESCO*. អាចរកបាននៅ https://www.coursehero.com/file/80090309/unesco-covid-19-response-in-cambodiapdf/ (ចូលទស្សនាថ្ងៃទី២៥ មេសា ២០២១) ។

Distance learning solutions. *UNESCO*. អាចរកបាននៅ https://en.unesco.org/covid19/educationresponse/solutions (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២១) ។

Fry G. និង H Bi (2013). *The evolution of educational reform in Thailand: The Thai educational paradox* [ការវិវត្តនៃកំណែទម្រង់អប់រំនៅប្រទេសថៃ៖ ភាពផ្ទុយគ្នានៃការអប់រំថៃ]. Journal of Educational Administration, Vol. 51/3, pp. 290-319. (ចូលទស្សនាថ្ងៃទី១១ មិថុនា ២០២១) ។

Flynn G. និង Himel J (2020). School closures highlight inequality in education as classes move online. Cambodianess. អាចរកបាននៅ https://cambodianess.com/article/school-closures-highlight-inequality-in-education-as-classes-move-online (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២១) ។

Globalteer. Free education for 300 children in rural Cambodia. *Global Giving*. អាចរកបាននៅ https://www.globalgiving.org/projects/free-education-for-300-children-in-cambodia/ (ចូលទស្សនាថ្ងៃទី១១ មិថុនា ២០២១) ។

Julia K. Liên B និង Chris N. (2018). The child poverty report in cambodia summary report. អាចរកបាននៅ https://www.unicef.org/cambodia/media/1496/file/Child%20poverty%20report%20in%20Cambodia_Full%20Report_Eng.pdf (ចូលទស្សនាថ្ងៃទី១០ មិថុនា ២០២១) ។

Justhine U. (2020) Cambodia to reopen schools — full list. *AEC News Today*. អាចរកបាននៅ https://aecnewstoday.com/2020/cambodia-to-reopen-schools-full-list/ (ចូលទស្សនាថ្ងៃ៦ ឧសភា ២០២១) ។

Key Issues affecting Youth in Cambodia. OECD. អាចរកបាននៅ https://www.oecd.org/dev/inclusivesocietiesanddevelopment/youthissues-in-cambodia.htm (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២១) ។

Office of the Permanent Secretary (2014). *Educational Statistics in Brief 2013* [ស្ថិតិអប់រំសង្ខេបឆ្នាំ ២០១៣], Office of the Permanent Secretary, Ministry of Education of Thailand, Bangkok.

Pech S. (2020). E-Learning moves to TV. *Khmer Times*. អាចរកបាននៅ https://www.khmertimeskh.com/50715186/e-learning-moves-to-tv/ (ចូលទស្សនាថ្ងៃទី១១ មិថុនា ២០២១) ។

Prigent S. (2019). Education for All′in Cambodia: Democratic Educational and Children′s Empowerment Global Values Facing State Patronage. The Asia Pacific Journal of Anthropology, 20(1), 1-21. អាចរកបាននៅ https://doi.org/10.1080/14442213.2018.1548643 (ចូលទស្សនាថ្ងៃទី ១២ មិថុនា ២០២១) ។

Riccardo C. Robert E. Flinn. និង Patchanee T. (2019). *Can ICT Help Cambodian Students Become the Solution for Improving Education in the Country*. Research paper. Paragon International University, Cambodia និងChiang Mai University, Thailand. អាចរកបាននៅ https://jomeino.com/journal/can-ict-help-cambodian-students-become-solution-improving-education-country (ចូលទស្សនាថ្ងៃទី១៥ ឧសភា ២០២១)។

Riccardo C. និង Patchanee T. (2009). Teachers' Motivation and Quality Education Represent the Key for the Change in Cambodia [ការជម្រុញទឹកចិត្តគ្រូបង្រៀននិងការអប់រំប្រកបដោយគុណភាព តំណាងឱ្យគន្លឹះនៃការផ្លាស់ប្តូរនៅកម្ពុជា]. Conference paper, The 4th Thailand International College Consortium (TICC) ។

Secondary Education Regional Information Base: Country Profile – Thailand. (2016). *Education in Thailand*. (ចូលទស្សនាថ្ងៃទី២៩ មេសា ២០២១) ។

UNESCO និង IBE (2011). Thailand [ប្រទេសថៃ]. World Data on Education, 7th edition, UNESCO and International Bureau of Education.

UNESCO-UIS (2015). UIS data center website. អាចរកបាននៅ http://uis.unesco.org/ (ចូលទស្សនាថ្ងៃទី២៨ មិថុនា ២០២១) ។

WHO works closely with the Royal Government of Cambodia in the fight against COVID-19 (2020). *World Health Organization. World Health Organization*. អាចរកបាននៅ https://www.who.int/cambodia/news/detail/12-05-2020-who-works-closely-with-the-royal-government-of-cambodia-in-the-fight-against-covid-19 (ចូលទស្សនាថ្ងៃទី២៥ មេសា ២០២១) ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១ : កម្រងសំណួរស្ទង់មតិ

## កម្រងសំណួរស្ថិតិចំពោះផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ ទៅលើវិស័យអប់រំ

ពួកយើងខ្ញុំជាក្រុមនិស្សិតផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ចុះមកធ្វើការស្រាវជ្រាវលើប្រធានបទមួយស្តីអំពី "ផលប៉ះពាល់នៃជម្ងឺកូវីដ-១៩ មកលើវិស័យអប់រំ"។ ដោយសារតែការរាតត្បាតនៃជម្ងឺកូវីដ-១៩, សាលារៀននៅទូទាំងប្រទេសត្រូវបានបិទ ការសិក្សាត្រូវធ្វើឡើងពីចម្ងាយ ឬE-learningវិញ។ ការស្ទង់មតិនេះធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់បន្ថែមលើបញ្ហាប្រឈមផ្សេងៗដែលសិស្សនិស្សិតកំពុងតែជួបប្រទះ ក្នុងការរៀនតាមអនឡាញ នៅអំឡុងពេលកូវីដ-១៩នេះ ។

អាស្រ័យដូចបានរៀបរាប់ខាងលើ សូមឱ្យលោកអ្នកមេត្តាជួយបំពេញនូវកម្រងសំណួរមួយចំនួនដែលពាក់ព័ន្ធទៅនឹង ការយល់ឃើញ ក៏ដូចជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកទាំងអស់គ្នា។ យើងខ្ញុំសូមសន្យាថារាល់ចម្លើយរបស់លោកអ្នកនឹងត្រូវបានរក្សានូវការសម្ងាត់ ហើយចម្លើយនេះគឺត្រូវបានប្រើប្រាស់សម្រាប់គម្រោងនៃការស្រាវជ្រាវរបស់យើងខ្ញុំ ក៏ដូចជាផ្តល់ជាអនុសាសន៍ សម្រាប់អ្នកដែលរៀនអនឡាញផងដែរ។

សូមអរគុណសម្រាប់ការចូលរួម

1. ភេទ
   - o ប្រុស
   - o ស្រី
2. អាយុ
   - o ១៥-១៨ ឆ្នាំ
   - o ១៩-២១ ឆ្នាំ
   - o ២២-២៦ ឆ្នាំ
   - o ចាប់ពី ២៧ឆ្នាំឡើងទៅ
3. បច្ចុប្បន្ន, តើអ្នកកំពុងប្រកបការងារអ្វី?
   - o ជាសិស្ស/និស្សិត

- o ធ្វើការ
- o ទាំងពីរខាងលើ

4. កន្លងមក តើអ្នកធ្លាប់មានបទពិសោធន៍ក្នុងការសិក្សាពីចម្ងាយ(អនឡាញ)/E-learning ដែរឬទេ?
   - o ធ្លាប់
   - o មិនធ្លាប់
5. ប្រសិនបើអ្នកជាសិស្ស-និស្សិត, តើអ្នកកំពុងសិក្សាក្នុងកម្រិតអ្វី?
   - o វិទ្យាល័យ
   - o សាកលវិទ្យាល័យ
   - o បានបញ្ចប់ការសិក្សា
6. តើអ្នកមានអារម្មណ៍យ៉ាងដូចម្ដេចចំពោះការអប់រំពីចម្ងាយ/E-learning? (សន្មតថា ១០ល្អណាស់ ហើយ ១មិនល្អទេ)

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

7. តើអ្នកមានលទ្ធភាពប្រើឧបករណ៍សម្រាប់រៀនតាមអ៊ិនធឺណេតដែរឬទេ?
   - o មាន
   - o មាន, ប៉ុន្តែដំណើរការមិនសូវល្អ
   - o មិនមានទេ
8. តើនៅផ្ទះរបស់អ្នកមានអ៊ិនធឺណេតគ្រប់គ្រាន់សម្រាប់រៀនដែរឬទេ?
   - o មាន
   - o មានតែពិបាកប្រើប្រាស់
   - o មិនមានទេ
9. បើប្រៀបធៀបទៅនឹងការសិក្សាផ្ទាល់នៅក្នុងថ្នាក់ តើអ្នកមានពេលវេលាក្នុងការសិក្សាច្រើនជាងពេលមុនដែរឬទេ?
   - o មាន

- o មិនសូវមានទេ(ព្រោះពិបាកផ្តោតអារម្មណ៍ក្នុងការរៀន)
- o មិនមានទេ

10. ក្នុងអំឡុងពេលរៀនតាមប្រព័ន្ធអេឡិចត្រូនិច/E-learning, តើអ្នកគិតថាបញ្ហាអ្វីដែលអ្នកប្រឈមខ្លាំងបំផុត?
    - o ការសម្របខ្លួន
    - o អ៊ិនធឺណេត (Internet)
    - o ខ្វះសម្ភារៈ
    - o ចំណេះដឹងផ្នែកបច្ចេកវិទ្យា និងជំនាញ
11. តើក្នុងមួយថ្ងៃអ្នកចំណាយពេលប៉ុន្មានជាមធ្យមទៅលើការអប់រំពីចម្ងាយ?
    - o 1-3 ម៉ោង
    - o 3-5 ម៉ោង
    - o 5-7 ម៉ោង
    - o ច្រើនជាង 7ម៉ោង
12. តើការរៀនសូត្រពីចម្ងាយ/E-learning ក្នុងអំឡុងពេលកូវីដ-១៩នេះ មានប្រសិទ្ធភាពយ៉ាងណាសម្រាប់អ្នក? (សន្មតថា១០ មានប្រសិទ្ធភាពណាស់ ហើយ១ គ្មានប្រសិទ្ធភាពទេ)?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

13. តើការផ្លាស់ប្តូរបរិបទសិក្សា រៀនពីចម្ងាយ/E-learning ក្នុងពេលជម្ងឺរាតត្បាតកូវីដ-១៩ មានផលវិបាកកម្រិតណាសម្រាប់អ្នកទាំងអស់គ្នា? (១០មានការលំបាកណាស់ ហើយ១គ្មានការលំបាកទេ)

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

14. តើអ្នកអាចគ្រប់គ្រងពេលវេលាបានល្អកម្រិតណាក្នុងពេលរៀនពីចម្ងាយ/E-learning នេះ? (សន្មតថា ១០ ល្អណាស់ ហើយ១ មិនល្អ)

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

15. បើតាមគំនិតអ្នក តើអ្នកចូលចិត្តរៀនពីចម្ងាយ/E-learning ដែរឬទេ?

- o ចូលចិត្តណាស់
- o ចូលចិត្តដែរ
- o មិនចូលចិត្ត

16. កាលពីឆ្នាំ២០២០កន្លងទៅ តើអ្នកទទួលបានលទ្ធផលយ៉ាងដូចម្តេច ចំពោះការសិក្សាតាមអនឡាញ/E-learning នេះ?

- o ល្អ
- o ល្អបង្គួរ
- o ល្អមធ្យម
- o ខ្សោយ

17. ក្រៅពីបញ្ហាដែលបានរៀនរាប់ខាងលើ, តើអ្នកគិតថាការរីករាលដាលនៃជម្ងឺកូវីដ-១៩ ផ្តល់ផលលំបាកអ្វីផ្សេងទៀត មកលើការសិក្សាអប់រំរបស់អ្នកក្នុងអំឡុងពេលរៀនពីចម្ងាយ/E-learning? បើមានសូមជួយរៀបរាប់ត្រួសៗ

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

18. ក្រៅពីផលប៉ះពាល់, តើអ្នកគិតថាការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដែលធ្វើឱ្យការសិក្សាត្រូវពឹងផ្អែកតាម E-learning, បានផ្តល់ផលវិជ្ជមានអ្វីខ្លះដល់អ្នក? បើមានសូមជួយរៀបរាប់ត្រួសៗ

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

# ឧបសម្ព័ន្ធទី២

ឧបសម្ព័ន្ធទី២៖ ផលលំបាកផ្សេងៗទៀតនៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ មកលើការសិក្សាអប់រំរបស់អ្នកក្នុងអំឡុងពេលរៀនពីចម្ងាយ/E-learning ដែលសិស្ស និស្សិតបានជួបប្រទះគឺ៖

- ពិបាកក្នុងការផ្តោតអារម្មណ៍ ពិបាកសម្របខ្លួននៅពេល មិនសូវចាប់បាននៅពេលដែលគ្រូបង្រៀន (១៤ករណី)
- គុណភាពអប់រំមិនសូវល្អដូចពេលរៀនផ្ទាល់ក្នុងថ្នាក់រៀន ហើយចំណេះដឹងទាបជាងមុន (១៩ករណី)
- មានបញ្ហាInternet (២៩ករណី)
- ខ្វះសម្ភារៈក្នុងការសិក្សាតាមអនឡាញ (៩ករណី)
- លទ្ធផលធ្លាក់ចុះ រៀនខ្សោយជាងមុន (១០ករណី)
- ពិបាកជួបគ្រូ ពេលរៀនមិនសូវយកចិត្តទុកដាក់ (៥ករណី)
- គ្មានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាពីចម្ងាយ (៦ករណី)
- ប៉ះពាល់សេដ្ឋកិច្ចទាំងមូលរបស់ប្រទេស (៨ករណី)។

# ឧបសម្ព័ន្ធទី៣

ឧបសម្ព័ន្ធទី៣៖ ផលវិជ្ជមានមួយចំនួន នៃការរីករាលដាលនៃជម្ងឺកូវីដ-១៩ ដែលធ្វើអោយការសិក្សាត្រូវពឹងផ្អែកតាមE-learning ដែលសិក្ស និស្សិតបានបញ្ជាក់ដូចខាងក្រោម៖

- សិស្ស និស្សិតមានភាពស្រាវជ្រាវជាងមុន និងស្វែងយល់ខ្លួនឯងច្រើនជាងមុន (៣៥ករណី)
- យល់ដឹងទាក់ទងនឹងបច្ចេកវិទ្យ,E-learning កាន់តែប្រសើរជាងមុន (៣២ករណី)
- ចំណេញពេលវេលា បានរៀននូវអ្វីដែលថ្មីទាក់ទងនឹងទម្រង់សិក្សាថ្មីនេះ មិនខាតពេលជិះទៅសាលារៀន
- (២០ករណី)
- កាត់បន្ថយការចំណាយ កាត់បន្ថយការជួបជុំ មានសុវត្ថិភាព (១៣ករណី) ។

# ឧបសម្ព័ន្ធទី៤

# ច្បាប់

# ស្តីពី

# ការអប់រំ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/១២០៧/០៣២

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអប់រំ ដែលរដ្ឋសភា បានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DE CAMBODGE

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.- គោលដៅ

ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងលក្ខខណ្ឌតម្រូវថ្នាក់ជាតិ សម្រាប់កសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព ដែលធានាបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២.- គោលបំណង

ច្បាប់នេះមានគោលបំណងអភិវឌ្ឍធនធានមនុស្ស ដោយផ្តល់ការអប់រំពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដើម្បីឱ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញ សមត្ថភាព សេចក្តីថ្លៃថ្នូរ អាកប្បកិរិយាប្រកបដោយសីលធម៌ សំដៅជំរុញឱ្យអ្នកសិក្សាស្គាល់ ស្រឡាញ់ រួមចំណែកការពារអត្តសញ្ញាណជាតិ វប្បធម៌ជាតិ និងភាសាជាតិ ។

### មាត្រា ៣.- វិសាលភាពអនុវត្តន៍

ច្បាប់នេះមានវិសាលភាពលើគ្រប់កម្មវិធីអប់រំ សិក្សាស្រាវជ្រាវ អប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ គ្រប់កម្រិតភូមិសិក្សាសាធារណៈ និងឯកជននៃប្រព័ន្ធអប់រំ ទោះជាកម្មវិធីអប់រំនោះ ធ្វើឡើងនៅក្នុងស្ថាប័នអប់រំ ឬ ដោយបុគ្គលិកអប់រំព្រមទាំងគ្របដណ្តប់លើរដ្ឋបាលកិច្ចនិងការគ្រប់គ្រងការអប់រំគ្រប់កម្រិត លើកលែងតែការអប់រំអំពីគម្ពីរសាសនា ការអប់រំខាងបច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខ ការអប់រំខាងផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ការអប់រំដែលផ្តល់ដោយសាលាភូមិន្ទរដ្ឋបាល និងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈតុលាការដែលផ្តល់ដោយស្ថាប័នបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈច្បាប់ និងតុលាការ ។

ច្បាប់នេះអនុវត្តផងដែរលើបុគ្គល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដូចជាកុមារដែលស្ថិតក្នុងអាយុត្រូវចូលសិក្សា អ្នកសិក្សា មាតាបិតា ឬ អ្នកអាណាព្យាបាល ក្រុម ឬ ក្លឹបអ្នកសិក្សា និងបុគ្គលិកអប់រំ ព្រមទាំងអ្នកកាន់អាជ្ញាប័ណ្ណអប់រំ និងសិទ្ធិវន្តនៃអាជ្ញាប័ណ្ណអប់រំ លើកលែងតែអ្នកពាក់ព័ន្ធក្នុងការអប់រំ និង ប្រតិបត្តិខាងសាសនា បច្ចេកទេស យុទ្ធសាស្ត្រយោធា និងសន្តិសុខ ផ្នែកគ្រប់គ្រងរដ្ឋបាលដែនដី ផ្នែកភូមិន្ទរដ្ឋបាល និងផ្នែកវិជ្ជាជីវៈតុលាការ ។

ROYAUME DU CAMBODGE • LE MINISTERE ... ROYAL • ព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៤.– និយមន័យការអប់រំ និងវាក្យស័ព្ទសំខាន់ៗ**

ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬ ការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក ។

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ឧត្តមក្រុមប្រឹក្សាជាតិអប់រំ

**មាត្រា ៥.– ការបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ**

ត្រូវបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដែលមានភារកិច្ច :

-លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល

-វាយតម្លៃការងារ ដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល ។

-កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ

**មាត្រា ៦.– សមាសភាព និង ការរៀបចំ និងការប្រព្រឹត្តទៅ**

ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ស្ថិតក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងក្នុងចំណោមឥស្សរជនដែលមានបទពិសោធន៍ខាងអប់រំ នយោបាយ សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកទេស វប្បធម៌ ។

សមាសភាពរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ ត្រូវកំណត់ដោយអនុ-